ADB



ក្របខ័ណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្ររបស់យើង

# ការប្រឆាំងអំពើពុករលួយ និងសុចរិតភាព

បោះពុម្ពផ្សាយឆ្នាំ ខែ តុលា ២០១០

កំណែទី ២

Asian Development Bank

ADB

ក្របខ័ណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្ររបស់យើង

# ការប្រឆាំងអំពើពុករលួយ និងសុចរិតភាព

បោះពុម្ពផ្សាយឆ្នាំ ខែ តុលា ២០១០

Asian Development Bank

© ធនាគារអភិវឌ្ឍន៍អាស៊ី 2010

រក្សាសិទ្ធិគ្រប់យ៉ាង បោះពុម្ពផ្សាយឆ្នាំ 2010
បោះពុម្ពនៅប្រទេសហ្វីលីពីន

ISBN: 978-92-9092-428-9
សន្និធិបោះពុម្ពលេខ: TIM114001

លីបិក្រមក្នុងទិន្នន័យបោះពុម្ពផ្សាយ

ការប្រឆាំងអំពើពុករលួយ និងសុចរិតភាព
ទីក្រុងម៉ែនដាលលូយ៉ង់ ប្រទេសហ្វីលីពីន: ធនាគារអភិវឌ្ឍន៍អាស៊ី 2010

1. អំពើពុករលួយ 2. អភិបាលកិច្ច 3. គម្រោងអភិវឌ្ឍន៍ផ្សេងៗ

I. ធនាគារអភិវឌ្ឍន៍អាស៊ី

ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅនេះ គឺជាទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយវាមិនឆ្លុះបញ្ចាំងពីទស្សនៈ និងគោលនយោបាយ ផ្សេងៗទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬ ក្រុមប្រឹក្សាភិបាលរបស់ខ្លួន ឬរដ្ឋាភិបាលដែលខ្លួនតំណាងឡើយ ។

ADB មិនធានានូវភាពជាក់លាក់នៃទិន្នន័យ ដែលបានប្រើប្រាស់នៅក្នុងការបោះពុម្ពផ្សាយនេះឡើយ ហើយក៏មិនទទួលខុសត្រូវចំពោះ ផលវិបាកណាមួយដែលកើតឡើងដោយសារការប្រើប្រាស់ទិន្នន័យទាំងនេះដែរ ។

ពាក់ព័ន្ធទៅនឹងអធិបតេយ្យភាពដែនដី ឬភូមិសាស្ត្រណាមួយ ឬការប្រើប្រាស់វាក្យស័ព្ទ "ប្រទេស" ក្នុងឯកសារនេះ ADB មិនមានចេតនា ធ្វើការវិនិច្ឆ័យណាមួយទាក់ទងទៅនឹងផ្នែកច្បាប់ ឬផ្នែកផ្សេងៗទៀត នៃអធិបតេយ្យភាពដែនដី ឬតំបន់ណាមួយឡើយ ។

ADB លើកទឹកចិត្តអោយមានការបោះពុម្ព ឬថតចំលងព័ត៌សម្រាប់ប្រើប្រាស់ជាលក្ខណៈបុគ្គល និងលក្ខណៈមិនមានជាធុរកិច្ច តែត្រូវ មានការទទួលស្គាល់ត្រឹមត្រូវពី ADB ជាមុនសិន។ អ្នក ប្រើប្រាស់ទាំងឡាយត្រូវបានហាមឃាត់មិនអោយមានការលក់បន្ត ចែកចាយបន្ត ឬដកស្រង់ការងារពីច្បាប់ដើមសម្រាប់ធ្វើធុរកិច្ចផ្សេងៗដោយគ្មានការយល់ព្រមជាផ្លូវការពី ADB។

កំណត់ចំណាំ:
ក្នុងការបោះពុម្ពផ្សាយនេះ "$" មានន័យថា ជាដុល្លារសហរដ្ឋអាមេរិច ។

Asian Development Bank
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel +63 2 632 4444
Fax +63 2 636 2444
www.adb.org

សម្រាប់ការស្នើសុំ សូមទំនាក់ទំនង:
នាយកដ្ឋានទំនាក់ទំនងសាធារណ:
Fax +63 2 636 2648
adbpub@adb.org

ធនាគារអភិវឌ្ឍនអាស៊ី (ADB) បានខិតខំប្រឹងប្រែងដើម្បីផ្ទៀងផ្ទាត់ទៅលើភាពជាក់លាក់នៃការបកប្រែនេះ។ ភាសាអង់គ្លេស គឺជាភាសាការងាររបស់ ADB ហើយឯកសារច្បាប់ដើមជាភាសាអង់គ្លេសគឺជាឯកសារដែលត្រឹមត្រូវ និងផ្លូវការតែមួយគត់របស់ខ្លួន។ សេចក្តីដកស្រង់ណាមួយចេញពីឯកសារនេះ ត្រូវតែយោងទៅលើឯកសារច្បាប់ដើមក្នុងភាសាអង់គ្លេស" ។

# មាតិកា

## គោលការណ៍ និងសេចក្តីណែនាំសុចរិតភាព (ឧសភា ២០១០) ទំព័រ


I. គោលការណ៍ និងសេចក្តីណែនាំសម្រាប់ការស៊ើបអង្កេត របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ៣

បុព្វកថា ៣

គោលការណ៍ទូទៅ ៤

និយមន័យ ៨

សិទ្ធិ និងកាតព្វកិច្ច ៨

សាក្សី និងគោលដៅ ៨

ការិយាល័យស៊ើបអង្កេត ១០

សេចក្តីណែនាំអំពីនីតិវិធី ១១

ប្រភពនៃបណ្តឹង ១១

ការទទួលពាក្យបណ្តឹង ១២

ការវាយតម្លៃបឋម ១២

ការផ្តល់អាទិភាពចំពោះករណីនៃពាក្យបណ្តឹង ១២

សកម្មភាពស៊ើបអង្កេត ១៣

លទ្ធផលនៃការស៊ើបអង្កេត ១៣

ការផ្តល់ព័ត៌មានទៅអាជ្ញាធរជាតិ ១៤

ការពិនិត្យមើលឡើងវិញ និងការធ្វើវិសោធនកម្ម ១៤

ការបោះពុម្ពផ្សាយ ១៤

II. **ទណ្ឌកម្ម** **១៤**

មូលដ្ឋានសម្រាប់ចាត់វិធានការកែតម្រូវ ១៥

ការជូនដំណឹងដល់បុគ្គល ដែលស្ថិតនៅក្រោមការស៊ើបអង្កេត ១៦

បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ១៦

ភាគីដទៃទៀត ១៦

សកម្មភាពកែតម្រូវ ១៧

រដ្ឋាភិបាល ១៧

បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ១៧

ភាគីដទៃទៀត ១៧

រយៈពេលនៃការហាមឃាត់ ១៩

ការប្តឹងឧទ្ធរណ៍ ២១

ការទទួលស្គាល់ឡើងវិញ ២២

ការបង្ហាញព័ត៌មានជាសាធារណៈ ២៣

ការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ២៣

## គោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ២៥

ឈ្មោះអក្សរកាត់ ២៦
I. សេចក្តីផ្តើម ២៧
II. ការឆ្លើយតបរបស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ៣០
III. និយមន័យនៃអំពើពុករលួយ ៣១
IV. ការខាតបង់ដោយសារអំពើពុករលួយ ៣៣
V. គោលជំហររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំពោះការប្រឆាំងអំពើពុករលួយ ៣៧
VI. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៤៧
VII. ឧបសម្ព័ន្ធ ៤៩
ការគៃបន្លំ និងអំពើពុករលួយ ៥១

# គោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាព

ខែ ឧសភា ឆ្នាំ ២០១០

# I. គោលការណ៍ និងសេចក្តីណែនាំសម្រាប់ការស៊ើបអង្កេត របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ[១]

## បុព្វកថា

បណ្តាស្ថាប័នទាំងនេះ បានអនុម័តរួមគ្នានូវគោលការណ៍ និងសេចក្តីណែនាំរួមសម្រាប់ការស៊ើបអង្កេត ដែលបានរៀបចំឡើង ដោយអង្គភាពស៊ើបអង្កេតរបស់ស្ថាប័ន រៀង១ខ្លួនដូចខាងក្រោម :

- ក្រុមធនាគារអភិវឌ្ឍន៍អាហ្វ្រិក
- ធនាគារអភិវឌ្ឍន៍អាស៊ី
- ធនាគារអឺរ៉ុបសម្រាប់ការស្តារ និងអភិវឌ្ឍន៍
- ក្រុមធនាគារអភិវឌ្ឍន៍អន្តរអាមេរិកកាំង
- ក្រុមធនាគារពិភពលោក

គោលការណ៍ និងសេចក្តីណែនាំទាំងនេះ មានគោលដៅយកមកប្រើប្រាស់ជាការណែនាំ ដើម្បីធ្វើការស៊ើបអង្កេត រួមជាមួយនឹងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលអាចអនុវត្តបាននៅក្នុងអង្គការ[២] ។

| | |
|---|---|
| ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : | គោលការណ៍ និងសេចក្តីណែនាំទាំងនេះ នឹងត្រូវអនុវត្តចំពោះការិយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព (OAI), បុគ្គលិករបស់ការិយាល័យនេះ និងភាគីទាំងឡាយ ដែល OAI អនុញ្ញាត ឬ ដែលប្រធានធនាគារតែងតាំងឱ្យធ្វើការស៊ើបអង្កេតជំនួសឱ្យ OAI និងគ្រប់បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍ អាស៊ីទាំងអស់ ក៏ដូចជាទីប្រឹក្សា និងអ្នកទទួលបានកិច្ចសន្យា ដែលធនាគារអភិវឌ្ឍន៍អាស៊ីជួល និងភាគីទី ៣ ដទៃទៀត ដែលចូលរួមនៅក្នុងសកម្មភាពពាក់ព័ន្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី[៣] ក្នុងការគោរពទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយនេះ[៤] ។ |

ចំពោះគោលបំណងនៃឯកសារនេះ ការប្រើប្រាស់ពាក្យថា "អង្គការ" សំដៅដល់គ្រប់ស្ថាប័នទាំងអស់ដែលជាផ្នែក ឬដែលទាក់ទងនឹងស្ថាប័ន ដែលបានលើកឡើងខាងលើ ។ ចាប់ពីពេលនេះតទៅ អង្គភាពស៊ើបអង្កេតរបស់អង្គការនីមួយ១ ហៅថា "ការិយាល័យស៊ើបអង្កេត" ។

---

[១] គោលការណ៍ និងសេចក្តីណែនាំរបស់ស្ថាប័នហិរញ្ញវត្ថុស្តីពីការស៊ើបអង្កេត ដែលត្រូវបានអនុម័តដោយស្ថាប័នជាច្រើន ត្រូវបានដាក់បញ្ចូលជាផ្នែកទីមួយនៃគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពនេះ ដោយកថាខ័ណ្ឌដែលពាក់ព័ន្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានដាក់បញ្ចូល ។

[២] គោលការណ៍ណែនាំនេះមិនមានគោលបំណងប្រគល់ ដាក់ចេញ ឬផ្តល់ករណីយកិច្ច កាតព្វកិច្ច ឬសិទ្ធិដាក់ពាក្យបណ្តឹងនៅក្នុងច្បាប់តុលាការ ឬក្នុងនីតិវិធីរដ្ឋបាលចំពោះអង្គការ ដែលកំពុងធ្វើការស៊ើបអង្កេតនោះទេ ។ គ្មានចំណុចណាមួយនៅក្នុងគោលការណ៍ណែនាំនេះ ត្រូវបានបកស្រាយ ដែលនាំឱ្យប៉ះពាល់ ដល់សិទ្ធិ និងកាតព្វកិច្ច របស់អង្គការនីមួយ១តាមច្បាប់ គោលនយោបាយ និងនីតិវិធីនានារបស់ខ្លួន ហើយក៏គ្មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិត្រូវផ្តល់ឱ្យអង្គការនីមួយ១ ដោយសន្ធិសញ្ញាអន្តរជាតិ និងច្បាប់របស់ប្រទេសជាសមាជិកឡើយ ។

[៣] "សកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានកំណត់និយមន័យនៅក្នុងកថាខណ្ឌ ១.គ *infra*

[៤] ឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R-89-98 គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានអនុម័តនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៨ ដូចដែលបានបញ្ជាក់នៅក្នុង ឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R185-04 គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយៈ សំណើបញ្ជាក់ និងការផ្លាស់ប្តូរដែលពាក់ព័ន្ធនឹងសេចក្តីណែនាំអំពីការពិគ្រោះយោបល់ និងលទ្ធកម្ម ដែលទទួលបានការអនុម័តនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R179-06 គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយៈ និយមន័យរួមស្តីពីការអនុវត្តអំពើពុករលួយ និងការកេងបន្លំ ដែលត្រូវបានអនុម័តកាលថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។

## គោលការណ៍ទូទៅ

១. អង្គការនីមួយៗ ត្រូវមានការិយាល័យស៊ើបអង្កេតមួយ ដែលទទួលបន្ទុកធ្វើការស៊ើបអង្កេត ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

១.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព គឺជាការិយាល័យទំនាក់ទំនងបឋម និងជាការិយាល័យ ដែលធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តល្មើសនានា ដែលពាក់ព័ន្ធនឹងសកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ឬបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

១.ខ. "ការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព" សំដៅលើសកម្មភាពទាំងឡាយណា ដែលបំពានលើគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជា អំពើពុករលួយ ការកែបន្លំ ការបង្ខិតបង្ខំ ឬការសមគំនិតគ្នា ការរំលោភបំពានទំនាស់ផលប្រយោជន៍ និងការរារាំងបន្ទុចបង្អាក់ ដូចដែលបានកំណត់នៅក្នុងឯកសារនេះ ។

១.គ. "សកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី" រួមមាន សកម្មភាពដែលទទួលហិរញ្ញប្បទានចាត់ចែង ឬគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ឬសកម្មភាពទាំងឡាយណា ដែលមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ឬអាចមានផលប៉ះពាល់ ឬពាក់ព័ន្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី។

២. គោលបំណងនៃការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេត គឺដើម្បីត្រួតពិនិត្យ និងបញ្ជាក់នូវសច្ចភាពនៃការចោទប្រកាន់ពីអំពើពុករលួយ ឬអំពើកែបន្លំ ដូចដែលបានកំណត់ដោយស្ថាប័ននីមួយៗ រួមទាំងការពាក់ព័ន្ធ តែមិនកំណត់ចំពោះគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយអង្គការ និងការចោទប្រកាន់ពីបទប្រព្រឹត្តខុសឆ្គងទៅលើបញ្ហាណាមួយរបស់បុគ្គលិកក្នុងអង្គការឡើយ ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

២.ក. ការប្រព្រឹត្តល្មើសនឹងសុចរិតភាព ដែលការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព អាចធ្វើការស៊ើបអង្កេត រួមមាន :

- i. ការប្រព្រឹត្តអំពើពុករលួយ ដែលជាការផ្តល់ជូន ការឱ្យ ការទទួល ឬការសុំ ដោយផ្ទាល់ ឬដោយប្រយោលនូវនូវអ្វីម្យ៉ាង ដែលមានតម្លៃក្នុងគោលដៅប្រើឥទ្ធិពលមិនត្រឹមត្រូវដល់សកម្មភាពរបស់ភាគីម្ខាងទៀត ។
- ii. ការប្រព្រឹត្តអំពើកែបន្លំ ដែលជាការធ្វើសកម្មភាពអ្វីមួយ ឬការខកខានមិនបានធ្វើសកម្មភាពអ្វីមួយ ដូចជា ការភូតកុហកបំភ្លៃខុសពីការពិតជាក់ស្តែង ដែលនាំឱ្យមានការយល់ខុស ទោះដោយចេតនាក្តី ឬ ដោយធ្វេសប្រហែសក្តី ឬការប៉ុនប៉ងធ្វើឱ្យភាគីម្ខាងទៀតមានការយល់ខុសដើម្បីទទួលបានប្រាក់កាស ឬផលប្រយោជន៍ផ្សេងទៀត ឬដើម្បីគេចចេញពីកាតព្វកិច្ចណាមួយ ។
- iii. ការប្រព្រឹត្តអំពើបង្ខិតបង្ខំ ដែលជាការធ្វើឱ្យទន់ខ្សោយ ឬការបង្កមហន្តរាយ ឬការការគំរាមកំហែងធ្វើឱ្យទន់ខ្សោយ ឬមហន្តរាយដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដល់ភាគីណាមួយ ឬទ្រព្យសម្បត្តិរបស់គូភាគីក្នុងការប្រើឥទ្ធិពលមិនត្រឹមត្រូវ ទៅលើសកម្មភាពរបស់ភាគីម្ខាងទៀត ។
- iv. ការប្រព្រឹត្តអំពើឃុបឃិត ដែលជាការរៀបចំផែនការរវាងភាគីពីរ ឬច្រើន ដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងមិនត្រឹមត្រូវ រួមទាំងការប្រើឥទ្ធិពលមិនត្រឹមត្រូវទៅលើសកម្មភាពរបស់ភាគីម្ខាងទៀត ។[៥]
- v. ការរំលោភបំពាន ដែលជាការលួច ខ្ជះខ្ជាយ ឬការប្រើប្រាស់មិនសមស្របនូវទ្រព្យសម្បត្តិពាក់ព័ន្ធ នឹងសកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ទោះប្រព្រឹត្តដោយចេតនា ឬដោយអចេតនាក្តី។
- vi. ទំនាស់ផលប្រយោជន៍ ដែលជាស្ថានភាពណាមួយ ដែលក្នុងនោះភាគីមួយមានផលប្រយោជន៍ ដែលធ្វើឱ្យជះឥទ្ធិពលមិនល្អដល់ការបំពេញការងារកាតព្វកិច្ច ឬការទទួលខុសត្រូវផ្លូវការ កាតព្វកិច្ចនៃកិច្ចសន្យា ឬការគោរពតាមច្បាប់ និងបទបញ្ជានានាជាធរមាន ។

[៥] និយមន័យនៃអំពើពុករលួយ ការកែបន្លំ ការបង្ខិតបង្ខំ និងការឃុបឃិត ត្រូវបានធ្វើសុខដុមកម្មឱ្យស្របទៅតាមនិយមន័យរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត និងត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី ក្រោមឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R179-06 (supra នៅលេខយោងទី ៣) ។

vii. ការរារាំងបន្ទុចបង្អាក់ ដូចជា (i) ការមានចេតនាបំផ្លាញ ក្លែងបន្លំ ផ្លាស់ប្តូរ ឬការលាក់បាំងភ័ស្តុតាង ដែលមានសារៈសំខាន់ចំពោះការស៊ើបអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ii) ការផ្តល់សេចក្តីថ្លែងក្លែងក្លាយដល់អ្នកស៊ើបអង្កេត ដើម្បីធ្វើឱ្យខូចដល់ការស៊ើបអង្កេត របស់ធនាគារអភិវឌ្ឍន៍អាស៊ី, (iii) ការគម្រាមកំហែង ការបៀតបៀន ឬការសម្លុតភាគីណាមួយ ដើម្បីកុំឱ្យភាគីនោះបង្ហាញពីការដឹងឮរបស់ខ្លួនអំពីបញ្ហា ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត ឬមិនឱ្យមានការបន្តការស៊ើបអង្កេត ឬ (iv) រាំងដល់សិទ្ធិធ្វើសវនកម្ម ឬទទួលព័ត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចបញ្ជាក់នៅក្នុងកិច្ចសន្យា ។

viii. ការបំពានលើទោសទណ្ឌ ដែលដាក់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ។

ix. ការប្រព្រឹត្តល្មើសដទៃទៀត ទៅនឹងគោលនយោបាយប្រឆាំងអំពើពុករលួយ ដូចជាការខកខានមិនអនុលោមទៅតាមស្តង់ដាក្រមសីលធម៌កម្រិតខ្ពស់បំផុតជាដើម ។

x. ការសងសឹកចំពោះអ្នកផ្តល់ព័ត៌មាន ឬសាក្សី ដែលសកម្មភាពបង្កគ្រោះថ្នាក់ ដោយផ្ទាល់ ឬដោយប្រយោល ត្រូវបានផ្តល់ជាអនុសាសន៍ ត្រូវបានគំរាមកំហែង ឬអនុវត្តចំពោះអ្នកផ្តល់ព័ត៌មាន ឬសាក្សី ឬអ្នកដែលមានទំនាក់ទំនងជាមួយអ្នកផ្តល់ព័ត៌មាន ឬសាក្សីក្នុងលក្ខណៈដែលអាចធ្វើឱ្យប៉ះពាល់ដល់ ពាក្យបណ្តឹង ដោយសារតែអ្នកផ្តល់ព័ត៌មាន ឬសាក្សីនោះ រាយការណ៍ ឬសហការនៅក្នុងការស៊ើបអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលការប្រព្រឹត្តបែបនេះត្រូវមានការស៊ើបអង្កេតទៅតាមបញ្ជារដ្ឋបាល (AO) លេខ ២.១០ ។[៦]

២.ខ. ការស៊ើបអង្កេតអាចដាក់បញ្ចូលការប៉ុនប៉ងប្រព្រឹត្តល្មើសទៅនឹងសុចរិភាព ។

២.គ. ការចោទប្រកាន់ពីការប្រព្រឹត្តិមិនត្រឹមត្រូវ របស់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិល្មើសទៅនឹងសុចរិតភាព ឬការសងសឹកចំពោះអ្នកផ្តល់ព័ត៌មាន ឬសាក្សីនានា នឹងត្រូវស៊ើបអង្កេតទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពទាំងនេះ ដូចនៅក្នុងឧបសម្ព័ន្ធទី ២ នៃបញ្ជារដ្ឋបាលលេខ ២.0៧៥ និងបញ្ជារដ្ឋបាលលេខ ២.១០ ។

២.ឃ កាិរយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព អាចស៊ើបអង្កេតអំពីការប្រព្រឹត្តិមិនត្រឹមត្រូវផ្សេងទៀត ទៅតាមបទបញ្ជារដ្ឋបាលលេខ ២.0៤ ទៅតាមការស្នើសុំរបស់ប្រធានធនាគារ ឬអគ្គនាយក នាយកដ្ឋានថវិកាបុគ្គលិក និងប្រព័ន្ធគ្រប់គ្រង ។

៣. កាិរយាល័យស៊ើបអង្កេត ត្រូវរក្សាវត្ថុវិស័យភាពអព្យាក្រឹតភាព និងភាពយុត្តិធម៌ក្នុងដំណើរការស៊ើបអង្កេតទាំងមូល និងធ្វើសកម្មភាពប្រកបដោយសមត្ថភាព និងសុចរិតភាពបំផុត ។ ជាពិសេស កាិរយាល័យស៊ើបអង្កេតត្រូវប្រតិបត្តិការងាររបស់ខ្លួនដោយឯករាជ្យ មិនជាប់ទាក់ទិននឹងអ្នកទទួលខុស-ត្រូវ ឬអ្នកពាក់ព័ន្ធនៅក្នុងសកម្មភាពប្រតិបត្តិ ព្រមទាំងមិនទាក់ទិននឹងបុគ្គលិកដែលជាគោលដៅនៃការស៊ើបអង្កេត និងមិនត្រូវស្ថិតនៅក្រោមឥទ្ធិពលមិនសមស្រប និងការភ័យខ្លាចចំពោះការសងសឹក ។

៤. បុគ្គលិកនៃកាិរយាល័យស៊ើបអង្កេត ត្រូវរាយការណ៍ជូនអ្នកគ្រប់គ្រងឱ្យបានទាន់ពេលនូវទំនាស់ផលប្រយោជន៍សំខាន់ៗ ឬជាក់ស្តែងណាមួយ ដែលគាត់មានជាប់ពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតដែលខ្លួនកំពុងចូលរួម ហើយអ្នកគ្រប់គ្រងត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយទំនាស់នោះ ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ៤.ក. ការបង្ហាញពីទំនាស់ផលប្រយោជន៍ ត្រូវធ្វើឡើងទៅកាន់ប្រធានកាិរយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព ឬតំណាងរបស់គាត់ភ្លាមៗបន្ទាប់ពីការរកឃើញ និងមុនពេលដែលមានការស៊ើបអង្កេតអ្វីមួយ ។ ទំនាស់ផលប្រយោជន៍ដែលពាក់ព័ន្ធនឹងប្រធានកាិរយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព ត្រូវបង្ហាញទៅកាន់ប្រធានធនាគារ ។ សកម្មភាពទាំងឡាយណា ដើម្បីគ្រប់គ្រងទំនាស់ផលប្រយោជន៍ ត្រូវមានការកត់ត្រាជាលាយលក្ខណ៍អក្សរ ។ សកម្មភាព ដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍អាចរួមមាន ប៉ុន្តែមិនកម្រិតត្រឹម ការដកចេញពីការស៊ើបអង្កេត និងការកំហិតលើការទទួលបានឯកសារ និងព័ត៌មានអំពីករណី ។

---

៦ *ការការពារអ្នកផ្តល់ព័ត៌មាន និងសាក្សី*

៧ *វិធានការ និងនីតិវិធីដាក់វិន័យ*

៥. ត្រូវអនុវត្តនីតិវិធីសមស្រប ដើម្បីស៊ើបអង្កេតទៅលើការចោទប្រកាន់ពីអំពើមិនគប្បីចំពោះបុគ្គលិកនៃការិយាល័យស៊ើបអង្កេត ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

៥.ក. របាយការណ៍ពីការចោទប្រកាន់អំពីករណីសង្ស័យថាមានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ឬការប្រព្រឹត្តមិន ត្រឹមត្រូវរបស់បុគ្គលិកគ្រប់គ្រងនៅក្នុងការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព ឬ នាយកដ្ឋានថវិកាបុគ្គលិក និងប្រព័ន្ធគ្រប់គ្រង (BPMSD) អាចបញ្ជូនទៅកាន់អនុប្រធានធនាគារ (ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល) ស្របទៅតាមបញ្ជារដ្ឋបាល AO2.10 ខចែងលេខ ៤.៣។

៥.ខ. របាយការណ៍ពីការចោទប្រកាន់អំពីករណីសង្ស័យថាមានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ឬការ ប្រព្រឹត្តមិនត្រឹមត្រូវរបស់អនុប្រធានធនាគារណាម្នាក់ អាចបញ្ជូនទៅកាន់ប្រធានធនាគារ ស្របទៅតាមបញ្ជា រដ្ឋបាល AO2.10 ខចែងលេខ ៤.៣។

៥.គ. របាយការណ៍ពីការចោទប្រកាន់អំពីករណីសង្ស័យថាមានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ដោយ បុគ្គលិកដទៃទៀតរបស់ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព ទីប្រឹក្សា ឬអ្នកទទួលបានកិច្ចសន្យានានា អាចបញ្ជូនដោយផ្ទាល់ទៅកាន់ប្រធាន ឬនាយកការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព។

៦. អង្គការនីមួយៗ ត្រូវបោះពុម្ពផ្សាយនូវអាណត្តិ និង/ឬរយៈពេលកំណត់នៃការិយាល័យស៊ើបអង្កេតរបស់ខ្លួន ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំដែលពន្លេចឱ្យឃើញនូវសុចរិតភាព និងសកម្មភាពប្រឆាំងការគែបន្លំ និងអំពើពុករលួយនៃការិយាល័យស៊ើបអង្កេតរបស់ខ្លួន ដោយអនុលោមទៅតាមគោលនយោបាយបើកចំហរព័ត៌មាន ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

៦.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI), បុគ្គលិករបស់ការិយាល័យនេះ, ភាគីនានា ដែល OAI អនុញ្ញាត ឬបុគ្គលណាម្នាក់ ដែលប្រធានធនាគារតែងតាំងឱ្យធ្វើការស៊ើបអង្កេតជំនួសឱ្យ OAI ត្រូវធ្វើការវាយតម្លៃលើការចោទប្រកាន់នានា និងធ្វើការស៊ើបអង្កេតទៅតាមគោលការណ៍ និងសេចក្ដីណែនាំទាំងនេះឱ្យបានហ្មត់ចត់ភ្លាមៗ និងត្រូវផ្ដល់ជាអនុសាសន៍អំពីវិធានការរដ្ឋបាល ដើម្បីឱ្យធនាគារអភិវឌ្ឍន៍អាស៊ីអនុវត្តសំដៅដោះស្រាយបញ្ហាប្រឈមទាំងនេះ។

៦.ខ. ក្រោមលក្ខខណ្ឌយោងរបស់ខ្លួន ប្រធាន OAI ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធានធនាគារ ។ គាត់ត្រូវរាយ-ការណ៍ទៅកាន់ប្រធានធនាគារ និងទៅកាន់គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល តាមរយៈប្រធានធនាគារអំពីសកម្មភាព និងលទ្ធផលដែលសម្រេចបានដោយ OAI ។ នៅក្នុងការបំពេញសកម្មភាពរបស់ OAI ប្រធាន OAI និងបុគ្គលិក OAI ដែលទទួលបានការអនុញ្ញាត ត្រូវអាចមានលទ្ធភាពដោយពេញលេញ និង ដោយមិនមានការកំហិត (អាចកាន់កាប់ ឬគ្រប់គ្រងជាបណ្ដោះអាសន្ន) លើព័ត៌មាន និងឯកសារនានា ដែលពាក់ព័ន្ធនឹងគ្រប់សកម្មភាពបុគ្គលិក និងអចលនទ្រព្យរូបវ័ន្តទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការទទួលខុសត្រូវសំខាន់ៗរបស់ OAI រួមមាន :

- សហការជាមួយនឹងនាយកដ្ឋាន/ការិយាល័យដែលពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីគោលនយោបាយ ប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។
- ធ្វើការពិគ្រោះយោបល់ជាមួយនឹងនាយកដ្ឋាន/ការិយាល័យដែលពាក់ព័ន្ធ ដើម្បីស្នើ និងពិនិត្យឡើងវិញ លើនីតិវិធីសមស្របក្រោមគោលនយោបាយប្រឆាំងអំពើពុករលួយនេះ សំដៅធានាយ៉ាងណាឱ្យបុគ្គលិក និងគម្រោង ដែលពាក់ព័ន្ធទាំងអស់អនុលោមទៅតាមស្តង់ដាខ្ពស់បំផុត ដើម្បីរក្សាសុចរិតភាពប្រឆាំងនឹងអំពើពុករលួយ ។
- បំពេញនាទីជាកន្លែងទំនាក់ទំនង សម្រាប់គ្រប់ការចោទប្រកាន់ទាំងអស់អំពីការគែបន្លំ ការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពាននានា ដូចដែលបានកំណត់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ខ្លួន ក្នុងគ្រប់សកម្មភាពនានា ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី រាប់បញ្ចូលទាំងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ ។
- ធ្វើការស៊ើបអង្កេតដោយឯករាជ្យ និងដោយសត្យានុម័តលើការគែបន្លំ និងការប្រព្រឹត្តអំពើពុករលួយ ការឃុបឃិតគ្នា ការបង្ខិតបង្ខំ ទំនាស់ផលប្រយោជន៍ និងការរំលោភបំពានផ្សេងៗ ដែលផ្ទុយទៅនឹង គោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែល OAI បានដឹង ឬបានរកឃើញ។

- ធ្វើការពិនិត្យឡើងវិញលើសកម្មភាព ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលពាក់ព័ន្ធជាមួយនឹងលទ្ធកម្ម ដោយសហការជាមួយនឹងការិយាល័យអគ្គសវនករ និងជាផ្នែកមួយនៃការទប់ស្កាត់ និងរកឱ្យឃើញនូវការគៃបន្លំ ការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពានផ្សេងៗ ។
- ផ្តល់លទ្ធផលរកឃើញចេញពីការស៊ើបអង្កេត ដែលត្រូវធ្វើការតាមដានបន្ត ដូចដែលមានចែងនៅក្នុងគោលការណ៍ និងសេចក្តីណែនាំទាំងនេះ ។
- នៅក្នុងការស៊ើបអង្កេត ត្រូវសម្របសម្រួលជាមួយគណៈគ្រប់គ្រង, ការិយាល័យអគ្គមេធាវី (OGC), BPMSD, និងនាយកដ្ឋាន/ការិយាល័យផ្សេងទៀតទៅតាមការសមស្រប ហើយត្រូវអនុវត្តនីតិវិធី ដែលសមស្រប ដើម្បីកំណត់ថាតើមាន ការគៃបន្លំ ការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពាន នៅក្រោមគោលនយោបាយប្រឆាំងអំពើពុករលួយដែរឬអត់, ប្រមូលភ័ស្តុតាងឱ្យបានគ្រប់គ្រាន់, រៀបចំនីតិវិធី ដែលត្រូវអនុវត្តតាម ដើម្បីរកឱ្យឃើញនូវជនប្រព្រឹត្ត, កំណត់ពីវិសាលភាពនៃការគៃបន្លំការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពាន, បច្ចេកទេសប្រើប្រាស់ និងមូលហេតុនៃការគៃបន្លំ ការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពាន, កំណត់ថាតើចាំបាច់ត្រូវអនុវត្ត ឬពង្រឹងការត្រួតពិនិត្យ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដែរឬទេ និងរៀបចំយន្តការ ដើម្បីជួយបង្ការពីការកើតឡើងនូវការគៃបន្លំការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពានស្រដៀងៗគ្នា ។
- ស៊ើបអង្កេតលើការចោទប្រកាន់ពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលិក ដែលផ្ទុយទៅនឹងគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ( ដូចជា ការគៃបន្លំ, ការប្រព្រឹត្តអំពើពុករលួយ ឬទំនាស់ផលប្រយោជន៍) ឬការរំលោភបំពាន ( ការលួច ការប្រើខ្ជះខ្ជាយ ឬការប្រើប្រាស់មិនត្រូវនូវទ្រព្យសម្បត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ទោះដោយចេតនាក្តី ដោយអចេតនាក្តី) ដោយអនុលោមទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពនេះ និងទៅតាមឧបសម្ព័ន្ធទី ២ នៃបញ្ជារដ្ឋបាល ២.០៤ ។
- ស៊ើបអង្កេតលើការចោទប្រកាន់ពីការប្រព្រឹត្តមិនត្រឹមត្រូវ ដែលបញ្ជូនពីផ្នែកធនធានមនុស្ស ដោយអនុលោមទៅតាមបញ្ជារដ្ឋបាល ២.០៤ ។
- រៀបចំ និងផ្ញើរបាយការណ៍ប្រចាំឆ្នាំទៅកាន់ប្រធានធនាគារ ដោយសង្ខេបអំពីសកម្មភាពនានារបស់ខ្លួន ។
- ពិគ្រោះយោបល់ និងសហការជាមួយនឹងធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬភាគីពាក់ព័ន្ធ ដើម្បីធ្វើការផ្លាស់ប្តូរគំនិត បទពិសោធន៍ និងទស្សនាទានអំពីវិធីដែលល្អបំផុត ដើម្បីដោះស្រាយបញ្ហាគៃបន្លំ អំពើពុករលួយ ឬការរំលោភបំពាននានា ទាំងក្នុង និងក្រៅធនាគារអភិវឌ្ឍន៍អាស៊ី ។

៧. ការិយាល័យស៊ើបអង្កេតត្រូវចាត់វិធានការសមស្រប ដើម្បីជួយរក្សាការសម្ងាត់ចំពោះព័ត៌មានឯកជន ដែលទាក់ទងនឹងការស៊ើបអង្កេត រួមទាំងអត្តសញ្ញាណរបស់ភាគី ដែលជាគោលដៅនៃការស៊ើបអង្កេត និងអត្តសញ្ញាណរបស់ភាគីផ្តល់វត្ថុតាង និងភ័ស្តុតាង ។ បែបបទនៃការរក្សាទុកព័ត៌មាន និងការផ្តល់ព័ត៌មានឱ្យភាគីនៅក្នុងអង្គការ និងភាគីនៅក្រៅអង្គការ រួមទាំងអាជ្ញាធរជាតិ មានចែងនៅក្នុងច្បាប់គោលនយោបាយ និងនីតិវិធីរបស់អង្គការ ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

៧.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ត្រូវរក្សាព័ត៌មាន និងឯកសារនានារបស់ខ្លួន ដោយមានការត្រួតពិនិត្យជាលក្ខណៈរូបវ័ន្តអេឡិចត្រូនិច និងមាននីតិវិធីគ្រប់គ្រាន់ ។ OAI នឹងកំហិតការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត ដោយផ្តល់ព័ត៌មានដល់អ្នកដែលចាំបាច់ត្រូវដឹងតែប៉ុណ្ណោះ ។ អាស្រ័យទៅតាមលក្ខណៈរបស់ករណីជាក់ស្តែង OAI អាចបង្ហាញនូវភ័ស្តុតាងមួយចំនួន ដល់អ្នកដែលកំពុងទទួលរងការស៊ើបអង្កេត[៨] ក្នុងលក្ខណៈមួយ ដែលផ្តល់ការការពារដល់អ្នកផ្តល់ព័ត៌មាន និងសាក្សី ដោយអនុលោមទៅតាមបញ្ជារដ្ឋបាល ២.១០ ។

៧.ខ. មានតែ OAI និងប្រធានធនាគារតែប៉ុណ្ណោះ ដែលអាចចូលមើលឯកសារ និងកំណត់ត្រានានារបស់ OAI បាន ។ OAI ឬប្រធានធនាគារ អាចធ្វើការសម្រេចចិត្តថាតើឯកសារ និងកំណត់ត្រានានារបស់ OAI អាចចែករំលែក ដោយមិនកែសម្រួល ឬមិនដាក់កាលបរិច្ឆេទជាថ្មី ទៅឱ្យភាគីផ្សេងទៀតបាន ដោយអនុលោមទៅតាមបញ្ជារដ្ឋបាល ២.០៤, បញ្ជារដ្ឋបាល ២.១០, គោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈ និង វិធានដែលពាក់ព័ន្ធដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

[៨] "អ្នកទទួលរងការស៊ើបអង្កេត" សំដៅលើភាគី ដែលត្រូវបានគេចោទប្រកាន់ថាបានចូលរួមនៅក្នុងការប្រព្រឹត្តល្មើសនឹងសុចរិតភាព និង/ឬការប្រព្រឹត្តមិនត្រឹមត្រូវ ដែល OAI កំពុង ស៊ើបអង្កេត ។

៨. លទ្ធផលនៃការស៊ើបអង្កេត ត្រូវផ្អែកលើអង្គហេតុ និងការវិភាគដែលស៊ីសង្វាក់គ្នា ដែលរួមទាំងការពិចារណាសមហេតុផលផងដែរ ។

៩. ការិយាល័យស៊ើបអង្កេត ត្រូវផ្ដល់អនុសាសន៍ដែលបានមកពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ដោយមានហេតុផលច្បាស់លាស់ជូនដល់ថ្នាក់ដឹកនាំរបស់អង្គការ ។

១០. គ្រប់ការស៊ើបអង្កេតដែលបានធ្វើឡើងដោយការិយាល័យស៊ើបអង្កេត ត្រូវមានលក្ខណៈរដ្ឋបាលត្រឹមត្រូវ ។

## និយមន័យ

១១. អំពើមិនគប្បី គឺជាការខកខានរបស់បុគ្គលិក ក្នុងការគោរពតាមបទបញ្ញត្តិប្រតិបត្តិ ឬបទដ្ឋានឥរិយាបទដែលកំណត់ដោយអង្គការ ។

> ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ១១.ក ក្រមសីលធម៌ និងស្តង់ដានៃការប្រព្រឹត្តរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានចែងនៅក្នុងបញ្ជារដ្ឋបាល ២.០២[៧] ។ វិធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលរៀបរាប់ពីការប្រព្រឹត្តមិនត្រឹមត្រូវ មានចែងនៅក្នុងបញ្ជារដ្ឋបាល ២.០៤។

១២. បទដ្ឋាននៃភ័ស្តុតាងដែលនឹងត្រូវប្រើប្រាស់ដើម្បីកំណត់ថាតើបណ្ដឹងមួយមានភ័ស្តុតាងត្រឹមត្រូវ ឬគ្មាន គឺត្រូវបានគេកំណត់ជានិយមន័យ មួយឡើងដើម្បីធ្វើការស៊ើបអង្កេត ។ ជាទូទៅ និយមន័យនេះ គឺជាព័ត៌មានដែលបញ្ជាក់ថាអាចមានបញ្ហាអ្វីមួយកើតឡើងពិតប្រាកដជាងមិនអាចមាន ។

> ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ១២.ក ធនាគារអភិវឌ្ឍន៍អាស៊ី អាចចាត់ទុកបទដ្ឋាននៃភ័ស្តុតាងនេះ ថាជាប្រភេទមួយនៃភ័ស្តុតាង ឬជាភ័ស្តុតាង ដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការជឿជាក់យ៉ាងសមហេតុសមផលថា ភាគីមួយបានប្រព្រឹត្តល្មើសក្នុងករណីណាមួយ ដោយធ្វើការពិចារណាពីគ្រប់កត្តា និងកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់។

## សិទ្ធិ និងកាតព្វកិច្ច

### សាក្សី និងគោលដៅ

១៣. សមាជិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "អ្នកផ្ដល់ប្រភពព័ត៌មាន" ស្ថិតក្រោមច្បាប់គោលនយោបាយ និងនីតិវិធីរបស់អង្គការមិនត្រូវជាក្លាយគោលដៅនៃការសងសឹករបស់អង្គការទេ ។ អង្គការ នឹងចាត់ទុកការសងសឹកនេះថាជាអំពើមិនគប្បីមួយផ្សេងទៀត ។

> ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ១៣.ក. ការផ្ដល់ការការពារដល់អ្នកផ្ដល់ព័ត៌មាន និងសាក្សី ត្រូវកំណត់ដោយបញ្ជារដ្ឋបាល ២.១០ ។

១៤. អង្គការនឹងតម្រូវឱ្យបុគ្គលិករាយការណ៍អំពីសកម្មភាពដែលគួរឱ្យសង្ស័យនៃការគៃបន្លំ អំពើពុករលួយ និងទម្រង់ផ្សេងទៀតនៃអំពើមិនគប្បី ។

[៧] *គោលនយោបាយបុគ្គលិក និងភារកិច្ច សិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គលិក ។*

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ីៈ ១៤.ក បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានកាតព្វកិច្ចរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ទៅកាន់ OAI ។ បុគ្គលិកទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តមិនត្រឹមត្រូវផ្សេងទៀត ទៅកាន់ BPMSD ដោយអនុលោមទៅតាមបញ្ញើរដ្ឋបាល ២.១០ ។ បុគ្គលិកអាចរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវបានដោយមិនចាំបាច់សុំការឯកភាព ឬការអនុញ្ញាតជាមុន ។

១៥. អង្គការតម្រូវឱ្យបុគ្គលិកទាំងអស់ ចូលរួមសហការនៅក្នុងការស៊ើបអង្កេត និងឆ្លើយសំណួរផ្សេងៗ ព្រមទាំងអនុវត្តតាមការស្នើរសុំព័ត៌មាននានា ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ីៈ ១៥.ក. បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានភារកិច្ចសហការពេញលេញនៅក្នុងការពិនិត្យ ឬការស៊ើបអង្កេតអ្វីមួយ នៅពេលដែលមានការស្នើសុំពី OAI ។ ការសហការបែបនេះ រួមមាន ប៉ុន្តែមិនមែនកំហិតត្រឹមតែចំណុចខាងក្រោមឡើយៈ

- មានវត្តមានឱ្យគេសម្ភាស និងឆ្លើយចំពោះសំណួរទាំងអស់ដែលបានសួរ ដោយពេញលេញ និងដោយស្មោះត្រង់ ។
- ផ្តល់ឱ្យ OAI នូវអ្វីៗដែលត្រូវបានស្នើសុំ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលិករូបនោះ ដូចជា ប៉ុន្តែមិនកំហិតត្រឹមឯកសារ និងវត្ថុបរិក្ខាផ្សេងទៀត ។
- សហការនៅក្នុងការធ្វើតេស្តនានា ដែលស្នើឡើងដោយ OAI ដូចជា ប៉ុន្តែមិនកំហិតត្រឹមការកំណត់អត្តសញ្ញាណស្នាមម្រាមដៃ ការវិភាគលើការសរសេរដោយដៃ ការប្រើប្រាស់ឧបករណ៍វិភាគដង្ហើម និងការពិនិត្យ និងវិភាគជាលក្ខណៈរូបវ័ន្ត ។
- ការរក្សា និងការពារការសម្ងាត់នៃគ្រប់ព័ត៌មានទាំងអស់ ដែលត្រូវបានពិភាក្សាជាមួយ OAI នឹង BPMSD ។

១៥.ខ. បុគ្គលិក ដែលស្ថិតក្រោមការស៊ើបអង្កេត ត្រូវផ្តល់លទ្ធភាពឱ្យមានការផ្តល់ព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួនដោយផ្ទាល់ទៅកាន់ OAI ប្រសិនបើមានការស្នើសុំបែបនេះ ។ បន្ទាប់ពីមានការស្នើពី OAI អ្នកដែលស្ថិតក្រោមការស៊ើបអង្កេត ត្រូវផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរដល់ស្ថាប័នហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីបដិសេធចោលនូវសិទ្ធិរក្សាភាពជាឯកជន ឬការរក្សាការសម្ងាត់របស់អ្នកដែលស្ថិតក្រោមការស៊ើបអង្កេត ពាក់ព័ន្ធជាមួយនឹងព័ត៌មាន ដែលត្រូវបង្ហាញ ។

១៥.គ. បុគ្គលិក ដែលស្ថិតក្រោមការស៊ើបអង្កេត អាចស្នើសុំឱ្យបុគ្គលិកម្នាក់ទៀតនៅអមជាមួយខ្លួននៅក្នុងពេលធ្វើការសម្ភាស ដែលជាផ្នែកមួយនៃការស៊ើបអង្កេត ដរាបណាការស្នើបែបនេះ មិនធ្វើឱ្យមានការពន្យារពេល ឬរាំងស្ទះដល់ការស៊ើបអង្កេត ។ ប៉ុន្តែ បុគ្គលិកដែលនៅអមនេះមិនអាចជាបុគ្គលិករបស់ OAI, OGC, ការិយាល័យលេខាធិការ, OAG, ការិយាល័យសេវារដ្ឋបាល ឬ BPMSD បានឡើយ ។ ទាំងអ្នកដែលស្ថិតនៅក្រោមការស៊ើបអង្កេត និងសាក្សីអាចពិគ្រោះយោបល់ជាមួយនឹងទីប្រឹក្សាច្បាប់ខាងក្រៅអំពីបញ្ហា ដែលកំពុងត្រូវបានស៊ើបអង្កេតដោយរ៉ាប់រងសោហ៊ុយនានាដោយខ្លួនឯង ប៉ុន្តែមិនអាចឱ្យទីប្រឹក្សាច្បាប់រូបនេះនៅអមក្នុង បរិវេណការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី ឬក្នុងពេលសម្ភាស ដែលជាផ្នែកមួយនៃការស៊ើបអង្កេតនេះបានឡើយ ។ ការពិគ្រោះយោបល់បែបនេះមិនត្រូវពន្យារពេលការសម្ភាស ឬការអនុលោមរបស់បុគ្គលិកទៅតាមកាតព្វកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រោមវិធានទាំងនេះឡើយលើកលែងតែមានការអនុញ្ញាតពី OAI ។

១៥.ឃ ប្រសិនបើសមាជិកម្នាក់មិនអនុលោមទៅតាមកាតព្វកិច្ច ដែលតម្រូវឱ្យមានការសហការនោះធនាគារអភិវឌ្ឍន៍អាស៊ីអាចចាត់ទុកការបដិសេធបែបនេះ ថាជាចំណុចអវិជ្ជមានមួយ ។ នៅក្នុងករណីបែបនេះ OAI អាចបញ្ជូនករណីនេះទៅកាន់ BPMSD ដើម្បីចាត់វិធានការវិន័យដែលសមស្រប ។ ការខកខានមិនសហការរួមមានការមិនឆ្លើយតបទាន់ពេលវេលា និងមិនបានពេញលេញចំពោះសំណួររបស់ OAI, ការខកខានមិនផ្តល់ឯកសារ ឬភ័ស្តុតាងដទៃទៀត ដែលស្នើសុំដោយ OAI, ការបំផ្លាញ ឬការលាក់បាំងភ័ស្តុតាង ឬការក្លែងបន្លំព័ត៌មាន ក្នុងកំឡុងការស៊ើបអង្កេត ឬធ្វើឱ្យមានការរាំងស្ទះដល់ការស៊ើបអង្កេតរបស់ OAI ។

១៦. អង្គការនីមួយៗ ត្រូវអនុវត្តតាមច្បាប់ គោលនយោបាយ និងនីតិវិធីនានា ហើយដោយស្ថិតក្នុងកម្រិតមួយសមស្របទៅតាមក្របខ័ណ្ឌនៃច្បាប់ និងពាណិជ្ជកម្ម អង្គការទាំងនោះត្រូវបន្ថែមការអនុវត្តទៅលើកិច្ចសន្យាជាមួយភាគីទីបី ជាផ្នែកដែលភាគីពាក់ព័ន្ធនៅក្នុងដំណើរការស៊ើបអង្កេតត្រូវសហប្រតិបត្តិការក្នុងការស៊ើបអង្កេត ។

១៧. អ្នកដែលជាគោលដៅនៃការស៊ើបអង្កេតខ្លួនឯង គឺជាផ្នែកមួយនៃដំណើរការស៊ើបអង្កេត ហើយត្រូវបានគេផ្តល់ឱកាសឱ្យពន្យល់បកស្រាយនូវការប្រព្រឹត្ត និងឱ្យលាតត្រដាងព័ត៌មានរបស់ខ្លួន ។ ច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការគឺជាអ្នកកំណត់ពេលវេលានៃការផ្តល់ឱកាសដល់អ្នកដែលជាគោលដៅនេះ ។

## ការិយាល័យស៊ើបអង្កេត

១៨. ការស៊ើបអង្កេត គួរតែធ្វើឡើងឱ្យបានឆាប់រហ័ស ទៅតាមកម្រិតធនធាន ។

១៩. ការិយាល័យស៊ើអង្កេត គួរតែត្រួតពិនិត្យទាំងព័ត៌មានដែលនាំឱ្យមានការចោទប្រកាន់ និងព័ត៌មានដែលនាំឱ្យរួចផុតពីការចោទប្រកាន់ ។

២០. ការិយាល័យស៊ើបអង្កេតត្រូវរក្សា និងការពារសុវត្ថិភាពឱ្យបានល្អ នូវកំណត់ត្រានៃការស៊ើបអង្កេត និងព័ត៌មានផ្សេងៗដែលប្រមូលបាន ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ២០.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព ត្រូវរក្សា:

- ឯកសារនៃការស៊ើបអង្កេត ដែលពាក់ព័ន្ធជាមួយនឹងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី តិចបំផុត រយៈពេល ៥ ឆ្នាំ ក្រោយពីពេលដែលបុគ្គលិករូបនេះចេញពីធនាគារអភិវឌ្ឍន៍អាស៊ី អាស្រ័យទៅតាម អាយុរបស់បុគ្គលិកនោះ ឬកាលៈទេសៈដែលធនាគារអភិវឌ្ឍន៍អាស៊ី នឹងមិនពិចារណាជួលបុគ្គលិករូបនោះម្តងទៀត ។
- ឯកសារអំពីការស៊ើបអង្កេតផ្សេងទៀត តិចបំផុតរយៈពេល ១០ ឆ្នាំ ចាប់ពីពេលទទួលពាក្យបណ្តឹង ។
- ឯកសារអំពីការពិនិត្យឡើងវិញពាក់ព័ន្ធនឹងលទ្ធកម្មគម្រោង រយៈពេល ៥ ឆ្នាំ បន្ទាប់ពីមានការចេញរបាយការណ៍ ។
- កិច្ចសន្យាពាក់ព័ន្ធនឹងទីប្រឹក្សា ដែលបានជួលឱ្យធ្វើសវនកម្ម និងការស៊ើបអង្កេត តិចបំផុតរយៈពេល ៥ ឆ្នាំ បន្ទាប់ពីការបញ្ចប់កិច្ចសន្យា ។
- លិខិតឆ្លើយឆ្លង ដូចជា លិខិតពីការិយាល័យមួយ ទៅការិយាល័យមួយទៀត និងអនុសាសន៍នានាដល់អ្នកគ្រប់គ្រង តិចបំផុត ៥ ឆ្នាំ ។
- របាយការណ៍ប្រចាំឆ្នាំរបស់ OAI ជូនប្រធានធនាគារ ទុកជារៀងរហូត ។

២១. បុគ្គលិករបស់ការិយាល័យស៊ើបអង្កេត ត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការការផ្សព្វផ្សាយព័ត៌មាននៃការស៊ើបអង្កេត ដោយគ្មានការអនុញ្ញាត ។

២២. ការិយាល័យស៊ើបអង្កេត ត្រូវចងក្រងជាឯកសារនូវលទ្ធផល និងសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេតរបស់ខ្លួន ។

២៣. ក្នុងគោលបំណងនៃការស៊ើបអង្កេតការិយាល័យស៊ើបអង្កេត ត្រូវមានលទ្ធភាពពេញលេញ និងគ្រប់គ្រាន់ដើម្បីប្រមូលព័ត៌មានកំណត់ត្រាបុគ្គលិក និងទ្រព្យសម្បត្តិដែលពាក់ព័ន្ធរបស់អង្គការ ដោយអនុលោមទៅតាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ២៣.ក. បញ្ជារដ្ឋបាល ១.០២[១០] ដែលអាចអនុវត្តបានចំពោះ OAI និងលក្ខខណ្ឌយោងរបស់ OAI ផ្តល់ឱ្យ OAI នូវលទ្ធភាពចូលមើលព័ត៌មាន និងឯកសារនានា ពាក់ព័ន្ធនឹងសកម្មភាពទាំងអស់ របស់ធនាគារអភិវឌ្ឍន៍អាស៊ីយ៉ាងពេញលេញ និងដោយគ្មានការកំហិតអ្វីទាំងអស់ ។ OAI អាចពិនិត្យមើលគ្រប់ឯកសារកំណត់ត្រា

[១០] ព្រឹត្តិបត្រព័ត៌មានរបស់ស្ថាប័ន

ស្បៀវភៅទិន្នន័យ ក្រដាសស្នាមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងឯកសារផ្សេងទៀត ដែលពាក់ព័ន្ធជាមួយនឹង សកម្មភាពនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមការចាំបាច់ និងនៅពេលដែលចាំបាច់ ហើយអាចកាន់កាប់ ឯកសារទាំងនោះជាបណ្តោះអាសន្ន និងធ្វើការថតចម្លង ។

២៣.ខ. សំណើសុំមើលអ៊ីមេល ត្រូវធ្វើឡើងស្របទៅតាមបញ្ជារដ្ឋាល ៤.០៥ ។[១១]

២៤. តាមរយៈខ្លឹមសារដែលចែងក្នុងច្បាប់ គោលនយោបាយ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកិច្ចសន្យាពាក់ព័ន្ធការិយាល័យស៊ើបអង្កេតមាន អំណាចត្រួតពិនិត្យ និងថតចម្លងស្បៀវភៅ និងកំណត់ត្រាដែលពាក់ព័ន្ធនៃគម្រោង ភ្នាក់ងារប្រតិបត្តិ បុគ្គល ឬក្រុមហ៊ុនដែលកំពុងចូលរួម ឬកំពុងព្យាយាមចូលរួមក្នុង សកម្មភាពដែលផ្តល់ហិរញ្ញប្បទានដោយអង្គការ ឬអង្គភាពណាមួយផ្សេងទៀត ដែលចូលរួមក្នុងការចាយវាយមូលនិធិរបស់អង្គការ ។

២៥. ការិយាល័យស៊ើបអង្កេត អាចពិគ្រោះយោបល់ និងសហការជាមួយអង្គការ ស្ថាប័នអន្តរជាតិ និងភាគីផ្សេងទៀតដែលពាក់ព័ន្ធដើម្បីផ្លាស់ប្តូរ យោបល់ បទពិសោធន៍ និងការស្វែងយល់អំពីដំណោះស្រាយដ៏ល្អបំផុត លើបញ្ហាព្រួយបារម្ភទៅវិញទៅមក ។

២៦. ការិយាល័យស៊ើបអង្កេត អាចផ្តល់ជំនួយ និងចែករំលែកព័ត៌មានទៅឱ្យការិយាល័យស៊ើបអង្កេតផ្សេងទៀត ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

២៦.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ឬប្រធានធនាគារ អាចកំណត់ថាតើព័ត៌មាននានា ដូចជា ព័ត៌មានដែលទទួលបានក្នុងពេលធ្វើការស៊ើបអង្កេត អាចត្រូវបានចែករំលែកជាមួយ អង្គការអន្តរជាតិដទៃទៀត, តំណាង ឬទីភ្នាក់ងាររបស់ប្រទេសជាសមាជិកធនគារអភិវឌ្ឍន៍អាស៊ី ឬភាគីដទៃ ទៀត ដែលចាំបាច់ត្រូវដឹងពីព័ត៌មានទាំងនេះ ដើម្បីប្រយោជន៍នៃការសហការ ការធ្វើសុខុដុមកម្ម ឬកត្តាពាក់ ព័ន្ធដទៃទៀត ទៅតាមបញ្ជារដ្ឋបាល ២.០៤, បញ្ជារដ្ឋបាល ២.១០, គោលនយោបាយស្តីពីការប្រាស្រ័យទាក់ ទងសាធារណៈ និងវិធានពាក់ព័ន្ធដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ ។ នៅក្នុងករណី ដែល OAI សម្រេចចិត្តចែករំលែកព័ត៌មាននេះ, OAI ត្រូវតម្រូវឱ្យអ្នកទទួលព័ត៌មាននេះផ្តល់ការការពារដល់ការសម្ងាត់ របស់ព័ត៌មាន ហើយប្រើប្រាស់ព័ត៌មាននេះ តែសម្រាប់គោលបំណងរបស់ OAI នៅក្នុងការបង្ហាញព័ត៌មាននេះ តែប៉ុណ្ណោះ ។

២៦.ខ. OAI អាចសហការ នៅក្នុងការស៊ើបអង្កេតជាមួយអង្គការ ការិយាល័យ ឬភាគីនានាបាន ដរាបណាការ សហការនេះមិនមានឥទ្ធិពលលើឯករាជ្យភាព និងភាពសត្យានុម័តរបស់ OAI ឬធ្វើឱ្យប៉ះពាល់ដល់បុព្វសិទ្ធិ និងអភ័យ ឯកសិទ្ធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

# សេចក្តីណែនាំអំពីនីតិវិធី

## ប្រភពនៃបណ្តឹង

២៧. ការិយាល័យស៊ើបអង្កេត ត្រូវទទួលគ្រប់ពាក្យបណ្តឹងទាំងអស់ ដោយមិនគិតដល់ប្រភព រួមទាំងពាក្យបណ្តឹងអនាមិក ឬពាក្យបណ្តឹងសម្ងាត់ ។ ការិយាល័យស៊ើបអង្កេត ត្រូវតែទទួលស្គាល់នូវការទទួលពាក្យបណ្តឹងទាំងអស់ ប្រសិនបើអាចធ្វើបាន ។

២៨. ការទទួលពាក្យបណ្តឹង

[១១] គោលការណ៍ស្តីពីបច្ចេកវិទ្យា និងទំនាក់ទំនង

## ការទទួលពាក្យបណ្តឹង

២៩. ពាក្យបណ្តឹងទាំងអស់នឹងត្រូវចុះបញ្ជី និងពិនិត្យមើលឡើងវិញដើម្បីសម្រេចថា តើពាក្យបណ្តឹងទាំងនោះស្ថិតនៅក្នុងដែនសមត្ថកិច្ច ឬអំណាចរបស់ការិយាល័យស៊ើបអង្កេតដែរឬទេ ។

## ការវាយតម្លៃបឋម

៣០. នៅពេលដែលពាក្យបណ្តឹងត្រូវបានចុះក្នុងបញ្ជីការិយាល័យស៊ើបអង្កេត ពាក្យបណ្តឹងនោះ នឹងត្រូវការិយាល័យស៊ើបអង្កេតធ្វើការវាយតម្លៃ ដើម្បីកំណត់ភាពដែលអាចជឿបាន ភាពចាំបាច់ និងភាពដែលអាចផ្ទៀងផ្ទាត់បាន ។ ជាចុងបញ្ចប់ ពាក្យបណ្តឹងនឹងត្រូវគេពិនិត្យ ដើម្បីសម្រេចថាតើមានមូលដ្ឋានស្របច្បាប់ណាមួយ ដើម្បីធានាចំពោះការស៊ើបអង្កេតដែរ ឬទេ ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី :

៣០.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ធ្វើការវាយតម្លៃ ឬ "ត្រួតពិនិត្យ" ពាក្យបណ្តឹងនានាដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យខាងក្រោម ដើម្បីកំណត់ថាតើពាក្យបណ្តឹងទាំងនេះត្រូវមានការ ស៊ើបអង្កេតបន្តដែរឬទេ ។ ពាក្យបណ្តឹង គួរមានការចោទប្រកាន់ ឬព័ត៌មានដែល:

- ស្ថិតក្នុងក្របខ័ណ្ឌអណត្តិការងាររបស់ OAI — ពោលគឺពាក់ព័ន្ធជាមួយនឹងសកម្មភាព ដែល OAI ត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត ។
- អាចជឿជាក់បាន — ពោលគឺមានលទ្ធផលសមស្រប ដែលថាការប្រព្រឹត្តល្មើសមួយអាចកើតមានឡើង ។
- អាចផ្ទៀងផ្ទាត់បាន — ពោលគឺមានជម្រើស ដែលអាចទទួលបានភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់ពីភាពពិតប្រាកដ នៃការចោទប្រកាន់ និង
- មានសារៈសំខាន់ — ពោលគឺបញ្ហា ដែលតម្រូវឱ្យមានការស៊ើបអង្កេតនេះ មានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីកំណត់ ពីភាពសមហេតុសមផលនៃការតម្រូវឱ្យមានការស៊ើបអង្កេត និងសកម្មភាពកែតម្រូវនានា
- កត្តាដែលពាក់ព័ន្ធផ្សេងទៀត ឧ. ថាតើបញ្ហានេះអាចត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាពតាមរយៈជម្រើស ដែលធនាគារអភិវឌ្ឍន៍អាស៊ីមានដែរឬទេ

៣០.ខ. នៅពេលបញ្ចប់ការត្រួតពិនិត្យមួយ បុគ្គលិករបស់ OAI ត្រូវផ្តល់អនុសាសន៍ដល់ប្រធានការិយាល័យ OAI ឬតំណាងរបស់គាត់ ថាតើត្រូវបិទពាក្យបណ្តឹងនេះ ឬត្រូវមានការស៊ើបអង្កេតបន្ថែមទៀត ។ ការសម្រេច ចិត្ត ដើម្បីបិទករណីមួយបន្ទាប់ពីមានការត្រួតពិនិត្យ ត្រូវមានការចងក្រងទុកជាឯកសារត្រឹមត្រូវ ដោយមាន របាយការណ៍បិទពាក្យបណ្តឹង ដែលទទួលបានការឯកភាព ដោយមានបង្ហាញពីមូលហេតុ ដែលធ្វើឱ្យមានការ សម្រេចចិត្តបែបនេះ ។ ព័ត៌មាន ដែលពាក់ព័ន្ធជាមួយនឹងពាក្យបណ្តឹងដែលត្រូវបានបិទនេះ ត្រូវរក្សាទុកក្នុង ឯកសាររបស់ OAI ។ អនុសាសន៍ឱ្យមានការស៊ើបអង្កេតបន្តទៀត នឹងត្រូវបានចងក្រងទុកជាឯកសារ តាមរយៈ ផែនការស៊ើបអង្កេតមួយ ដើម្បីធ្វើការផ្ទៀងផ្ទាត់ពីការចោទប្រកាន់នេះ ។

៣០.គ. ប្រសិនបើពាក្យបណ្តឹងមួយពាក់ព័ន្ធជាមួយនឹងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី OAI អាចសម្របសម្រួលការស៊ើបអង្កេតជាមួយនឹង BPMSD ដោយពិចារណាលើបញ្ហារដ្ឋបាលដែលពាក់ព័ន្ធ រួមទាំងលក្ខណៈនៃការប្រព្រឹត្តមិនត្រឹមត្រូវ ដែលអាចកើតមានឡើង ។ OAI ត្រូវធ្វើបែបនេះ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងតាមបែបផែន ដែលមិនមានឥទ្ធិពលលើឯករាជ្យភាព និងភាពសត្យានុម័តរបស់ OAI ។

## ការផ្តល់អាទិភាពចំពោះករណីនៃពាក្យបណ្តឹង

៣១. សេចក្តីសម្រេចនានាសម្រាប់បន្តការស៊ើបអង្កេត ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ឯសេចក្តីសម្រេចសម្រាប់ប្រើប្រាស់សកម្មភាពស៊ើបអង្កេតក្នុងពាក្យបណ្តឹង ត្រូវអាស្រ័យលើការិយាល័យស៊ើបអង្កេត ។

៣២. ការរៀបចំផែនការ និងដំណើរការនៃការស៊ើបអង្កេត ព្រមទាំងធនធានសម្រាប់ប្រើប្រាស់ក្នុងការស៊ើបអង្កេត ត្រូវពិចារណាដល់ទម្ងន់នៃការចោទប្រកាន់ និងលទ្ធផលដែលអាចទទួលបាន ។

## សកម្មភាពស៊ើបអង្កេត

៣៣. ការិយាល័យស៊ើបអង្កេតត្រូវស្វែងរកបន្ថែមទៀត នូវព័ត៌មានលម្អិតដែលខ្លួនមាន ប្រសិនបើអាចធ្វើបាន ។

៣៤. សម្រាប់គោលបំណងនៃការស៊ើបអង្កេត សកម្មភាពស៊ើបអង្កេតរួមមាន ការប្រមូល និងការវិភាគព័ត៌មានតាមឯកសារ វីដេអូ សម្លេង រូបភាព និងតាមអេឡិចត្រូនិច ឬសម្ភារៈផ្សេងៗ ការសម្ភាសន៍សាក្សី ការឃ្លាំមើលរបស់អ្នកស៊ើបអង្កេត និងបច្ចេកទេសស៊ើបអង្កេតផ្សេងទៀត ដែលចាំបាច់ដើម្បីធ្វើការស៊ើបអង្កេត ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ីៈ ៣៤.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាពអាចប្រមូលភ័ស្តុតាងជាឯកសារ វីដេអូ រូបថត ការវិភាគក្នុងកុំព្យូទ័រ ឬខ្សែអាត់សម្លេង ដែលពាក់ព័ន្ធនឹងប្រធានបទនៃការស៊ើបអង្កេត ដោយមិនចាំបាច់ជូនដំណឹង ជាមុនទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដរាបណាសកម្មភាពទាំងនេះស្របទៅតាមវិធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៣៥. សកម្មភាពស៊ើបអង្កេត និងសេចក្តីសម្រេចសំខាន់ៗនានា គួរតែចងក្រងជាឯកសារដោយមានលាយលក្ខអក្សរ ហើយប្រធានការិយាល័យស៊ើបអង្កេតត្រូវពិនិត្យមើលឡើងវិញ ។

៣៦. តាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ទោះបីក្នុងពេលណាមួយក៏ដោយក្នុងកំឡុងពេលកំពុងស៊ើបអង្កេត ប្រសិនបើការិយាល័យស៊ើបអង្កេតយល់ថា ការិយាល័យគួរចាត់ឱ្យមានវិធានការប្រុងប្រយ័ត្នជាមុន ឬដើម្បីការពារព័ត៌មាន រារាំងជាបណ្តោះអាសន្នមិនឱ្យសមាជិក ដែលជាគោលដៅនៃការស៊ើអង្កេតអាចទទួលបានឯកសារ ឬចូលទៅកាន់ការិយាល័យរបស់ខ្លួន ឬផ្តល់អនុសាសន៍ឱ្យព្យួរការងារ ដោយផ្តល់ ឬមិនផ្តល់ប្រាក់កម្រៃ និងផលប្រយោជន៍ផ្សេងៗ ឬផ្តល់អនុសាសន៍ដាក់កំហិតលើសកម្មភាពផ្លូវការរបស់គេ ការិយាល័យត្រូវបញ្ជូនបញ្ហានេះទៅអាជ្ញាធរពាក់ព័ន្ធក្នុងអង្គការដើម្បីចាត់វិធានការសមស្រប ។

៣៧. បើសិនមានលទ្ធភាព ការិយាល័យស៊ើបអង្កេត ត្រូវរៀបចំឱ្យមានសមាជិកពីរនាក់ដើម្បីធ្វើការសម្ភាសន៍ ។

៣៨. តាមឆន្ទានុសិទ្ធិរបស់ការិយាល័យស៊ើបអង្កេត គេអាចប្រើភាសារបស់អ្នកដែលត្រូវសម្ភាសន៍ក្នុងករណីមានអ្នកបកប្រែត្រឹមត្រូវ ។

៣៩. ការិយាល័យស៊ើបអង្កេត នឹងមិនបង់ប្រាក់ទៅឱ្យសាក្សី ឬអ្នកដែលជាគោលដៅ ដើម្បីបានទទួលព័ត៌មានឡើយ ។ តាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ការិយាល័យស៊ើបអង្កេតអាចទទួលខុសត្រូវលើកការចំណាយសមស្របរបស់សាក្សី ឬប្រភពព័ត៌មានផ្សេងទៀត ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ការិយាល័យស៊ើបអង្កេត ។

៤០. ការិយាល័យស៊ើបអង្កេត អាចទំនាក់ទំនងជាមួយភាគីខាងក្រៅ ដើម្បីចូលរួមសហការក្នុងការស៊ើបអង្កេតរបស់ខ្លួន ។

## លទ្ធផលនៃការស៊ើបអង្កេត

៤១. ក្នុងពេលស៊ើបអង្កេត ប្រសិនបើការិយាល័យស៊ើបអង្កេត មិនអាចរកព័ត៌មានគ្រប់គ្រាន់ ដើម្បីបង្ហាញភ័ស្តុតាងចំពោះពាក្យបណ្តឹងនោះទេ ការិយាល័យនឹងចងក្រងលទ្ធផលនេះទុកជាឯកសារ បញ្ចប់ការស៊ើបអង្កេត និងជូនដំណឹងដល់ភាគីពាក់ព័ន្ធតាមការគួរ ។

ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី : ៤១.ក. ប្រធាន OAI និងនាយក OAI ទាំងពីរនាក់ ត្រូវឯកភាពដល់ការបិទករណីស៊ើបអង្កេតណាមួយ ។ នៅក្នុងករណីដែលគេមិនអាចសុំការសុំការឯកភាពពីអ្នកទាំងពីរក្នុងរយៈពេលមួយសមស្របបានទេ ដោយសារតែទីតាំងរូបវ័ន្តរបស់ពួកគេ បុគ្គលិកជាន់ខ្ពស់ OAI ដែលត្រូវបានចាត់តាំង អាចទទួលបានការអនុញ្ញាតឱ្យផ្តល់ការឯកភាពដល់ការសម្រេចចិត្ត ក្នុងនាមជាអាជ្ញាធរដែលមានសិទ្ធិផ្តល់ការឯកភាពបន្ទាប់ពីប្រធាន និងនាយករបស់ OAI ។

៤២. ប្រសិនបើ ការិយាល័យស៊ើបអង្កេតអាចរកព័ត៌មានបានគ្រប់គ្រាន់ ដើម្បីបង្ហាញភ័ស្តុតាងចំពោះពាក្យបណ្តឹង ការិយាល័យនឹងចងក្រងលទ្ធផលនៃការស៊ើបអង្កេតទុកជាឯកសារ ហើយបញ្ជូនលទ្ធផលនៃការស៊ើបអង្កេតនេះទៅអាជ្ញាធរពាក់ព័ន្ធនៅក្នុងអង្គការ ស្របទៅតាម ច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ។

៤៣. ក្នុងករណី លទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតបង្ហាញថា ពាក្យបណ្តឹងនេះមិនត្រឹមត្រូវ ការិយាល័យស៊ើបអង្កេតត្រូវបញ្ជូនបញ្ហានេះ ទៅឱ្យអាជ្ញាធរពាក់ព័ន្ធនៅក្នុងអង្គភាពតាមការគួរ ។

៤៤. ក្នុងករណី លទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតបង្ហាញថា សាក្សី ឬគោលដៅមានការខកខានមិនបានគោរពតាមកាតព្វកិច្ចដែលមានចែងក្នុងដំណើរការស៊ើបអង្កេត ការិយាល័យស៊ើបអង្កេតអាចនឹងបញ្ជូនបញ្ហានេះ ទៅឱ្យអាជ្ញាធរពាក់ព័ន្ធក្នុងអង្គការ ។

## ការផ្តល់ព័ត៌មានទៅអាជ្ញាធរជាតិ

៤៥. ការិយាល័យស៊ើបអង្កេតអាចនឹងពិចារណាថាតើការផ្តល់ព័ត៌មាន ដែលទាក់ទងទៅនឹងពាក្យបណ្តឹងទៅឱ្យអាជ្ញាធរជាតិមានសមត្ថកិច្ចជាការសមស្របដែរឬទេ ហើយការិយាល័យស៊ើបអង្កេតនឹងសុំការអនុញ្ញាតផ្ទៃក្នុងដែលចាំបាច់ ដើម្បីអនុវត្តបែបនេះ ក្នុងករណីដែលខ្លួនជឿជាក់ថាការផ្តល់ព័ត៌មាននេះត្រូវបានធានា។

## ការពិនិត្យមើលឡើងវិញ និងការធ្វើវិសោធនកម្ម

៤៦. រាល់ការធ្វើវិសោធនកម្មណាមួយចំពោះសេចក្តីណែនាំ ត្រូវអនុម័តដោយអង្គការតាមសម្លេងភាគច្រើន ។

## ការបោះពុម្ពផ្សាយ

៤៧. អង្គការណាក៏ដោយ អាចបោះពុម្ពគោលការណ៍ទាំងនេះ ដោយអនុលោមទៅតាមគោលនយោបាយស្តីពីការផ្សព្វផ្សាយព័ត៌មាន ។

# II. ទោសទណ្ឌ

## មូលដ្ឋានសម្រាប់ចាត់វិធានការកែតម្រូវ

៤៨. ការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព អាចជាមូលដ្ឋានសម្រាប់ឱ្យធនាគារអភិវឌ្ឍន៍អាស៊ីចាត់វិធានការកែតម្រូវ រាប់បញ្ចូលទាំងការដាក់ទោសទណ្ឌផងដែរ ។ ការប្រព្រឹត្តល្មើសនេះរួមមាន ការប្រព្រឹត្តល្មើស ដែលអាចមិនពាក់ព័ន្ធនឹងសកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ ។

៤៩. អនុលោមទៅតាមកិច្ចព្រមព្រៀងអំពីការសម្រេចចិត្តអំពីការអនុវត្តការហាមឃាត់ឱ្យគ្នាទៅវិញទៅមក[១២] ធនាគារអភិវឌ្ឍន៍អាស៊ី អាចហាមឃាត់ភាគីទាំងឡាយណាដែលត្រូវបានហាមឃាត់ដោយស្ថាប័នផ្សេងទៀតដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ[១៣] ហើយស្ថាប័នផ្សេងទៀតដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះអាចហាមឃាត់ភាគីទាំងឡាយ ដែលត្រូវបានហាមឃាត់ជាសាធារណៈដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ត្រូវទទួលខុសត្រូវក្នុងការជូនដំណឹងដល់ស្ថាប័នផ្សេងទៀត ដែលចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ អំពីការសម្រេចចិត្តហាមឃាត់នីមួយៗ ដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលស្ថិតនៅក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ និងការកែតម្រូវនានា ដែលមាន ។

៥០. ធនាគារអភិវឌ្ឍន៍អាស៊ីអាចចាត់ទុកថា ការសម្រេចចិត្តរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយទៀត ឬការសម្រេចចិត្តរបស់ស្ថាប័នច្បាប់ ឬនិយ័តកម្ម ដែលថាភាគីមួយខកខានមិនបានអនុលោមទៅតាមស្តង់ដាក្រមសីលធម៌សមស្រប ទៅតាមការកំណត់នៅក្នុងប្រព័ន្ធគោលការណ៍វិធាន ឬភារកិច្ចនានា ដូចជា ច្បាប់ ឬបទប្បញ្ញត្តិរបស់រដ្ឋជាដើម ថាជាការខកខានរបស់ភាគីនោះនៅក្នុងការរក្សានូវស្តង់ដាក្រមសីលធម៌ខ្ពស់បំផុត ដូចដែលបានតម្រូវដោយគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ភាគីនេះអាចត្រូវបានដាក់ឱ្យស្ថិតនៅក្រោមសកម្មភាពកែតម្រូវ អនុលោមទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពទាំងនេះ ។

៥១. ភាគីមួយ ត្រូវបានចាត់ទុកថាជាភាគីដែលទទួលខុសត្រូវលើសកម្មភាព ឬការប៉ុនប៉ងប្រព្រឹត្តសកម្មភាពអ្វីមួយ ដែលអាចជាមូលដ្ឋានសម្រាប់ការចាត់វិធានការកែតម្រូវ ដោយភាគីមួយទៀតរួមទាំង និយោជិត ភ្នាក់ងារ ឬតំណាង ដែលបំពេញការងារឱ្យភាគីនោះផង បើទោះបីជាសកម្មភាពនោះធ្វើឡើង ដោយមានការអនុញ្ញាតជាពិសេស ឬអត់ក៏ដោយ ។

៥២. ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវធានាឱ្យមានដំណើរការត្រឹមត្រូវ យុត្តិធម៌ និងសង្កតភាព ដោយមិនប្រើប្រាស់ដំណើរការតាមផ្លូវច្បាប់ ដែលមានចំពោះភាគីដែលទទួលរងការចោទប្រកាន់ថាបានប្រព្រឹត្តអំពើពុករលួយ ឬការគៃបន្លំ នៅក្រោមប្រព័ន្ធច្បាប់ ឬតុលាការ ។ នីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានលក្ខណៈជានីតិវិធីរដ្ឋបាល និងពុំមានលក្ខណៈជាដំណើរការច្បាប់ ឬតុលាការ ឬដូចដំណើរការច្បាប់ ឬតុលាការនោះឡើយ ។

៥៣. ធនាគារអភិវឌ្ឍន៍អាស៊ីពុំមានគោលបំណងធ្វើឱ្យក្រុមហ៊ុន[១៤] ឬបុគ្គលណាលែងអាចប្រកបអាជីវកម្ម ដោយសារការដាក់ទោសទណ្ឌរបស់ខ្លួនឡើយ បើទោះបីជាហានិភ័យដែលការលែងអាចប្រកបអាជីវកម្មនេះអាចកើតមានឡើង នឹងមិនអាចរារាំងមិនឱ្យធនាគារអភិវឌ្ឍន៍អាស៊ីដាក់ទោសទណ្ឌដែលសមស្របក៏ដោយ ។

---

[១២] ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០ ហើយត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

[១៣] ស្ថាប័នដទៃទៀត ដែលចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ អាចមានដូចជា ក្រុមធនាគារអភិវឌ្ឍន៍អាហ្វ្រិច, ធនាគារអឺរ៉ុបសម្រាប់ការស្ថាបនាឡើងវិញ និងការអភិវឌ្ឍ, ក្រុមធនាគារ អភិវឌ្ឍន៍អន្តរអាមេរិច និងក្រុមធនាគារពិភពលោក ។

[១៤] "ក្រុមហ៊ុន" ត្រូវបានប្រើប្រាស់ជាទូទៅ ហើយសំដៅដល់សាជីវកម្ម ស្ថាប័ន អង្គការ និងស្ថាប័នដទៃទៀត ដែលអាចមានស្ថានភាពផ្លូវច្បាប់ដោយឯករាជ្យ ឬអាចត្រូវបានបែងចែកដាច់ ពីបុគ្គលជាក់លាក់ ដែលបំពេញការងារនៅក្នុងស្ថាប័នទាំងនេះ ។

# ការជូនដំណឹងដល់បុគ្គល ដែលស្ថិតនៅក្រោមការស៊ើបអង្កេត

## បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី

៥៤. ការជូនដំណឹងដល់បុគ្គលិក ដែលត្រូវស្ថិតនៅក្រោមការស៊ើបអង្កេត ត្រូវអនុលោមទៅតាមបញ្ញើរដ្ឋបាល ២.០៤។

## ភាគីដទៃទៀត

៥៥. ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា អ្នកចូលរួមដេញថ្លៃ ទីប្រឹក្សា អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ ឬភាគីទីពាមិនមែនជារដ្ឋាភិបាលណាមួយ ប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ត្រូវចាត់វិធានការសមស្របគ្រប់បែបយ៉ាងទាំងអស់ ដើម្បីបង្ហាញពីលទ្ធផលរកឃើញ និងទោសទណ្ឌដែលអាចកើតមានដល់ភាគី ដែលស្ថិតនៅក្រោមការស៊ើបអង្កេតនោះ ហើយផ្តល់លទ្ធភាពឱ្យភាគីនោះ ធ្វើការឆ្លើយតបមកវិញ។ នៅពេលទំនាក់ទំនងជាមួយភាគីOAI អាចពឹងអាស្រ័យលើសុក្រិតភាពនៃព័ត៌មាន ទំនាក់ទំនង ដែលភាគីនោះបានផ្តល់ដល់ធនាគារអភិវឌ្ឍន៍អាស៊ី។ខណៈពេលដែល OAI ត្រូវធ្វើការខិតខំប្រឹងប្រែងសមស្របគ្រប់បែបយ៉ាងដើម្បីទំនាក់ទំនងទៅកាន់ភាគី ដែលស្ថិតនៅក្រោមការស៊ើបអង្កេត ការខកខានមិនបានទំនាក់ទំនងទៅកាន់ភាគី បើទោះបីជាមានការខិតខំប្រឹងប្រែងទាំងនេះក៏ដោយ នឹងមិនរារាំងធនាគារអភិវឌ្ឍន៍អាស៊ីមិនឱ្យដាក់ទោសទណ្ឌលើភាគីនេះបានឡើយ។

៥៦. នៅពេលបង្ហាញពីលទ្ធផលរកឃើញរបស់ខ្លួនទៅកាន់ក្រុមហ៊ុន ដែលស្ថិតនៅក្រោមការស៊ើបអង្កេត OAI ត្រូវជូនដំណឹងដល់ក្រុមហ៊ុននោះថា ធនាគារអភិវឌ្ឍន៍អាស៊ីអាចដាក់ទោសទណ្ឌលើអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុន និងភាគីដែលពាក់ព័ន្ធផ្សេងទៀត។ OAI ក៏ត្រូវជូនដំណឹង និងបង្ហាញពីលទ្ធផលរកឃើញ និងអនុសាសន៍របស់ខ្លួន ដោយផ្ទាល់ទៅកាន់អ្នកទទួលខុសត្រូវ និងភាគីដែលពាក់ព័ន្ធទាំងនេះអំពីសកម្មភាពកែតម្រូវ ដែលអាចនឹងត្រូវបានអនុវត្តលើពួកគេផងដែរ។

៥៧. ភាគី ត្រូវមានឱកាសឆ្លើយតបចំពោះការចោទប្រកាន់ផ្សេងៗ និងចំពោះភ័ស្តុតាង ដែលប្រឆាំងនឹងពួកគេ។OAI អាចទុកមិនបង្ហាញភ័ស្តុតាង ឬព័ត៌មានមួយចំនួនប្រសិនបើមានមូលហេតុសមស្រប ដើម្បីធ្វើការសន្និដ្ឋានថា ការបង្ហាញពីភ័ស្តុតាង ឬព័ត៌មាននេះអាចបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិត សុខភាព សុវត្ថិភាព ឬសុខុមាលភាព របស់បុគ្គល ឬស្ថាប័នណាមួយ ដូចជាអ្នកផ្តល់ព័ត៌មានជាដើម ឬប្រសិនបើភ័ស្តុតាង ឬ ព័ត៌មាននេះមានលក្ខណៈរសើប ឬត្រូវរក្សាការសម្ងាត់។

៥៨. ភាគីនានា ត្រូវទទួលបានពេលវេលាសមស្រប ដើម្បីផ្ញើឯកសារជាលាយល័ក្ខណ៍អក្សរបង្ហាញពីការឆ្លើយតបរបស់ខ្លួន អមជាមួយនឹងភ័ស្តុតាងនានា ប្រសិនបើមាន ដែលជាទូទៅរយៈពេលនេះមិនត្រូវតិចជាងសាបសិប (៣០) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានលទ្ធផលរកឃើញ និង អនុសាសន៍អំពីការដាក់ទោសទណ្ឌរួចមក។

៥៩. ភាគី ដែលស្ថិតនៅក្រោមការស៊ើបអង្កេតក៏អាចស្នើសុំឱកាស ដើម្បីបង្ហាញដោយផ្ទាល់មាត់ដល់ OAI ផងដែរ ដោយត្រូវផ្តល់នូវមូលហេតុជាក់លាក់សម្រាប់ការស្នើសុំបែបនេះ។

៦០. ប្រសិនបើភាគី ដែលស្ថិតនៅក្រោមការស៊ើបអង្កេតបដិសេធមិនទទួលយកការជូនដំណឹងរបស់ OAI ឬទទួលយកការជូនដំណឹងប៉ុន្តែខកខានមិនបានធ្វើការឆ្លើយតប OAI អាចកាត់យល់ចេញជាអវិជ្ជមានពីការបដិសេធ ឬការខកខានបែបនេះ ហើយការបដិសេធ ឬការខកខានបែបនេះអាចចាត់ទុកថាជាកាលៈទេសៈសម្រាប់ដាក់បន្ទុក។

៦១. OAI ត្រូវធ្វើការវាយតម្លៃឡើងវិញលើករណីមួយបន្ទាប់ពីបានទទួលការឆ្លើយតប ហើយអាចធ្វើការស៊ើបអង្កេតបន្ថែមទៀត និង/ឬ ស្នើសុំព័ត៌មានបន្ថែមពីភាគីដែលស្ថិតនៅក្រោមការស៊ើបអង្កេត។

# សកម្មភាពកែតម្រូវ

## រដ្ឋាភិបាល

៦២. ប្រសិនបើលទ្ធផលរកឃើញបង្ហាញថា មន្ត្រីណាម្នាក់របស់រដ្ឋាភិបាលបានប្រព្រឹត្ត ឬពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាពមួយ OAI នឹងរាយការណ៍ពីលទ្ធផលរកឃើញនេះ ទៅកាន់គណៈគ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ OAI នឹងធ្វើការងារជាមួយ គណៈគ្រប់គ្រង និងនាយកដ្ឋានប្រតិបត្តិការ ដើម្បីធ្វើការវាយតម្លៃលើវិធី ដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចធ្វើការឆ្លើយតប ស្របទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយ និងវិធានគោលនយោបាយ និងនីតិវិធីដទៃទៀត។

## បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី

៦៣. ប្រសិនបើលទ្ធផលរកឃើញបង្ហាញថា បុគ្គលិកណាម្នាក់របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានប្រព្រឹត្តល្មើសទៅនឹងសុចរិតភាពអ្វីមួយ ឬបានប្រព្រឹត្តអំពើមិនត្រឹមត្រូវផ្សេងទៀត ហើយ OAI សន្និដ្ឋានថា BPMSD គួរពិចារណាដាក់វិធានការវិន័យទៅតាមបញ្ជារដ្ឋបាល ២.០៤, OAI ត្រូវរាយការណ៍ពីលទ្ធផលរកឃើញរបស់ខ្លួន ទៅកាន់ BPMSD។ BPMSD ត្រូវទទួលខុសត្រូវតែឯកឯងនៅក្នុងដំណើរការដាក់វិន័យនេះ ទៅតាមបញ្ជារដ្ឋបាល ២.០៤ បើទោះបីជា OAI អាចផ្តល់ដំបូន្មាន និងការគាំទ្រដល់ BPMSD ពេញមួយដំណើរការដាក់វិន័យនេះក៏ដោយ។

## ភាគីដទៃទៀត

៦៤. នៅក្នុងករណីដែលអ្នកចូលរួមដេញថ្លៃ ទីប្រឹក្សា អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ ឬភាគីទី ៣ មិនមែនជារដ្ឋាភិបាលណាមួយ ដែល OAI បានរកឃើញថាបានប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ជំទាស់ទៅនឹងលទ្ធផលរកឃើញនៃការស៊ើបអង្កេត ឬអនុសាសន៍អំពីការដាក់ទោសទណ្ឌរបស់OAI ឬនៅពេលដែលពុំមានការឆ្លើយតបចំពោះលទ្ធផលរកឃើញទាំងនេះ, OAI ត្រូវផ្តល់ដល់គណៈកម្មាធិការត្រួតពិនិត្យ សុចរិតភាពនូវរបាយការណ៍អំពីការស៊ើបអង្កេតរបស់ខ្លួន ដោយមានឯកសារពាក់ព័ន្ធទាំងអស់អមជាមួយ រួមទាំងការឆ្លើយតបចំពោះភាគីចំពោះលទ្ធផលរកឃើញផងដែរ ប្រសិនបើមាន។

៦៥. នៅក្នុងករណីដែលភាគីធ្វើការឆ្លើយតបចំពោះលទ្ធផលរកឃើញនៃការស៊ើបអង្កេត ឬអនុសាសន៍អំពីការដាក់ទោសទណ្ឌរបស់ OAI ហើយមិនជំទាស់ទៅនឹងលទ្ធផលរកឃើញនៃការស៊ើបអង្កេត ឬអនុសាសន៍អំពីការដាក់ទោសទណ្ឌទាំងនេះ, OAI អាចសម្រេចចិត្តថា ធនាគារអភិវឌ្ឍន៍អាស៊ី អាចដាក់ទោសទណ្ឌបានដូចដែលមានចែងនៅក្នុងផ្នែកនេះ។

៦៦. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពមានសមាជិក ដែលមានសិទ្ធិបោះឆ្នោតចំនួន៣នាក់ ដែលក្នុងនោះសមាជិកម្នាក់ត្រូវជ្រើសចេញពីបញ្ជីឈ្មោះសមាជិកខាងក្រៅ។ ប្រធាន OAI ត្រូវដាក់ឈ្មោះ ហើយប្រធានធនាគារត្រូវតែងតាំងសមាជិករបស់គណៈកម្មាធិការនេះចេញ ពីបុគ្គលិកជាន់ខ្ពស់របស់ ADB និងអ្នកដែលមានឈ្មោះល្បីខាងក្រៅ ដែលមិនមែនជាបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបំពេញការងារក្នុងរយៈពេលកំណត់មួយ១៥។ នាយក OAI ឬបុគ្គលិកដទៃទៀត ទៅតាមការសម្រេចរបស់ប្រធានធនាគារត្រូវបំពេញនាទីជាលេខាធិការដ្ឋាន (មិនអាចបោះឆ្នោតបាន) សម្រាប់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ហើយត្រូវធានាយ៉ាងណាឱ្យសមាជិក ដែលត្រូវបានជ្រើសរើសសម្រាប់កិច្ចប្រជុំនីមួយៗ ពុំមានទំនាស់ផលប្រយោជន៍នៅពេលចូលរួមនៅក្នុងការពិភាក្សា និងការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព។ បុគ្គលិក រាប់បញ្ចូលទាំងតំណាងមកពីការិយាល័យសេវាប្រតិបត្តិការកណ្តាល និងការិយាល័យអគ្គមេធាវី ប្រហែលជានឹងត្រូវអញ្ជើញឱ្យផ្តល់ដំបូន្មាន ដល់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព។ ការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន ប៉ុន្តែត្រូវរាប់បញ្ចូលសម្លេងឆ្នោតរបស់សមាជិករបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ដែលមកពីខាងក្រៅធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ នៅក្នុងករណីដែលសម្លេងរបស់សមាជិកខាងក្រៅ មិនមែនជាផ្នែកមួយនៃការសម្រេចចិត្តដោយសម្លេងភាគច្រើន លេខាធិការដ្ឋានត្រូវរៀបចំឱ្យមានជាកិច្ចប្រជុំថ្មីមួយ ដោយមានការចូលរួមពីសមាជិកទាំង ៣ រូប ដែលបានពិភាក្សាពីករណី នេះតាំងពីដំបូង ឬក៏រួមទាំងសមាជិកខាងក្នុងម្នាក់ និងសមាជិកខាងក្រៅម្នាក់ទៀត។ នៅក្នុងកិច្ចប្រជុំទី ២ របស់គណៈកម្មាធិការត្រួតពិនិត្យ សុចរិតភាព ដើម្បីពិភាក្សាអំពីករណីនេះ ការសម្រេចចិត្តត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន។

---

[16] ជាធម្មតា អាណត្តិនេះមានរយៈពេល ២៤ ខែ ប៉ុន្តែប្រធាន វីភី និង/ឬប្រធានធនាគារ អាចកំណត់ពីរយៈពេលផ្សេងពីនេះ។

៦៧. ការបង្ហាញព័ត៌មានពីទំនាស់ផលប្រយោជន៍ ត្រូវធ្វើឡើងចំពោះគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពតាមរយៈលេខាធិការដ្ឋាននេះ។ សមាជិក ឬទីប្រឹក្សារបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព មិនត្រូវចូលរួមនៅក្នុងការពិភាក្សា ឬការសម្រេចចិត្តណា ដែលពាក់ព័ន្ធនឹងបញ្ហាដែលខ្លួនមានទំនាស់ផលប្រយោជន៍ឡើយ។ ប្រសិនបើមានការជំទាស់ថាតើមានទំនាស់ផលប្រយោជន៍ដែរឬអត់ សមាជិកដទៃទៀតរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ត្រូវធ្វើការសម្រេច ចិត្ត។ ការដកខ្លួនចេញ និងការសម្រេចចិត្តអំពីទំនាស់ផលប្រយោជន៍ នឹងត្រូវចងក្រងទុកជាឯកសារលាយល័ក្ខណ៍អក្សរដោយលេខាធិការដ្ឋាន។

៦៨. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ត្រូវកំណត់ថាតើមានមូលដ្ឋានសម្រាប់ចាត់វិធានការកែតម្រូវដែរឬទេ ដោយផ្អែកទៅតាមភ័ស្តុតាងនានានៃរបាយការណ៍របស់ OAI និងព័ត៌មានផ្សេងទៀត ដែលគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពអាចស្នើសុំ ឬបង្ហាញជូនដើម្បីបង្ហាញថា ភាគីដែលស្ថិតក្រោមការស៊ើបអង្កេតពិតជាបានប្រព្រឹត្តល្មើសទៅនឹងគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមែន។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព អាចផ្តល់នូវអនុសាសន៍ពាក់ព័ន្ធនឹងករណីដែលគណៈកម្មាធិការនេះបានធ្វើការពិចារណា ហើយអាចធ្វើការពិចារណាថាតើត្រូវផ្សព្វផ្សាយជាសាធារណៈអំពីឈ្មោះក្រុមហ៊ុន ឬបុគ្គល ដែលត្រូវបានហាមឃាត់ទៅតាមកថាខ័ណ្ឌទី ១០០ ដែរឬទេ នៅក្នុងករណីលើកលែងមួយចំនួន។

៦៩. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចធ្វើការកំណត់ថាតើភាគីមួយនឹងពុំមានលក្ខណៈសម្បត្តិសមស្រប ដើម្បីចូលរួមនៅក្នុងសកម្មភាព ដែលទទួលបានហិរញ្ញប្បទាន ចាត់ចែង ឬគ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ីដែរឬអត់ ៖

(ក) **ការហាមឃាត់:** ការហាមឃាត់ឆ្លុះបញ្ចាំងពីការសម្រេចចិត្តរដ្ឋបាល ថានឹងមិនមានការធ្វើធុរកិច្ចជាមួយនឹងភាគី ដែលធនាគារអភិវឌ្ឍន៍អាស៊ីមិនបានចាត់ទុកថាបានបំពេញទៅតាមស្តង់ដាក្រមសីលធម៌កម្រិតខ្ពស់បំផុត។ ជាធម្មតា ការហាមឃាត់នេះនឹងមិនប៉ះពាល់ដល់កាតព្វកិច្ចក្រោមកិច្ចសន្យា ដែលមានស្រាប់ឡើយ ប៉ុន្តែគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចផ្តល់ជាអនុសាសន៍ឱ្យលុបចោលកាតព្វកិច្ចក្រោមកិច្ចសន្យា ដែលមានស្រាប់។

ការហាមឃាត់ ដែលមិនសំដៅលើការហាមឃាត់ជារៀងរហូត ត្រូវមានរយៈពេលកំណត់ជាអប្បបរមា។ បន្ទាប់ពីរយៈពេលទោសទណ្ឌផុតកំណត់ ការទទួលស្គាល់ឡើងវិញមិនមែនធ្វើឡើងដោយស្វ័យប្រវត្តិនោះឡើយ ប៉ុន្តែភាគី ដែលត្រូវបានហាមឃាត់អាចស្នើសុំឱ្យមានការទទួលស្គាល់ជាថ្មី។ បន្ទាប់ពីទទួលបានការស្នើសុំឱ្យមានការទទួលស្គាល់ជាថ្មី ធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈ OAI ត្រូវធ្វើការវាយតម្លៃឡើងវិញលើទោសទណ្ឌនេះ ដើម្បីសម្រេចថាត្រូវទទួលស្គាល់ភាគីនេះឡើងវិញ ឬត្រូវបន្តរយៈពេលទោសទណ្ឌនេះបន្តទៀត (ឧ. ប្រសិនបើភាគីនេះត្រូវបានគេដឹងថា បានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព នៅក្នុងរយៈពេលជាប់ទោសទណ្ឌរបស់ខ្លួន) ដោយអនុលោមទៅតាមនីតិវិធីស្តីពីការទទួលស្គាល់ជាថ្មី ដែលបានបញ្ជាក់ខាងក្រោម។

(ខ) **ការហាមឃាត់ ជាមួយនឹងការទទួលស្គាល់ឡើងវិញដោយមានលក្ខខណ្ឌ:** គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចចិត្តថាគួរហាមឃាត់ភាគីណាមួយ ប៉ុន្តែត្រូវកំណត់លក្ខខណ្ឌជាក់លាក់ ដែលអាចជួយកាត់បន្ថយរយៈពេលហាមឃាត់ ប្រសិនបើភាគីអាចបំពេញទៅតាមលក្ខខណ្ឌទាំងនោះបាន។ លក្ខខណ្ឌទាំងនេះអាចមានដូចជា ៖ (i) ការកែលំអសុចរិតភាព និង/ឬការត្រួតពិនិត្យរបស់ក្រុមហ៊ុន ឬការអនុវត្តកម្មវិធីអនុលោមរបស់ក្រុមហ៊ុន, (ii) ចាត់វិធានការដើម្បីដាក់វិន័យ/បញ្ឈប់ការងាររបស់អ្នកទទួលខុសត្រូវលើការប្រព្រឹត្តបំពានសុចរិតភាព, (iii) កែលំអគ្រោះថ្នាក់ ដែលបង្កឡើងដោយការប្រព្រឹត្តបំពានសុចរិតភាព ដូចជាការកែតម្រូវ ឬសងត្រលប់ទៅវិញ ជាដើម។

(គ) **ការមិនហាមឃាត់ ដោយមានលក្ខខណ្ឌ:** គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចចិត្តថាមិនចាំបាច់មានការហាមឃាត់ដល់ភាគីមួយឡើយ ប្រសិនបើវិធានការមួយចំនួនត្រូវបានអនុវត្តដោយភាគីនោះ។ នៅក្នុងករណីបែបនេះ ភាគីដែលទទួលទោសទណ្ឌមិនត្រូវបានហាមឃាត់ឡើយ ប៉ុន្តែចាំបាច់ត្រូវអនុលោមទៅតាមលក្ខខណ្ឌ ដែលកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ក្នុងរយៈពេលមួយកំណត់។ ប្រសិនបើភាគីដែលទទួលទោសទណ្ឌខកខានមិនបានបង្ហាញពីការអនុលោមទៅតាមលក្ខខណ្ឌទាំងនេះនៅក្នុងរយៈពេលដែលបានកំណត់នោះទេ នោះការហាមឃាត់នឹងចូលជាធរមានដោយស្វ័យប្រវត្តិ ក្នុងរយៈពេលអប្បបរមា ដែលកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI នៅពេលមានការសម្រេចចិត្តអំពីការមិនហាមឃាត់ដោយមានលក្ខខណ្ឌ។

៧០. ទោសទណ្ឌដទៃទៀត ដែលគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចឱ្យធនាគារអភិវឌ្ឍន៍អាស៊ីដាក់ រួមមាន៖

(ក) **ការស្តីបន្ទោស:** ការស្តីបន្ទោស គឺជាបន្ទោសដល់សកម្មភាពរបស់ភាគីមួយ និងការជូនដំណឹងថាការប្រព្រឹត្តបំពានលើកក្រោយ នឹងទទួលរងការដាក់ទោសខ្លាំងជាងនេះ។ ការស្តីបន្ទោសជាលាយល័ក្ខណ៍អក្សរ គឺសមស្របសម្រាប់ករណីដែលមានការត្រួតពិនិត្យមិន គ្រប់គ្រាន់ណាមួយ ឬនៅក្នុងករណីដែលការប្រព្រឹត្តបំពានសុចរិតភាព ឬតួនាទីរបស់ភាគីមានត្រឹមតែតិចតួចប៉ុណ្ណោះនៅក្នុងករណីប្រព្រឹត្តបំពាននេះ។

(ខ) **ការទារឱ្យសង និង/ឬការផ្តល់សំណង:** ការទារឱ្យសង និងការផ្តល់សំណងហិរញ្ញវត្ថុផ្សេងទៀត អាចត្រូវបានប្រើប្រាស់នៅក្នុងករណីដែលចាំបាច់ត្រូវមានការផ្តល់សំណងក្នុងចំនួនមួយដល់ប្រទេស ឬគម្រោង ដែលជាអតិថិជនវិញ ។ ទោសទណ្ឌបែបនេះអាចត្រូវបានដាក់ដោយឯកឯង ឬដោយរួមគ្នាជាមួយនឹងទោសទណ្ឌដទៃទៀត ។

៧១. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ក៏អាចសម្រេចឱ្យធនាគារអភិវឌ្ឍន៍អាស៊ីចាត់វិធានការកែតម្រូវផ្សេងទៀត ដែលមិនមែនជាការដាក់ទោសទណ្ឌ ដូចជា លិខិតឱ្យមានការប្រុងប្រយ័ត្នជាដើម នៅក្នុងករណីដែលភាគីមានការខ្វះខាត ប៉ុន្តែមិនប្រព្រឹត្តបំពាននឹងសុចរិតភាព ( ឧ. ការធ្វេសប្រហែសជាធម្មតាជាដើម) ។

៧២. ការស្តីបន្ទោស ការប្រាប់ឱ្យប្រុងប្រយ័ត្ន ឬការព្រមាន មិនប៉ះពាល់ដល់លក្ខណៈសមស្របរបស់ភាគីមួយ ដើម្បីចូលរួមនៅក្នុងសកម្មភាព ដែលទទួលហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ឬចាត់ចែង ឬគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីឡើយ ។

៧៣. នៅក្នុងករណី ដែលពាក់ព័ន្ធនឹងភាគីច្រើនរួមបញ្ចូលជាក្រុមមួយ ដូចជា ការរួមហ៊ុនជាដើម គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI នឹងដាក់ទោសទណ្ឌលើភាគី ដែលប្រព្រឹត្តបំពានសុចរិតភាព ប្រសិនបើអាចកំណត់ពីការទទួលខុសត្រូវរបស់ភាគីនោះបាន ។

៧៤. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចថា គួរដាក់ទោសទណ្ឌលើភាគីដែលពាក់ព័ន្ធ ឬលើអ្នកទទួលខុសត្រូវចម្បង (ដូចជា ម្ចាស់ ប្រធាន មន្ត្រី ឬអ្នកមានភាគហ៊ុនសំខាន់ៗ) របស់ក្រុមហ៊ុនមួយ និង/ឬភាគីដែលពាក់ព័ន្ធដទៃទៀត ប្រសិនបើមានការបញ្ជាក់ច្បាស់លាស់ បើទោះបីជាភាគីដែលពាក់ព័ន្ធនេះ មិនបានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការប្រព្រឹត្តបំពាននេះក៏ដោយ ។ ភាគីពាក់ព័ន្ធ អាចរួមមានអ្នកដែលមាន

(ក) ទំនាក់ទំនងគ្រួសារ

(ខ) សមត្ថភាពគ្រប់គ្រង ឬមានឥទ្ធិពលលើភាគីម្ខាងទៀត ដោយផ្ទាល់ ឬដោយប្រយោល

(គ) មានកម្មសិទ្ធិ គ្រប់គ្រង ឬកាន់កាប់ជារួម ឬពាក់ព័ន្ធ ដែលមិនចាំបាច់ពាក់ព័ន្ធជាមួយនឹងកម្មសិទ្ធិ ឬសិទ្ធិ ក្នុងភាគរយណាមួយ

(ឃ) កិច្ចព្រមព្រៀងជាមួយភាគីមួយទៀត ឬការពឹងអាស្រ័យលើភាគីមួយទៀត ដូចជា ការរួមហ៊ុន ជាដើម

៧៥. នៅក្នុងការកំណត់ពីទោសទណ្ឌលើភាគីដែលពាក់ព័ន្ធ ឬអ្នកទទួលខុសត្រូវចម្បង គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ត្រូវពិចារណាលើកត្តាខាងក្រោម ក្នុងចំណោមកត្តាផ្សេងទៀត :

(ក) ការគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់អង្គភាព

(ខ) ថាតើភាគីដែលពាក់ព័ន្ធបានចូលរួម ឬមានឥទ្ធិពលធ្វើឱ្យមានការប្រព្រឹត្តបំពានសុចរិតភាពដែរឬទេ ឬថាតើភាគីពាក់ព័ន្ធ គឺជាអ្នកទទួលផលគោលដៅនៃការប្រព្រឹត្តបំពាននេះដែរឬទេ ។

(គ) លទ្ធភាពដែលភាគីស្ថិតនៅក្រោមការស៊ើបអង្កេត អាចចៀសវាងការដាក់ទោសទណ្ឌតាមរយៈភាគីពាក់ព័ន្ធ ដោយធ្វើការពិចារណាអំពីឥទ្ធិពល ដែលភាគីស្ថិតនៅក្រោមការស៊ើបអង្កេតមានមកលើភាគីពាក់ព័ន្ធ និងថាតើភាគីស្ថិតនៅក្រោមការស៊ើបអង្កេតនេះអាចទទួលបានប្រយោជន៍អ្វី តាមរយៈភាគីពាក់ព័ន្ធ ដែរឬទេ ។

៧៦. នៅពេលដែលសមស្រប គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចធ្វើការសម្រេចចិត្តមិនដាក់ទោសទណ្ឌលើភាគី (ក្រៅពីបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី) ដែលសហការនៅក្នុងការស៊ើបអង្កេតរបស់ OAI ។

## រយៈពេលនៃការហាមឃាត់

៧៧. ទោសទណ្ឌគោលសម្រាប់ការប្រព្រឹត្តបំពានសុចរិតភាព គឺការហាមឃាត់រយៈពេល ៣ ឆ្នាំ។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចកំណត់ពីរយៈពេលហាមឃាត់ច្រើនជាង ឬតិចជាងនេះ អាស្រ័យទៅតាមកាលៈទេសៈរបស់ករណីនីមួយៗ។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ត្រូវពិចារណាលើកត្តាខាងក្រោមក្នុងចំណោមកត្តាដទៃទៀត នៅពេលសម្រេចថាត្រូវដាក់ទោសទណ្ឌតិច ឬច្រើនៈ

(ក) គ្រោះថ្នាក់ពិតប្រាកដ ឬគ្រោះថ្នាក់ដែលអាចកើតមានឡើង មិនថាចំពោះសុវត្ថិភាព/សុខុមាលភាពសាធារណៈ, គម្រោង ឬ បញ្ហាដែលកំពុងស្ថិតនៅក្នុងការស៊ើបអង្កេត ឬផលប្រយោជន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

(ខ) ភាពស្មុគស្មាញនៃការប្រព្រឹត្តបំពានសុចរិតភាព ដូចជា កម្រិតនៃការរៀបចំផែនការ, បច្ចេកទេសដែលបានប្រើប្រាស់, កម្រិត នៃការលាក់បាំង, ចំនួន និងប្រភេទនៃបុគ្គល/អង្គការចាត់តាំងដែលពាក់ព័ន្ធ, រយៈពេលនៃការប្រព្រឹត្តបំពានសុចរិតភាព, របាយទីតាំងភូមិសាស្ត្រនៃការប្រព្រឹត្តបំពានសុចរិតភាព ។

(គ) កម្រិតនៃការពាក់ព័ន្ធ ឬកម្រិតនៃការត្រួតពិនិត្យរបស់អ្នកគ្រប់គ្រង ឬរបស់អង្គការចាត់តាំងតែមួយ ។

(ឃ) សារៈសំខាន់នៃតួនាទី ក្នុងការប្រព្រឹត្តបំពានសុចរិតភាព ឧទាហរណ៍ ជាតួនាទីដឹកនាំ តួនាទីសំខាន់ ឬតួនាទីតូចតាច ។

(ង) ថាតើភាគីនេះបន្តប្រព្រឹត្តបំពានសុចរិតភាពដែរឬទេ បន្ទាប់ពីដឹងពីការស៊ើបអង្កេតរបស់ OAI ឬថាតើភាគីបានបញ្ឈប់ការប្រព្រឹត្តបំពាននេះដោយស្ម័គ្រចិត្ត ។

(ច) កម្រិតនៃការសហការ ដែលបានបង្ហាញក្នុងកំឡុងពេលស៊ើបអង្កេត ឬការរារាំងដល់ការស៊ើបអង្កេត ។

(ឆ) ថាតើភាគីធ្លាប់ត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ីដាក់ទោសទណ្ឌដែរឬទេកន្លងមក ឬធ្លាប់ត្រូវបានស្ថាប័ន ឬអង្គភាពមួយទៀតដាក់ទោសទណ្ឌ ឬហាមឃាត់ដែរឬទេ ។

(ជ) សាវតាររបស់ភាគី ឬរបស់នាយក មន្ត្រី ឬអ្នកទទួលខុសត្រូវចម្បងដទៃទៀតរបស់ក្រុមហ៊ុន ។

(ឈ) ការពាក់ព័ន្ធ និងតួនាទីរបស់មន្ត្រីសាធារណៈ ឬរបស់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការប្រព្រឹត្តបំពានសុចរិតភាពនេះ ។

(ញ) ការសងវិញ និងជំហាននានា ដែលត្រូវបានអនុវត្តដើម្បីដោះស្រាយក្តីកង្វល់ទាំងនេះ ។

(ដ) វត្តមាន ការបង្កើត ការកែលំអ ឬការអនុវត្តវិធានការអភិបាលកិច្ចផ្ទៃក្នុង ដើម្បីពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងដើម្បីបង្ការមិនឱ្យការប្រព្រឹត្តបំពានសុចរិតភាពនេះកើតឡើងម្តងទៀត ។

(ឋ) ថាតើមានធនាគារអភិវឌ្ឍន៍ពហុភាគី ឬអង្គការអន្តរជាតិផ្សេងទៀត បានហាមឃាត់ភាគីនេះដែរឬទេ ។

៧៨. ដោយទទួលស្គាល់ថាកម្មសិទ្ធិ រចនាសម្ព័ន្ធស្ថាប័ន និង/ឬគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនអាចមានការផ្លាស់ប្តូរនៅក្នុងរយៈពេលមួយ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងហាមឃាត់ក្រុមជារៀងរហូត តែនៅក្នុងករណីពិសេសតែប៉ុណ្ណោះ (ដូចជា ការប្រព្រឹត្តបំពានសុចរិតភាពម្តងហើយម្តងទៀត, ការធ្វើប៉ះពាល់ជាពិសេសដល់ប្រយោជន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម) ។ ដោយសារតែបុគ្គលិកលក្ខណៈរបស់បុគ្គលទំនងជានឹងងាយផ្លាស់ប្តូរ ធនាគារអភិវឌ្ឍន៍អាស៊ីអាចហាមឃាត់បុគ្គល ដែលប្រព្រឹត្តបំពានសុចរិតភាពជារៀងរហូត ។

៧៩. នៅក្នុងការកំណត់ថាតើត្រូវដាក់ការហាមឃាត់ក្នុងរយៈពេលច្រើន ឬតិច គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ត្រូវ ពិចារណាលើការកំណត់ដូចខាងក្រោម ៖

(ក) ការហាមឃាត់លើកដំបូង ដូចជា នៅក្នុងករណីដែលភាគីមួយ ធ្លាប់ទទួលបានការស្តីបន្ទោសពីមុនមក ៖
   i) បុគ្គលៈ ១ ឆ្នាំ ដល់មិនកំណត់
   ii) ក្រុមហ៊ុនៈ ១ ដល់ ៧ ឆ្នាំ

(ខ) ការហាមឃាត់លើកទីពីរ ៖
   i) បុគ្គលៈ រហូតដល់មិនកំណត់
   ii) ក្រុមហ៊ុនៈ រហូតដល់ ១០ ឆ្នាំ

(គ) ការហាមឃាត់ក្រោយៗទៀត ៖
   i) បុគ្គលៈ រហូតដល់មិនកំណត់
   ii) ក្រុមហ៊ុនៈ រហូតដល់ ២០ ឆ្នាំ

៨០. ប្រធាន OAI ត្រូវផ្សព្វផ្សាយពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI រួមទាំងអំពីវិធានការកែតម្រូវផងទៅកាន់សាមីជនពាក់ព័ន្ធនឹងការសម្រេចចិត្តនេះ ហើយនៅក្នុងករណីដែលពាក់ព័ន្ធ ដល់គណៈគ្រប់គ្រង ឬនាយកដ្ឋានប្រតិបត្តិការ ។ នៅក្នុង គ្រប់ករណីទាំងអស់ ដែលគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព បានសម្រេចចិត្តចាត់នូវវិធានការកែតម្រូវអ្វីមួយ OAI ត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីសិទ្ធិតវ៉ាស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលបានដាក់ចេញនៅក្នុងគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពទាំងនេះ ។ នៅក្នុងករណីដែល OAI មិនអាចជូនដំណឹងដល់ភាគីមួយអំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពបាន OAI ត្រូវផ្សព្វផ្សាយជា សាធារណៈនូវការសម្រេចចិត្តនេះលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីទៅតាមនីតិវិធី ដែលបង្ហាញខាងក្រោម ។

៨១.  ដោយសហការជាមួយនឹងគណៈគ្រប់គ្រងនិងនាយកដ្ឋាន/ការិយាល័យដែលពាក់ព័ន្ធOAI ត្រូវធានាឱ្យមានការត្រួតពិនិត្យ ដើម្បីពង្រឹងការអនុវត្តវិធានការកែតម្រូវនេះ ។

## ការប្តឹងឧទ្ធរណ៍

៨២.  អ្នកចូលរួមដេញថ្លៃ ទីប្រឹក្សា អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ ឬភាគីទី ៣ ផ្សេងទៀត ដែលត្រូវទទួលការដាក់ទោសទណ្ឌពីធនាគារអភិវឌ្ឍន៍អាស៊ី អាចប្តឹងឧទ្ធរណ៍ទៅកាន់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ អំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព មិនឱ្យលើសពី ៩០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងរបស់ OAI អំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ។ ភាគីដែល ទទួលរងទោសទណ្ឌទាំងឡាយណាដែល OAI មិនអាចជូនដំណឹងអំពីទោសទណ្ឌនេះបាន ដោយភាគីនោះមិនមែនជាអ្នកមានកំហុសធ្វើឱ្យពុំអាចជូនដំណឹងនេះបាន ប៉ុន្តែក្រោយមកភាគីនេះដឹងពីទោសទណ្ឌនេះ ភាគីនេះអាចប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលមួយសមស្រប ។ ការប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរហើយរៀបរាប់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ដែលខ្លួនស្នើសុំឱ្យមានការពិនិត្យឡើងវិញលើការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ហើយត្រូវពន្យល់ពីមូលហេតុ ដែល OAI មិនអាចទាក់ទងភាគីបាន ប្រសិនបើអាច ។

៨៣.  ការហាមឃាត់ដោយសារការប្រព្រឹត្តបំពាននឹងទោសទណ្ឌ មិនអាចប្តឹងឧទ្ធរណ៍បានឡើយ ហើយការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI គឺជាការសម្រេចចិត្តស្ថាពរ ។

៨៤.  គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ត្រូវពិចារណាលើបណ្តឹងឧទ្ធរណ៍ ដែលមានព័ត៌មានថ្មីៗ នៅក្នុងករណីដែល :

(ក) ព័ត៌មាននេះមិនមាន ឬមិនដឹង ឬមិនអាចដឹងដោយសារមូលហេតុសមស្រប ចំពោះភាគី នៅពេលដែល OAI ព្យាយាមសុំការ ពន្យល់ពីភាគីហើយ

(ខ) ព័ត៌មាននេះ មានភាពពាក់ព័ន្ធជាមួយករណី ហើយអាចមានភាពពាក់ព័ន្ធជាមួយនឹងការសម្រេចចិត្តអំពីការដាក់ទោសទណ្ឌ

៨៥.  គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ អាចកាត់បន្ថយ ឬដកចេញនូវទោសទណ្ឌ ដែលដាក់ដោយធនាគារអភិវឌ្ឍន៍អាស៊ី បន្ទាប់ពីបានពិនិត្យពិចារណាលើបណ្តឹងឧទ្ធរណ៍រួចមក ។ ជាជម្រើសវិធានការមួយទៀត គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ អាចតម្រូវឱ្យគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពធ្វើការពិចារណាឡើងវិញលើករណីណាមួយ ប្រសិនបើគណៈកម្មាធិការនេះសម្រេចថា គួរមានការវាយតម្លៃឡើងវិញលើភស្តុតាង ដែលបានផ្ញើរមក ។

៨៦.  គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ត្រូវមានការចូលរួមពីអនុប្រធានធនាគារចំនួន ២ ឬ ៣ រូប អាស្រ័យទៅតាមលក្ខណៈរបស់ករណី និងរយៈពេលនៃទោសទណ្ឌ[១៦] ។ ប្រធាន OAI គឺជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ ។ អនុប្រធាន ដែលមានអណត្តិការងារវែងជាងគេ គឺជាប្រធានគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌនេះ ។ ប្រធាន OAI ត្រូវតែងតាំងសមាជិករបស់គណៈកម្មាធិការនេះ ហើយត្រូវបំពេញតួនាទីជាទីប្រឹក្សាសម្រាប់គណៈកម្មាធិការនេះ ។ អគ្គមេធាវី អាចមានវត្តមានជាទីប្រឹក្សា ។ នៅក្នុងករណីដែលមិនមានភាពស្មុគស្មាញ ប្រធាន OAI អាចបញ្ជូនករណីបណ្តឹងឧទ្ធរណ៍នេះ ទៅកាន់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ផ្អែកទៅតាមមូលដ្ឋានគ្មានការជំទាស់ ។ នៅក្នុងករណីបែបនេះ គណៈកម្មាធិការនេះត្រូវមានការចូលរួមពីអនុប្រធានធនាគារចំនួន ២ រូប លុះត្រាតែមានសមាជិកម្នាក់ ក្នុងចំណោមសមាជិកពីរនាក់របស់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌនេះ ស្នើសុំឱ្យមានការចូលរួមពីអនុប្រធានធនាគារទី ៣ នៅក្នុងការសម្រេចចិត្តអំពីបណ្តឹងឧទ្ធរណ៍នេះ ។

៨៧.  គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌនឹងធ្វើការសម្រេចចិត្តរបស់ខ្លួន តែនៅពេលដែលមានការឯកភាពគ្នាជាឯកច្ឆ័ន្ទពីគ្រប់សមាជិកទាំងអស់ ។ ប្រសិនបើ ប្រធានគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌសម្រេចចិត្តថា គណៈកម្មាធិការនេះមិនអាចឈានដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទ ប្រធានគណៈកម្មាធិការត្រូវស្នើសុំឱ្យមានការចូលរួមពីប្រធានធនាគារ ។ ប្រធានធនាគារត្រូវជួយដោះស្រាយការខ្វែងគំនិតគ្នានេះ ហើយត្រូវទុកលទ្ធភាពឱ្យគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌធ្វើការសម្រេចចិត្តរួមគ្នា ឬប្រសិនបើនៅតែមិនអាចសម្រេចចិត្តរួមគ្នាបានទៀត ប្រធានធនាគារត្រូវធ្វើការសម្រេចចិត្តចុងក្រោយ ។

---

[១៦] ប្រសិនបើលក្ខណៈទោសទណ្ឌទាមទារឱ្យមានការចូលរួមពីអនុប្រធានធនាគារចំនួន ៣ នាក់ ហើយលេខាធិការដ្ឋានសម្រេចថា គេមិនអាចរៀបចំឱ្យមានកិច្ចប្រជុំពីអនុប្រធានធនាគារ ទាំង ៣ នាក់ ក្នុងរយៈពេលមួយសមស្របបាននោះទេ ប្រធានគណៈកម្មាធិការអាចតែងតាំងប្រធាន ឬអនុប្រធាននាយកដ្ឋាន ឬការិយាល័យណាមួយ ធ្វើជាសមាជិកទី ៣ របស់គណៈ-កម្មាធិការនេះ ។

៨៨. ការសម្រេចចិត្តរបស់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌអំពីបណ្ដឹងឧទ្ធរណ៍ណាមួយ និងការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព លើករណីដែលគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌបញ្ជូនត្រលប់មកវិញ ត្រូវតែជាការសម្រេចចិត្តស្ថាពរ ចងកាតព្វកិច្ច និង មិនអាចប្ដឹងឧទ្ធរណ៍បន្តទៀតឡើយ។

## ការទទួលស្គាល់ឡើងវិញ

៨៩. ភាគី ដែលត្រូវបានហាមឃាត់ អាចស្នើសុំការទទួលស្គាល់ឡើងវិញ បន្ទាប់ពីរយៈពេលហាមឃាត់បានផុតកំណត់។ OAI អាចព្យាយាមជូនដំណឹងដល់ភាគីអំពីឱកាសស្នើសុំការទទួលស្គាល់ឡើងវិញ ក្នុងរយៈពេលប្រហែលជា ៤៥ ថ្ងៃ មុនពេលបញ្ចប់រយៈពេលទោសទណ្ឌអប្បបរមា។

៩០. ការស្នើសុំការទទួលស្គាល់ឡើងវិញ ត្រូវ :

(ក) ធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ផ្ញើទៅកាន់នាយក OAI

(ខ) លើកឡើងពីមូលហេតុនៃការដាក់ទោសទណ្ឌ និង

(គ) ផ្ដល់នូវព័ត៌មានជាមូលដ្ឋាន សម្រាប់ឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការពិចារណាលើការទទួលស្គាល់ឡើងវិញ

៩១. OAI នឹងធ្វើការវាយតម្លៃលើភាពជឿជាក់នៃសំណើសុំការទទួលស្គាល់ឡើងវិញនេះ ហើយនឹងធ្វើការវាយតម្លៃមូលដ្ឋានដើម្បីទទួលស្គាល់ភាគីណាមួយឡើងវិញ។ កត្តា ដែល OAI អាចយកមកធ្វើការពិចារណា អាចរួមមាន :

(ក) ការអនុលោមទៅតាមលក្ខខណ្ឌ ដែលត្រូវបានដាក់អនុលោមទៅតាមកថាខណ្ឌ ៦៩ (ខ)

(ខ) មូលហេតុ នៃការដាក់ទោសទណ្ឌ

(គ) ការសងវិញ

(ឃ) ការផ្លាស់ប្ដូរអ្នកគ្រប់គ្រង ឬកម្មសិទ្ធិរបស់ក្រុមហ៊ុន និងថាតើអ្នកទទួលខុសត្រូវចម្បងរបស់ក្រុមហ៊ុនបាន និងនៅតែទទួលរងទោសទណ្ឌដែរឬទេ

(ង) យន្តការ ដែលអាចផ្ទៀងផ្ទាត់បាន ដើម្បីកែលំអអភិបាលកិច្ចរបស់ក្រុមហ៊ុន

(ច) វិធានការផ្នែករដ្ឋបាល រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលភាគីដែលត្រូវបានហាមឃាត់បានផ្ដួចផ្ដើមឡើង ដើម្បីកែតម្រូវលើការប្រព្រឹត្តបំពានសុចរិតភាពរបស់ខ្លួន

(ឆ) ព័ត៌មានផ្សេងទៀត ដែលបង្ហាញថា ភាគីនេះនៅតែពាក់ព័ន្ធនឹងការប្រព្រឹត្តបំពានសុចរិតភាព បន្ទាប់ពីទទួលទោសទណ្ឌពីធនាគារអភិវឌ្ឍន៍អាស៊ី រួមទាំងទោសទណ្ឌ ដែលដាក់ដោយស្ថាប័នផ្សេងទៀត

(ជ) លទ្ធផលនៃការស៊ើបអង្កេតរដ្ឋបាល ឬព្រហ្មទណ្ឌ

៩២. បន្ទាប់ពីបានបញ្ចប់ការពិនិត្យឡើងវិញ ឬការស៊ើបអង្កេតរបស់ខ្លួនរួច OAI ត្រូវកំណត់ថាតើត្រូវទទួលស្គាល់ភាគីមួយបានដែរឬទេ។ ប្រសិនបើ OAI សម្រេចថា មិនគួរភាគីមួយឡើងវិញទេនោះ OAI ត្រូវរៀបចំរបាយការណ៍មួយ សម្រាប់ដាក់ជូនគណៈកម្មាធិការត្រួតពិនិត្យ សុចរិតភាព ជាមួយនឹងអនុសាសន៍បែបនេះ។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព អាចធ្វើការសម្រេចចិត្តទទួលស្គាល់ឡើងវិញនូវភាពសមស្របរបស់ភាគីនោះ ឬបន្តការដាក់ទោសទណ្ឌសម្រាប់រយៈពេលអប្បបរមាមួយទៀត ដែលបន្ទាប់ពីរយៈពេលនេះ ភាគីនេះអាចស្នើសុំការទទួលស្គាល់ឡើងវិញម្ដងទៀត។

៩៣. នៅក្នុងករណីដែលធនាគារអភិវឌ្ឍន៍អាស៊ីហាមឃាត់ភាគីដែលពាក់ព័ន្ធ អ្នកទទួលខុសត្រូវចម្បងរបស់ក្រុមហ៊ុន ឬភាគីដែលពាក់ព័ន្ធផ្សេងទៀត ស្របជាមួយនឹងការដាក់ទោសទណ្ឌលើក្រុមហ៊ុន ដែលបានប្រព្រឹត្តល្មើសនឹងគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ការពិនិត្យឡើងវិញ និងអនុសាសន៍របស់ OAI និងការសម្រេចចិត្តលើសំណើសុំការទទួលស្គាល់ឡើងវិញ ក៏អាចលើកឡើងពីការផ្ដល់ការទទួលស្គាល់ឡើងវិញដល់ភាគីទាំងនោះផងដែរ។

៩៤. OAI នឹងផ្សព្វផ្សាយការសម្រេចចិត្តរបស់ខ្លួនលើសំណើសុំការទទួលស្គាល់ឡើងវិញ ជាលាយល័ក្ខណ៍អក្សរ ដោយមានរៀបរាប់ពីមូលដ្ឋាននៃការសម្រេចចិត្តបន្តទោសទណ្ឌ សម្រាប់រយៈពេលអប្បបរមាមួយទៀត។ ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពសម្រេចបន្តទោសទណ្ឌ ក្នុងរយៈពេលអប្បបរមាមួយទៀត ភាគីអាចប្ដឹងឧទ្ធរណ៍អំពីការសម្រេចចិត្តនេះទៅកាន់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ អនុលោមទៅតាមនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍។

៩៥. ភាគីទទួលទោសទណ្ឌទាំងឡាយណា ដែល OAI មិនអាចជូនដំណឹងពីលទ្ធផលរកឃើញ និងទោសទណ្ឌបាន ដោយភាគីមិនមែនជាអ្នកមានកំហុសធ្វើឱ្យមិនអាចជូនដំណឹងបែបនេះបាន ប៉ុន្តែក្រោយមកបានដឹងពីទោសទណ្ឌ អាចស្នើសុំឱ្យមានការទទួលស្គាល់ឡើងវិញនៅពេលណាក៏បាន ដោយត្រូវដាក់បញ្ចូលព័ត៌មាន និងការពន្យល់នានាពីមូលហេតុ ដែលគេមិនអាចទាក់ទងខ្លួនបានដើម្បីគាំទ្រដល់ការស្នើសុំនេះ ។ នៅក្នុងករណីបែបនេះ សំណើសុំទទួលស្គាល់ឡើងវិញ ត្រូវពិចារណាដោយគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ។ ការសម្រេចចិត្តនេះ គឺជាការសម្រេចចិត្តស្ថាពរ ចងកាតព្វកិច្ច និងមិនអាចប្ដឹងឧទ្ធរណ៍បន្តទៀតបានឡើយ ។

៩៦. ជាឯកតោភាគី OAI អាចផ្ដួចផ្ដើមឱ្យមានការវាយតម្លៃលើលក្ខណៈសម្បត្តិ សម្រាប់ទទួលស្គាល់ភាគីមួយឡើងវិញ ឬដកភាគីចេញពីភាគីហាមឃាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ OAI អាចធ្វើបែបនេះ ដើម្បីបង្ការកុំឱ្យមានការដាក់ទោសទណ្ឌមិនត្រឹមត្រូវ ឬដើម្បីបង្ការកុំឱ្យបញ្ជីភាគីហាមឃាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ីលែងអាចប្រើប្រាស់បានទៀត ។

## ការបង្ហាញព័ត៌មានជាសាធារណៈ

៩៧. អនុលោមទៅតាមគោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បញ្ជីឈ្មោះភាគីដែលហាមឃាត់ដោយធនាគារអភិវ-ឌ្ឍន៍អាស៊ី មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ ។ ប៉ុន្តែ បញ្ជីនេះមិនមែនជាបញ្ជីលាក់ការសម្ងាត់ឡើយ ដោយសារតែOAI អាចផ្ដល់បញ្ជីឈ្មោះភាគីហាមឃាត់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ដល់ភាគីផ្សេងទៀតដែលចាំបាច់ត្រូវដឹង ដូចជា ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្ថាប័នអភិវឌ្ឍន៍ពហុភាគីដទៃទៀត និង ទីភ្នាក់ងារផ្ដល់ជំនួយទ្វេភាគី ជាដើម ។

៩៨. OAI នឹងជូនដំណឹងដល់ភាគី ដែលត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ីប្រកាសថាពុំមានលក្ខណៈសមស្របថា ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមិនផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះរបស់ពួកគេឡើយ ប៉ុន្តែការប៉ុនប៉ងរបស់ភាគីទាំងនោះដើម្បីចូលរួមនៅក្នុងសកម្មភាព ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ឬដែលត្រូវបានចាត់ចែង ឬគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ខណៈពេលដែលភាគីនោះកំពុងមានភាពមិនស្រប នឹងធ្វើឱ្យមានការបន្ថែមរយៈពេលទោសទណ្ឌ និងការផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះរបស់ភាគីនោះ លើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយភាគីនេះអាចទទួលបានការហាមឃាត់ពីស្ថាប័នដទៃទៀត ស្របទៅតាមកិច្ចព្រមព្រៀង ស្ដីពីការអនុវត្តការសម្រេចចិត្តស្ដីពីការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ។ OAI ក៏នឹងផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះភាគី ដែលត្រូវបានហាមឃាត់ ទៅតាមកថាខ័ណ្ឌទី ៧៩ (ខ) និង (គ) ផងដែរ ។ ការផ្សព្វផ្សាយនេះមិនត្រូវធ្វើមុនពេលផុតកំណត់រយៈពេលប្ដឹងឧទ្ធរណ៍ ឬការបដិសេធនៃបណ្ដឹងប្រសិនបើមានឡើយ ។

៩៩. ប្រសិនបើការព្យាយាមសមស្របគ្រប់បែបយ៉ាង ដើម្បីផ្ដល់ព័ត៌មានអំពីការសម្រេចចិត្តហាមឃាត់ដល់ភាគីមិនទទួលបានជោគជ័យ (ឧ. ប្រសិនបើភាគីបដិសេធមិនព្រមទទួលយកការជូនដំណឹង ឬបានផ្លាស់ប្ដូរទីតាំង ហើយរកមិនឃើញ) គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចឯកភាពលើការផ្សព្វផ្សាយពីព័ត៌មាននេះ រួមទាំងឈ្មោះរបស់ភាគីលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលអាចធ្វើឱ្យមានការហាមឃាត់ពីស្ថាប័នផ្សេងទៀត ស្របទៅតាមកិច្ចព្រមព្រៀងស្ដីពីការអនុវត្តការសម្រេចចិត្តស្ដីពីការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ។

១០០. នៅក្នុងករណីលើកលែង ដូចជា ករណីដែលមានការប្រព្រឹត្តបំពានសុចរិតភាពធ្ងន់ធ្ងរ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពអាច សម្រេចផ្សព្វផ្សាយសាធារណៈអំពីទោសទណ្ឌនេះ បើទោះបីនេះគឺជាកាប្រព្រឹត្តល្មើសលើកដំបូងក៏ដោយ ។

## ការហាមឃាត់ឱ្យគ្នាទៅវិញទៅមក

១០១. នៅក្រោមកិច្ចព្រមព្រៀងស្ដីពីការអនុវត្តការសម្រេចចិត្តស្ដីពីការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ការសម្រេចចិត្តហាមឃាត់ ដោយស្ថាប័នមួយដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ មានភាពសមស្របគ្រប់គ្រាន់សម្រាប់ឱ្យស្ថាប័នដទៃទៀត ដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះដែរប្រសិនបើ :

(ក) ការសម្រេចចិត្តនេះមានមូលដ្ឋានទាំងស្រុង ឬដោយអន្លើ លើលទ្ធផលរកឃើញអំពីការអនុវត្តដែលត្រូវទទួលរងទោសទណ្ឌ ដូចដែលបានកំណត់នៅក្រោមក្របខ័ណ្ឌរួមសម្រាប់ទប់ស្កាត់ និងបង្ក្រាបការគៃបន្លំ និងអំពើពុករលួយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៦ ។ ការអនុវត្តទាំងនេះរួមមាន ការប្រព្រឹត្តអំពើពុករលួយ ការគៃបន្លំ ការបង្ខិតបង្ខំ និងការឃុបឃិតគ្នា ជាដើម ។

(ខ) ការសម្រេចចិត្តនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយស្ថាប័នដែលដាក់ទោសទណ្ឌ ។

(គ) រយៈពេលបឋមនៃការហាមឃាត់ មានលើសពី ១ ឆ្នាំ។

(ឃ) ការសម្រេចចិត្តនេះត្រូវបានធ្វើឡើង បន្ទាប់ពីកិច្ចព្រមព្រៀងជាមួយនឹងស្ថាប័នដាក់ទោសទណ្ឌបានចូលជាធរមាន។

(ង) ការសម្រេចចិត្តដោយស្ថាប័នដាក់ទោសទណ្ឌ ត្រូវបានធ្វើឡើងក្នុងរង្វង់រយៈពេល ១០ ឆ្នាំ ចាប់គិតពីពេលមានការទទួលស្គាល់លើការអនុវត្ត ដែលត្រូវទទួលទោសទណ្ឌ និង

(ច) ការសម្រេចចិត្តដោយស្ថាប័នដាក់ទោសទណ្ឌ មិនត្រូវបានធ្វើឡើងដោយទទួលស្គាល់ពីការសម្រេចចិត្ត ដែលធ្វើឡើងនៅក្នុងវេទិកាជាតិ ឬអន្តរជាតិដទៃទៀត។

១០២. ប្រធាន OAI ត្រូវជូនដំណឹងដល់ស្ថាប័នចូលរួមដទៃទៀតអំពីទោសទណ្ឌនីមួយៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានលក្ខណៈសមស្របទៅតាមកិច្ចព្រមព្រៀងនេះ និងការផ្លាស់ប្តូរនានាដែលមាន។ ការជូនដំណឹងនេះត្រូវដាក់បញ្ចូល (ក) ឈ្មោះ និងព័ត៌មានសម្រាប់ទាក់ទងភាគី ដែលត្រូវបានដាក់ទោសទណ្ឌ (ខ) ការអនុវត្តដែលអាចដាក់ទោសទណ្ឌបាន ដែលបានរកឃើញថាភាគីបានប្រព្រឹត្ត និង (គ) រយៈពេលនៃការហាមឃាត់ ឬការផ្លាស់ប្តូរនានា។ ស្របជាមួយនឹងកិច្ចព្រមព្រៀងខាងលើ និងជាមួយនឹងនីតិវិធីអំពីការផ្សព្វផ្សាយអំពីការដាក់ទោសទណ្ឌ ការជូនដំណឹងនឹងកម្រិតត្រឹមតែទោសទណ្ឌទាំងឡាយណា ដែលត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីតែប៉ុណ្ណោះ ហើយការជូនដំណឹងនេះនឹងត្រូវផ្ញើរ តែក្រោយពេលមានការផ្សព្វផ្សាយលើគេហទំព័រនេះតែប៉ុណ្ណោះ។ ការសម្រេចចិត្តនៅពេលក្រោយ ដើម្បីដកទោសទណ្ឌណាមួយចេញពីគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជាប្រសិនបើភាគីដែលមិនអាចទាក់ទងពីដំបូង ប៉ុន្តែត្រូវបានរកឃើញនៅពេលក្រោយ អាចចាត់ទុកថាជាការផ្លាស់ប្តូរដែលនឹងតម្រូវឱ្យមានការដកទោសទណ្ឌនេះចេញពីវិសាលភាពនៃកិច្ចព្រមព្រៀងនេះ បើទោះបីជាទោសទណ្ឌនេះនៅដដែល ប៉ុន្តែមិនត្រូវបានផ្សព្វផ្សាយក៏ដោយ។

១០៣. នៅពេលដែលទោសទណ្ឌដែលមានលក្ខណៈសមស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តការសម្រេចចិត្ត ស្តីពីការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ត្រូវបានដាក់ដោយស្ថាប័នចូលរួមដទៃទៀត ប្រធាន និងនាយក OAI ត្រូវពិនិត្យលើបញ្ជីទោសទណ្ឌ ដើម្បីកំណត់ថាតើធនាគារអភិវឌ្ឍន៍អាស៊ីគួរដាក់ទោសទណ្ឌដូចគ្នានេះដែរឬទេ។ ការត្រួតពិនិត្យបែបនេះ ត្រូវធ្វើការពិចារណាលើវិធានកំណត់ពីលក្ខណៈសមស្របរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលើសញ្ជាតិ ដោយមិនរាប់បញ្ចូលអ្នកដែលមិនមានលក្ខណៈសមស្រប ដោយសារតែមូលហេតុសញ្ជាតិ និងថាតើការហាមឃាត់បែបនេះអាចមិនមានសង្គតភាពជាមួយនឹងកត្តាច្បាប់ ឬកត្តាស្ថាប័នដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែរឬទេ។ ប្រសិនបើមានការសម្រេចចិត្តហាមឃាត់ ដោយប្រើបញ្ជីឈ្មោះភាគីរបស់ស្ថាប័នផ្សេង ការហាមឃាត់បែបនេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយនេះតទៅ។ ប្រធាន OAI ត្រូវផ្តល់អនុសាសន៍អំពីការសម្រេចចិត្តមិនហាមឃាត់ក្រុមហ៊ុន ឬបុគ្គល ដែលមានលក្ខណៈសមស្រប ដើម្បីចូលរួមនៅក្នុងសកម្មភាពទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដល់ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី។

១០៤. នៅពេលដែលការដាក់ទោសទណ្ឌលើភាគី ដែលត្រូវបានហាមឃាត់នេះ ត្រូវបានដកដោយស្ថាប័នចូលរួមដែលដាក់ទោសទណ្ឌ នោះការដាក់ទោសទណ្ឌដោយធនាគារអភិវឌ្ឍន៍អាស៊ី ក៏នឹងត្រូវដកចេញដូចគ្នាដែរ។

# គោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៨

# ឈ្មោះអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BPMAD | នាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង |
| COSO | ការិយាល័យសេវាកម្មប្រតិបត្តិការកណ្តាល |
| DMCs | ប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក |
| GDP | ផលិតផលក្នុងស្រុកសរុប |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| MDB | ធនាគារអភិវឌ្ឍន៍ពហុភាគី |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| OAS | អង្គការនៃបណ្តារដ្ឋអាមេរិកកាំង |
| OECD | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| OGA | ការិយាល័យអគ្គសវនករ |
| OGC | ការិយាល័យអគ្គក្រុមប្រឹក្សា |
| SPD | នាយកដ្ឋានយុទ្ធសាស្ត្រ និងគោលនយោបាយ |
| TA | ជំនួយបច្ចេកទេស |

### កំណត់ចំណាំ

នៅក្នុងរបាយការណ៍នេះ “$” សំដៅលើប្រាក់ដុល្លារអាមេរិក

ឯកសារនេះគឺសម្រាប់បោះពុម្ពផ្សព្វផ្សាយ

# I. សេចក្តីផ្តើម

១. បញ្ហាអំពើពុករលួយ ដែលនៅទីនេះសំដៅលើការប្រើប្រាស់ដោយពុំត្រឹមត្រូវនូវតួនាទីសាធារណៈ ឬឯកជន សម្រាប់ផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួន បានក្លាយទៅជាទ្វេគ្រោះយ៉ាងរ៉ាំរ៉ៃដែលរដ្ឋាភិបាលនានាប្រឈមមុខនៅក្នុងប្រវត្តិសាស្ត្រ ។ ទោះបីជាប្រភេទ និងវិសាលភាពនៃអំពើពុករលួយ មានចរិតប្លែកៗគ្នាក៏ដោយ និងទោះបីមានវិធានការមួយចំនួនប្រឆាំងនឹងអំពើពុករលួយក្តី ក៏បាតុភូតនេះនៅតែកើតមានគ្រប់ពេល និង នៅក្នុងគ្រប់ប្រព័ន្ធគ្រប់គ្រងនយោបាយទាំងអស់ ។ អំពើពុករលួយក៏កើតមានផងដែរនៅក្នុងស្ថាប័នឯកជន ។ ជាក់ស្តែងអំពើពុករលួយដែលកើតមាននៅក្នុងទំនាក់ទំនងរវាងស្ថាប័នសាធារណៈ និងស្ថាប័នឯកជន គឺជាការព្រួយបារម្ភណ៍ជាពិសេស ទាំងនៅក្នុងបណ្តាប្រទេសជឿនលឿន និង ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅតំបន់អាស៊ី និងមហាសាគរប៉ាស៊ីភិច ។

២. នៅក្នុងប្រវត្តិសាស្ត្រ ការព្រួយបារម្ភណ៍អំពីអំពើពុករលួយតែងកើតឡើងគ្មានទីបញ្ចប់នៅក្នុងវដ្ត ដែលនៅក្នុងនោះការលេចឡើងនូវអំពើរំលោភជាផ្លូវការ ជាដើមហេតុនាំឱ្យមានយុទ្ធនាការប្រឆាំងអំពើពុករលួយ និងការចាត់វិធានការរដ្ឋបាលតបត ហើយបន្ទាប់មកវិធានការទាំងនេះក៏ត្រូវសាបរលាបមួយរយៈរហូតដល់ដំណាក់កាលមួយដែលកើតមានបញ្ហាអាស្រូវមួយជាថ្មីដែលបង្កើតជាកំលាំងជំរុញនាំឱ្យមានការទាមទារឱ្យធ្វើកំណែទម្រង់ ។ គោលបំណងនៃការកាត់បន្ថយ ឬលុបបំបាត់អំពើពុករលួយគឺជាគោលដៅស្នូលនៃកិច្ចប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការរៀបចំឱ្យមានអភិបាលកិច្ចល្អ ។ ការកែទម្រង់ជាចម្បងខាងផ្នែករដ្ឋបាលសាធារណៈនៅចុងសតវត្សទី 19 និងដើមសតវត្សទី 20, ដូចជាការដាក់បញ្ចូលប្រព័ន្ធលើកសរសើរដល់បុគ្គល ឬស្ថាប័នមានស្នាដៃនៅក្នុងស្ថាប័នស៊ីវិល និងការគ្រប់គ្រងផ្នែកលើវិជ្ជាជីវៈនៅក្នុងបណ្តាក្រសួង និងនាយកដ្ឋាន ឬការបង្កើតប្រព័ន្ធថវិកា លទ្ធកម្ម ព្រមទាំងការបង្កើតស្ថាប័ននិងនីតិវិធីសវនកម្ម ដែលមានលក្ខណៈផ្លូវការ, សុទ្ធសឹងផ្តើមចេញពីគោលបំណងជៀងវាងពីដើមទីនូវអំពើរំលោភគៃបន្លំ និងការចេញបញ្ជាពីអ្នកដឹកនាំថ្នាក់នយោបាយ ។

៣. នៅពេលថ្មីៗនេះ កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ បានក្លាយទៅជាចំនុចសំខាន់ជាគន្លឹះនៅក្នុងការពិភាក្សាវែកញែកលើប្រធានបទស្តីពីអភិ-បាលកិច្ចល្អ និងការលូតលាស់ខាងផ្នែកសេដ្ឋកិច្ច ។ កំលាំងចលករដែលនាំឱ្យមានការជជែកវែកញែកអំពីបញ្ហានេះផ្តើមចេញពីប្រភពផ្សេងៗគ្នា ។ ចំពោះភាគីប្រទេសជាម្ចាស់ជំនួយ ការបញ្ចប់សង្គ្រាមត្រជាក់បានជំរុញឱ្យបណ្តាប្រទេសទាំងនេះយកចិត្តទុកដាក់កាន់តែខ្លាំងលើចំនុចខុសឆ្គង ក្នុងការចាត់ចែងហិរ-ញ្ញវត្ថុក្នុងក្របខ័ណ្ឌនៃផលប្រយោជន៍ទូលំទូលាយពាក់ព័ន្ធនឹងកត្តាភូមិសាស្ត្រ និងនយោបាយ ។ ការធុញទ្រាន់នៃបណ្តាប្រទេសផ្តល់ជំនួយបានដាក់ការកៀបសង្កត់កាន់តែខ្លាំងឡើងដល់ទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ ដើម្បីឱ្យទីភ្នាក់ងារផ្តល់ជំនួយទាំងនេះបង្ហាញថា ពួកគេអាចនាំមកនូវសមិទ្ធផលជាផលប្រយោជន៍ក្នុងកម្រិតអតិបរមា ពីការប្រើប្រាស់ប្រាក់ដែលមាន ។ បណ្តាសាជីវកម្មពហុជាតិជាច្រើនមានជំនឿជឿជាក់ថា ពួកគេបាននាំមកនូវផលប្រយោជន៍ក្នុងកម្រិតខ្ពស់នៅក្នុងករណីដែលមានការប្រកួតប្រជែងជាចំហ និងប្រកបដោយតម្លាភាព ។ ផ្ទុយទៅវិញ ឥទ្ធិពលអវិជ្ជមាននៃការប្រកាន់របប "កិបកេងនិយម" តែងបង្កគ្រោះថ្នាក់ដួលរលំផ្នែកនយោបាយ និងសង្គម ប្រសិនបើអំពើពុករលួយដ៏រាលដាល ពុំត្រូវបានគេគ្រប់គ្រង ។

៤. ចំពោះភាគីទទួលជំនួយ នៅក្នុងបណ្តាប្រទេសនៅទូទាំងតំបន់អាស៊ី និងមហាសាគរប៉ាស៊ីភិច ប្រជាពលរដ្ឋបានកត់សម្គាល់ថា ពួកគេពុំមានបំនងនឹងអត់អោនដល់អំពើរំលោភយ៉ាងធ្ងន់ធ្ងរនៅក្នុងស្ថាប័នសាធារណៈសម្រាប់បំពេញផលប្រយោជន៍ឯកជនទៀតឡើយ ។ ការបើក ឱ្យមានសេរីភាពខាងសារពត៌មាននៅក្នុងបណ្តាប្រទេសជាច្រើនលើពិភពលោក បានផ្តល់លទ្ធភាពឱ្យអ្នកយកពត៌មានអាចសរសេរដោយសេរីអំពីការធ្វេសប្រហែសរបស់មន្ត្រីរាជការ ។ ការកែលម្អផ្នែកអប់រំ និងការបង្កើនទំនាក់ទំនងពត៌មានរវាងប្រទេសនានា បានជួយឱ្យសាធារណៈជនក្នុងប្រទេសទាំងនោះឱ្យកាន់តែយល់ដឹងអំពីកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយក្នុងបណ្តាប្រទេសនានា ដែលជាប្រការជំរុញឱ្យសាធារណៈជនពុំអាចទ្រាំទ្រនឹងអំពើរំលោភ ដែលកើតមានជាបន្តបន្ទាប់នៅក្នុងប្រទេសរបស់ខ្លួន ។ ការបង្កើតអង្គការក្រៅរដ្ឋាភិបាលជាច្រើននៅលើពិភពលោក ដែលផ្តោតលើការងារប្រឆាំងអំពើពុករលួយ បានជួយបើកកកាយបកអាក្រាតបញ្ហាអំពើពុករលួយទាំងនៅក្នុងប្រទេសជឿនលឿន និងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

៥. ការប្រែប្រួលជាច្រើនតាមទម្រង់បែបនេះ ទំនងជានឹងនៅតែបន្តយ៉ាងហោចណាស់នៅក្នុងអំឡុងពេលនៃទសវត្សខាងមុននេះ ឬអាចបន្តដល់ទសវត្សក្រោយទៀតផង ដែលនឹងធ្វើឱ្យមានការប្រែប្រួលជាមូលដ្ឋានក្នុងក្របខ័ណ្ឌនៃការងារប្រតិបត្តិរបស់បណ្តាធនាគារអភិវឌ្ឍន៍ពហុភាគី ។ ការកៀបសង្កត់ឱ្យចាត់វិធានការកាន់តែតឹងរ៉ឹងប្រឆាំងអំពើពុករលួយ និងការគៃបន្លំ នឹងលែងមានតាមរូបភាពដាច់ដោយឡែក និងពុំទៀងទាត់ដូចមុនទៀតឡើយ ។ ក៏ដូចជាបញ្ហាទាក់ទងនឹងប្រធានបទស្តីពីបរិស្ថាន និងស្ត្រីក្នុងការអភិវឌ្ឍន៍ដែរ បណ្តាស្ថាប័នដែលមានឥទ្ធិពល និងមានបណ្តាញទាក់ទងល្អទាំងនៅក្នុង និងក្រៅសហគមន៍នៃធនាគារអភិវឌ្ឍន៍ពហុភាគី នឹងធ្វើការកៀបសង្កត់យ៉ាងខ្លាំងក្លា ដើម្បីធានាថាបញ្ហានៃអំពើពុករលួយ និងអភិបាលកិច្ចល្អ នៅតែជាប្រធានបទដ៏ចម្បង និងជាចំណែកដ៏សំខាន់ នៅក្នុងកិច្ចពិភាក្សាវែកញែកពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ។

៦. ជាការឆ្លើយតបនឹងការកៀបសង្កត់បែបនេះ អង្គការអន្តរជាតិជាច្រើនបានប្រកាន់យកវិធានការតឹងរ៉ឹងប្រឆាំងនឹងអំពើពុករលួយ ៖

(i) នៅក្នុងកិច្ចប្រជុំកំពូលនៅទ្វីបអាមេរិច កាលពីខែឧសភា ឆ្នាំ ១៩៩៤ អង្គការបណ្តារដ្ឋក្នុងទ្វីបអាមេរិចសន្យាក្នុងការដាក់ឱ្យនៅក្រៅច្បាប់នូវការសូកប៉ាន់ឆ្លងកាត់ព្រំដែនប្រទេស និង "ការមានទ្រព្យសម្បត្តិដោយខុសច្បាប់" ក្នុងចំណោមមន្ត្រីនៅក្នុងបណ្តាប្រទេសក្នុងអឌ្ឍគោលនេះ ។ នៅខែមីនា ឆ្នាំ ១៩៩៦ រដ្ឋចំនួន ២១ នៃអង្គការបណ្តារដ្ឋក្នុងទ្វីបអាមេរិច បានចុះហត្ថលេខាលើអនុសញ្ញាទីក្រុងការ៉ាកាស ដែលអំពាវនាវឱ្យចាត់វិធានការរួមគ្នាតាមគោលការណ៍បួនដូចខាងក្រោម ៖ វិធានការការពារ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការសូកប៉ាន់ឆ្លងព្រំដែនប្រទេស ការមានទ្រព្យសម្បត្តិដោយខុសច្បាប់ និង បត្យាប័ន ។ បច្ចុប្បន្ន អនុសញ្ញាក្រុងការ៉ាកាសកំពុងអនុវត្តជាធរមានរវាងបណ្តាប្រទេសដែលបានផ្តល់សច្ចាប័ន ដែលរួម មានប្រទេសបូលីវី កូស្តារីកា អេក្វាឌ័រ ម៉ិចសិច ប៉ារ៉ាយហ្គាយ ប៉េរូ និង វេនេស៊ុយអេឡា ។

(ii) នៅខែ ឧសភា ឆ្នាំ ១៩៩៦ ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ បានអនុម័តសេចក្តីសម្រេចក្នុងការលើកទឹកចិត្តដល់បណ្តារដ្ឋជាសមាជិក ដើម្បីលុបចោលការកាត់បន្ថយពន្ធអាករលើសំណូកមកពីបរទេស និងប្រាក់កម្រៃ ជើងសារសម្រាប់បណ្តាក្រុមហ៊ុនសាជីវកម្មពហុភាគីរបស់អង្គការនេះ ។ រយៈពេលមួយឆ្នាំក្រោយមក ក្រុមប្រឹក្សានេះបានអនុម័តលើអនុសាសន៍ជាច្រើន ស្តីពីការកំណត់បទព្រហ្មទណ្ឌពាក់ព័ន្ធនឹងសំណូកឆ្លងព្រំដែនអនុម័តប្រព័ន្ធគណនេយ្យតឹងរ៉ឹងជាងមុន និងតម្រូវឱ្យមានការត្រួតពិនិត្យលើសវនកម្មផ្ទៃក្នុងដោយស្ថាប័នឯករាជ្យ លទ្ធកម្មសាធារណៈតឹងរ៉ឹងជាងមុន និងពង្រឹងការត្រួតពិនិត្យជាអន្តរជាតិ ។ នៅខែ ធ្នូ ឆ្នាំ ១៩៩៧ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ បានផ្តល់សច្ចាប័នលើអនុសញ្ញាដែលចាត់ទុកបញ្ហាស៊ីសំណូកជាមួយមន្ត្រីបរទេស គឺជាបទល្មើសឧក្រិដ្ឋ ដូចគ្នានឹងករណីនៃសំណូកដែលប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាលក្នុងប្រទេស ដែលក្រុមហ៊ុនសាជីវកម្មនោះមានមូលដ្ឋានតាំងនៅដែរ ។

(iii) ថ្មីៗនេះ សភាពាណិជ្ជកម្មអន្តរជាតិបានអនុម័តលើការកែសម្រួលបទបញ្ជាប្រតិបត្តិ ដែលហាមឃាត់ការទទួលសំណូក និងបានលើកអនុសាសន៍ថា បណ្តាសមាគមជាសមាជិករបស់ខ្លួននៅលើពិភពលោក និងក្រុមហ៊ុនសាជីវកម្មដែលជាសមាជិកត្រូវទទួលយក និងអនុវត្តបទបញ្ជាដែលមានលក្ខណៈតឹងតែងទាំងនេះ ។

(iv) នៅខែ ធ្នូ ឆ្នាំ ១៩៩៦ អគ្គក្រុមប្រឹក្សានៃអង្គការសហប្រជាជាតិបានអនុម័តសេចក្តីប្រកាសប្រឆាំងអំពើពុករលួយ និងការ សូកប៉ាន់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ។

៧. អ្នកនាំមុខគេក្នុងការលើកស្នើឱ្យមានគោលជំហរតឹងរឹងប្រឆាំងនឹងអំពើពុករលួយ គឺប្រធានធនាគារពិភពលោក ឈ្មោះលោក James Wolfensohn ។ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរវាងធនាគារពិភពលោកនិងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ នាខែតុលា ឆ្នាំ ១៩៩៦ លោក Wolfensohn បានប្រៀបធៀបអំពើពុករលួយទៅនឹង "ជំងឺមហារីក" នៅក្នុងសេដ្ឋកិច្ចពិភពលោក និងបានសង្កត់ធ្ងន់ថា ពេលនេះជាឱកាសមួយសមស្របដែលត្រូវចាត់វិធានការដោយគ្មានការលើកលែង នៅក្នុងកិច្ចប្រឹងប្រែងរបស់ធនាគារពិភពលោក ក្នុងការដោះស្រាយបញ្ហានេះ ។ នាយកគ្រប់គ្រងនៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិលោក Michael Camdessus ក៏បានថ្លែងជាចំហដោយបានកត់សម្គាល់ថា ចាប់ពីពេលនេះតទៅ មន្ត្រីក្នុងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវចាត់ទុកថាជាកាតព្វកិច្ចរបស់ខ្លួន នូវការជំរុញឱ្យមានការកែទម្រង់ប្រឆាំងនឹងអំពើពុករលួយនៅក្នុងបណ្តាប្រទេស ដែលស្នើសុំខ្ចីប្រាក់ពីអង្គការមូលនិធិនេះ ។ នៅក្នុងឱកាសនៃកិច្ចប្រជុំប្រចាំឆ្នាំ គេបានបង្កើតក្រុមការងារមួយចំណុះ អនុប្រធាន ធនាគារពិភពលោក ដែលទទួលបន្ទុកផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីឱ្យក្រុមការងារនេះរៀបចំយុទ្ធសាស្ត្រសមាហរណកម្មប្រឆាំងអំពើពុករលួយ ។ របាយការណ៍ចុងក្រោយដែលមានភ្ជាប់ជាមួយនូវគោលការណ៍ណែនាំសម្រាប់មន្ត្រីប្រតិបត្តិ ត្រូវបានទទួលការគាំទ្រពីក្រុមប្រឹក្សានាយកប្រតិបត្តិ នៃធនាគារពិភពលោក នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៧ ។

៨. របៀបដោះស្រាយរបស់ធនាគារពិភពលោកផ្អែកលើយុទ្ធសាស្ត្រប្រកបដោយតុល្យភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយឈរលើមូលដ្ឋានបួនជាសំខាន់ ៖ (i) រាំងស្កាត់អំពើកែបន្លំ និងអំពើពុករលួយនៅក្នុងបណ្តាគម្រោងដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារ ពិភពលោក (ii) ជួយបណ្តាប្រទេសដែលស្នើសុំជំនួយពីធនាគារពិភពលោកនៅក្នុងកិច្ចប្រឹងប្រែងរបស់ប្រទេសនោះ ដើម្បីកាត់បន្ថយអំពើពុករលួយ (iii) ចាត់ទុក អំពើពុករលួយជាបញ្ហាចម្បងមួយដែលត្រូវថែងឱ្យបានច្បាស់នៅក្នុងយុទ្ធសាស្ត្រផ្តល់ជំនួយសម្រាប់ប្រទេសណាមួយ នៅក្នុងកិច្ចពិភាក្សាជជែកវែកញែក

---

[១] សូមអានឯកសារ World Bank 1997. *Helping Country Combat Corruption: The Role of the World Bank,* Washington DC.

អំពីបញ្ហាគោលនយោបាយការវិភាគព្រមទាំងក្នុងការជ្រើសរើស និងរៀបចំគម្រោង និង (iv) បន្ថែមជាកំលាំង និងការគាំទ្រចំពោះកិច្ចប្រឹង ប្រែងអន្តរជាតិក្នុងការកាត់បន្ថយអំពើពុករលួយ[១] ។

៩. នៅខែសីហា អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានចាត់វិធានការដែលពុំធ្លាប់មានពីមុនមក ក្នុងការព្យួរទុកនូវការផ្តល់មូលនិធិជាលើកទីពីរសម្រាប់កម្មវិធីពង្រឹងកិច្ចការកែទម្រង់រចនាសម្ព័ន្ធ នៅពេលដែលមានប្រទេសមួយក្នុងចំណោមបណ្តាប្រទេសជាសមាជិកមិនបានបង្ហាញ នូវគោលជំហរក្នុងការអនុវត្តវិធានការឱ្យបានម៉ឺងម៉ាត់ ដើម្បីកាត់បន្ថយបញ្ហានៃអំពើពុករលួយ ។ ធនាគារពិភពលោកបានគាំទ្រយ៉ាងពេញទំហឹងចំពោះវិធានការរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងបានព្រមានថា កម្រិតនៃការផ្តល់ឥណទានរបស់ខ្លួនក៏នឹងត្រូវកាត់បន្ថយយ៉ាងច្រើនដែរក្នុងករណីដែលរដ្ឋាភិបាលពុំបានចាត់វិធានការម៉ឺងម៉ាត់ណាមួយនោះ[២] ។ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរួមគ្នានៅទីក្រុងហុងកុង នាប្រទេសចិន នាខែ កញ្ញា ឆ្នាំ ១៩៩៧ រវាងធនាគារពិភពលោក និងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ស្ថាប័នទាំងពីរបានបញ្ជាក់ជាថ្មីឡើងវិញយ៉ាងឧឡារិកនូវការសន្យាប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

១០. កិច្ចប្រជុំកំពូលរវាងក្រុមប្រទេសឧស្សាហកម្មជឿនលឿនទាំងប្រាំពីរនៅទីក្រុងដិនវើ នាសហរដ្ឋអាមេរិក នៅឆ្នាំ ១៩៩៧ បានកត់សម្គាល់ជាពិសេសចំពោះតួនាទីរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ សេចក្តីថ្លែងការណ៍នៅក្នុងកិច្ចប្រជុំដំបូង នៃបណ្តារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងធនាគារិកណ្តាលក្នុងខែមេសាបានកំណត់ថា "ដោយសារអំពើពុករលួយ និងការសូកប៉ាន់មានឥទ្ធិពលអវិជ្ជមាន ជាទូទៅចំពោះគោលដៅអភិវឌ្ឍន៍ ការលូតលាស់ និងស្ថិរភាពសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព តាងនាមឱ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការ សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ យើងសូមស្វាគមន៍ជានិច្ចចំពោះកំនើននៃការយកចិត្តទុកដាក់លើបញ្ហានេះ" ។ នៅខែ មិថុនា សេចក្តីថ្លែងការណ៍ចុងក្រោយនៃកិច្ចប្រជុំកំពូលបានអំពាវនាវឱ្យអង្គការមូលនិធិរូបិយ-វត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍ពហុភាគី ពង្រឹងសកម្មភាពរបស់ខ្លួន ដើម្បីជួយបណ្តាប្រទេសនានាប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមទាំងការជួយចាត់វិធានការឱ្យមានការអនុវត្តន៍តាមវិធាននៃច្បាប់ ជួយលើកកម្ពស់ប្រសិទ្ធភាព និងការទទួលខុសត្រូវនៅក្នុងវិស័យសាធារណៈ ព្រមទាំងជួយបង្កើនសមត្ថភាព និងប្រសិទ្ធភាពការងាររបស់ស្ថាប័ន ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ក៏បានទទួលការលើកទឹកចិត្តឱ្យជំរុញការងារអភិបាលកិច្ចល្អ នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចការងាររបស់ខ្លួន និងឱ្យរួមសហប្រតិបត្តិការយ៉ាងពេញលេញជាមួយកិច្ចប្រឹងប្រែងរបស់ធនាគារពិភពលោក ដើម្បីរៀបចំគោលការណ៍ណែនាំស្តីពីលទ្ធកម្មដែលធានាបាននូវតម្លាភាព និងភាពហ្មត់ចត់តាមបទដ្ឋានការងារខ្ពស់បំផុត ។

១១. ភាគច្រើននៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានរួមចំណែកដើរតួនាទីយ៉ាងសំខាន់ផងដែរនៅក្នុងចលនាប្រឆាំងអំពើពុករលួយ ។ នៅតំបន់អាស៊ីបូព៌ា បណ្តាប្រទេសមួយចំនួន ដែលធ្លាប់ទទួលបាននូវអត្រានៃកំនើនសេដ្ឋកិច្ចក្នុងកម្រិត ខ្ពស់កាលពីអតីតកាលបានសម្តែងការព្រួយបារម្ភណ៍ថាការរីករាលដាលនៃអំពើពុករលួយអាចបង្កជាឧបស័គ្គក្នុងការទាក់ទាញឱ្យមានការវិនិយោគ នៅក្នុងប្រទេសគេទៅអនាគត ។ នៅឆ្នាំ ១៩៩៥ សាធារណរដ្ឋប្រជាមានិតចិនបានអនុម័តច្បាប់ ដែលតម្រូវឱ្យមន្ត្រីជាន់ខ្ពស់ក្នុងបក្សកុម្មុយនិស្ត ប្រកាសអំពីប្រាក់ចំណូលរបស់ពួកគេ ។ នៅខែ មករា ឆ្នាំ ១៩៩៧ នាយករដ្ឋមន្ត្រីថៃបានសន្យាធ្វើការបោសសំអាតករណីមិនប្រក្រតី នៅក្នុង ទីចាត់ការគយដែលបានបង្កើត "ប្រព័ន្ធយកកម្រៃលាក់កំបាំង" ពីបណ្តាជនបរទេសដែលស្នើសុំចូលធ្វើវិនិយោគក្នុងប្រទេសថៃ ។ ក្នុងខែនោះដែរ ប្រធានាធិបតីប្រទេសហ្វីលីពីន បានបរិយាយបញ្ហាអាស្រូវនៃអំពើពុករលួយក្នុងស្ថាប័នសាធារណៈថាជាទុក្ខវេទនារ៉ាំរ៉ៃមួយក្នុងចំណោមការឈឺចាប់ជាច្រើននៅក្នុងប្រទេសនេះ ហើយបានបញ្ជាឱ្យគ្រប់ស្ថាប័នក្នុងរដ្ឋាភិបាលធ្វើសេចក្តីរាយការណ៍ប្រចាំខែ ស្តីពីកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ នៅក្នុងការិយាល័យរបស់ខ្លួន ។

១២. នៅជ្រោយឧបទ្វីបខាងត្បូង បញ្ហានៃអំពើពុករលួយបានក្លាយជាកិច្ចការបន្ទាន់បំផុត ដែលមេដឹកនាំរដ្ឋាភិបាលនានាកំពុងប្រឈមមុខបច្ចុប្បន្ន ។ នៅក្នុងប្រទេសប៉ាគីស្ថាន នាយករដ្ឋមន្ត្រីបានប្រឹងប្រែងបោសសំអាតអំពើពុករលួយក្នុងរដ្ឋាភិបាល ហើយដែលនេះជាគោលដៅគន្លឹះ នៃប្រព័ន្ធរដ្ឋបាលថ្មីរបស់រដ្ឋាភិ-បាលប្រទេសនេះ ។ ថ្មីៗនេះ ប្រធានាធិបតីនៃប្រទេសឥណ្ឌាបានចាត់ទុកអំពើពុករលួយ ថាជាបញ្ហាប្រឈមយ៉ាងចម្បង ដែលប្រទេសនេះកំពុងជួបប្រទះ[៣] ។

---

[២] យោងតាមឯកសារដែលមានក្នុង Oxford Analytica. 1997. *Asia Pacific Daily Brief*, 14 August. បញ្ហាដទៃទៀតមានយោងនៅក្នុងឯកសាររបស់អង្គការមូលនិធិ រូបិយវត្ថុអន្តរជាតិ រួមមាន ការមិនបានចាត់វិធានការនាំខ្លួនជនប្រព្រឹត្តបទល្មើសក្នុងការគៃបន្លំហិរញ្ញវត្ថុរាប់លានដុល្លារដើម្បីកាត់ក្តី, ភាពមិនប្រក្រតីពាក់ព័ន្ធនឹងការផ្តល់កិច្ចសន្យាលើគម្រោង ថាមពលពីរកន្លែង និងការប្រើប្រាស់មូលនិធិដែលពុំមានកំណត់ក្នុងគម្រោងថវិកា ដើម្បីទិញយន្តហោះសម្រាប់ប្រធានាធបតី និងការកសាងព្រលានយន្តហោះអន្តរជាតិ នៅស្រុកកំនើត របស់ប្រធានាធិបតី ។

[៣] K.R. Narayanan. 1997. ប្រទេសឥណ្ឌាអនាគតសម្រាប់យើងទាំងអស់គ្នា ប្រកបដោយក្តីត្រាប្រណី និងគ្មានអំពើពុករលួយ ។ វិចារណកថានៅក្នុងកាសែត *International Herald Tribune* ថ្ងៃទី ១៣ ខែសីហា ។

# II. វិធានការឆ្លើយតបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

១៣. ក្នុងនាមជាស្ថាប័នអភិវឌ្ឍន៍ពហុភាគីចម្បងមួយ និងជាប្រភពនាំមុខក្នុងការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍នៅទ្វីបអាស៊ី ធនាគារអភិវឌ្ឍន៍អាស៊ីស្វាគមន៍ជានិច្ចចំពោះការយកចិត្តទុកដាក់លើការប្រឆាំងអំពើពុករលួយ ដែលជាផ្នែកមួយនៃក្របខ័ណ្ឌការងារដ៏ទូលំទូលាយ ពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ច និងការកសាងសមត្ថភាព ។ ឯកសាររបស់ក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍អាស៊ីស្តីពី *"អភិបាលកិច្ច : កិច្ចគ្រប់គ្រងការអភិវឌ្ឍន៍ឱ្យបានត្រឹមត្រូវ"* ទទួលស្គាល់នូវសារៈសំខាន់នៃការទទួលខុសត្រូវក្នុងចំណោមមន្ត្រីស្ថាប័នសាធារណៈ ព្រមទាំងតម្លាភាព និងភាពអាចទស្សន៍ទាយទុកបាន លើកិច្ចការប្រតិបត្តិរបស់រដ្ឋាភិបាល ដែលជាគោលការណ៍គន្លឹះក្នុងការប្រឆាំងអំពើពុករលួយ[៤] ។ ការយកចិត្តទុកដាក់នៃ គោលនយោបាយនេះផ្តោតជាសំខាន់លើការពង្រឹងលក្ខខណ្ឌចាំបាច់ សម្រាប់ការងាររដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព សំដៅធានាឱ្យមានមូលដ្ឋានគ្រឹះសម្រាប់កសាងប្រព័ន្ធរដ្ឋបាលប្រកបដោយតម្លាភាព ដែលអាចព្យាករណ៍បាន និងដែលមានការទទួលខុសត្រូវ ។ មូលដ្ឋានគ្រឹះចាំបាច់ទាំងនេះរួមមាន ក្របខ័ណ្ឌច្បាប់សមស្រប និង យន្តការពង្រឹងការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាព, សេវាកម្មស៊ីវិលដែលមានវិជ្ជាជីវៈ មានសមត្ថភាពគ្រប់គ្រាន់ ប្រកបដោយភាពជំរុញលើកទឹកចិត្ត និងផ្តល់ការលើកសរសើរការអនុវត្តន៍លទ្ធកម្មប្រកបដោយតម្លាភាព ប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពនិងមានការិយាល័យសវនកម្មឯករាជ្យ ប្រកបដោយសមត្ថភាពគ្រប់គ្រាន់ ។គោលការណ៍ចម្បងទីបួន នៃនយោបាយស្តីពីអភិបាលកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺការចូលរួមពីភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ ។ បទពិសោធន៍ពីហុងកុង ប្រទេសចិន និង សិង្ហបុរី បានបង្ហាញថា ការគាំទ្រជាសាធារណៈមានអត្ថប្រយោជន៍ក្នុងយុទ្ធនាការប្រឆាំងនឹងអំពើទុច្ចរិតរបស់មន្ត្រី ។

១៤. ក្នុងក្របខ័ណ្ឌទូលាយគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រឆាំងនឹងអំពើពុករលួយ មានបំណងកាត់បន្ថយនូវបន្ទុក ដែលអំពើពុករលួយដ៏រាលដាល និងមានលក្ខណៈជាយថាក្រម បានដាក់ទៅលើរដ្ឋាភិបាល និងសេដ្ឋកិច្ចក្នុងតំបន់ ។យុទ្ធសាស្ត្រជាក់លាក់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តោតលើចំនុចជាមូលដ្ឋានបីដូចខាងក្រោម :

(i) ជួយទ្រទ្រង់ទីផ្សារដែលមានការប្រកួតប្រជែង និងប្រព័ន្ធរដ្ឋបាលសាធារណៈប្រកបដោយសមត្ថភាព ប្រសិទ្ធភាព មានការ ទទួលខុសត្រូវ និងតម្លាភាពដែលជាផ្នែកមួយនៃកិច្ចការដ៏ទូលំទូលាយរបស់ខ្លួននៅក្នុងបញ្ហាអភិបាលកិច្ច និងការ កសាងសមត្ថភាព។

(ii) ជួយទ្រទ្រង់កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយដែលអាចមានជោគជ័យតាមករណីដោយឡែកនីមួយៗ និងលើកកម្ពស់គុណភាពនៃការពិភាក្សារវាងធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ស្តីពីបញ្ហាអភិបាលកិច្ចនានា ព្រមទាំងបញ្ហាអំពើពុករលួយ ។

(iii) ធានាថា បណ្តាគម្រោង និងបុគ្គលិកបម្រើការក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីគោរពបាននូវស្តង់ដានៃក្រមសីលធម៌ខ្ពស់បំផុត ។

១៥. ជំពូកទី III និងទី IV នឹងកំណត់នូវវេទិកាសម្រាប់ការពិភាក្សាអំពីគោលបំណងទាំងនេះ ដោយកំណត់អំពីនិយមន័យពាក់ព័ន្ធនឹងប្រធានបទ និងការខាតបង់ដោយសារអំពើពុករលួយនៅក្នុងការអភិវឌ្ឍន៍ ។ ផ្នែកដទៃទៀតនៃឯកសារនេះនឹងពិចារណាអំពីចរិតលក្ខណៈ នៃវិធានការឆ្លើយតបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ជំពូកទី V អធិប្បាយអំពីគោលជំហររបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីបញ្ហាអំពើពុករលួយ និងអធិប្បាយអំពីកម្មវិធីនានានៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានផ្នែកសំខាន់ៗប្រឆាំងអំពើពុករលួយ ហើយដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន ។ ជំពូកនេះ ក៏នឹងបញ្ជាក់ផងដែរអំពីផលវិបាកនានានៃគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រឆាំងអំពើពុករលួយ នៅក្នុងដំណើរការ ប្រតិបត្តិកម្ម វិធីបច្ចុប្បន្នរបស់ស្ថាប័ននេះ ។ ជំពូកទី VI នឹងធ្វើសេចក្តីសន្និដ្ឋាន ដោយធ្វើការកត់សម្គាល់លើបណ្តាវិធានការដែលត្រូវអនុវត្តជាក់លាក់ នៅពេលខាងមុខ ដែលធនាគារអភិវឌ្ឍន៍អាស៊ីនឹងត្រូវប្រកាន់យកដើម្បីអនុវត្តគោលនយោបាយខាងលើនេះ ។

---

៤ R151-95 *Governance: Sound Development Management*, 17 August.

# III. និយមន័យនៃអំពើពុករលួយ

១៦. ពាក្យថា "អំពើពុករលួយ" ត្រូវបានប្រើប្រាស់សម្រាប់សម្គាល់នូវបណ្តាសកម្មភាពខុសច្បាប់ និងខុសទម្លាប់ តាមរូបភាពប្លែកៗជាច្រើនបែប ។ ទោះបីពុំមានការកំណត់និយមន័យឱ្យបានពេញលេញ និងជាសកល អំពីចរិតលក្ខណៈនៃអំពើពុករលួយក្តី ក៏និយមន័យដែលលេចធ្លោជាងគេក្នុងការប្រើប្រាស់មានចំនុចរួមមួយ គឺសង្កត់ធ្ងន់លើអំពើរំលោភដោយប្រើសិទ្ធិអំណាច ឬតួនាទីសាធារណៈ សម្រាប់ផលប្រយោជន៍បុគ្គល ។ វចនានុក្រម *Oxford Unabridged Dictionary* កំណត់និយមន័យនៃអំពើពុករលួយថាជា "អំពើរបិលល្លស ឬការបំផ្លាញភាពសុចរិតក្នុងការអនុវត្ត មុខនាទី តាមរយៈការទទួលសំណូក ឬការអនុគ្រោះ" ។ វចនានុក្រម *Webster's Collegiate Dictionary* បានឱ្យនិយមន័យពាក្យនេះថាជា "ការទាក់ទាញឱ្យមានកំហុសដោយសារមធ្យោបាយពុំត្រឹមត្រូវ ឬខុសច្បាប់ (ជាសំណូក) " ។ និយមន័យជាក់លាក់ប្រើប្រាស់ ដោយធនាគារពិភពលោកគឺ "ការរំលោភលើតួនាទីសាធារណៈ ដើម្បីផលប្រយោជន៍ឯកជន" ។ និយមន័យនេះមានលក្ខណៈប្រហាក់ប្រហែលនឹងនិយមន័យ ដែលប្រើប្រាស់ដោយអង្គការតម្លាភាពអន្តរជាតិ ដែលជាអង្គការក្រៅរដ្ឋាភិបាលឈានមុខគេ ក្នុងកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយលើពិភពលោក ។ អង្គការនេះបានឱ្យនិយមន័យទៅអំពើពុករលួយថា :

> អំពើពុករលួយពាក់ព័ន្ធនឹងឥរិយាបថរបស់មន្ត្រីក្នុងស្ថាប័នសាធារណៈ ទោះជាអ្នកនយោបាយ ឬមន្ត្រីរាជការ ក្នុងការប្រព្រឹត្តិដោយពុំត្រឹមត្រូវ ឬពុំស្របច្បាប់ ដើម្បីនាំមកនូវប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់មនុស្សជិតស្និទ្ធ តាមរយៈការប្រើប្រាស់អំណាចសាធារណៈពុំត្រឹមត្រូវនៅក្នុងតួនាទីរបស់ខ្លួន"[៥] ។

១៧. បណ្តានិយមន័យខាងលើសុទ្ធសឹងមានប្រយោជន៍ ប៉ុន្តែតាមទស្សនៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និយមន័យទាំងនេះពុំបាន ផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ទៅលើបញ្ហាអំពើពុករលួយនៅក្នុងស្ថាប័នឯកជន ឬទៅលើតួនាទីនៃស្ថាប័នឯកជននៅក្នុងការជំរុញឱ្យមានអំពើពុករលួយនៅក្នុងស្ថាប័នសាធារណៈឡើយ ។ តាមការឱ្យនិយមន័យខ្លីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី អំពើពុករលួយគឺជា "អំពើរំលោភលើតួនាទី សាធារណៈ ឬឯកជន ក្នុងបំណងទាញយកប្រយោជន៍ផ្ទាល់ខ្លួន " ។ និយមន័យជាក់លាក់ជាងនេះទៀតត្រូវបានកំណត់ដូចខាងក្រោម :

> អំពើពុករលួយពាក់ព័ន្ធនឹងឥរិយាបថនៃមន្ត្រីនៅក្នុងស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ដែលប្រព្រឹត្តមិនត្រឹមត្រូវ និងខុសច្បាប់ ដើម្បីទាញយកនូវប្រយោជន៍ផ្ទាល់ខ្លួន និង/ឬសម្រាប់មនុស្សជិតស្និទ្ធ ឬអន្ទងអ្នកដទៃឱ្យប្រព្រឹត្ត ដូចនេះដោយប្រើប្រាស់ឋានៈរបស់ខ្លួនពុំត្រឹមត្រូវ ។

១៨. ឥរិយាបថដែលចាត់បញ្ចូលក្នុងជំពូកនៃ "អំពើពុករលួយ" មានបង្ហាញជូនក្នុងប្រអប់ទី ១ ។ ប្រការដែលមានចែងនេះមិនទាន់ពេញលេញនៅឡើយទេ តែមានគោលបំណងដើម្បីបង្ហាញជូនឱ្យបានជ្រាបអំពីបណ្តាប្រការដែលគួរចាប់អារម្មណ៍ និងជាការព្រួយបារម្ភណ៍ជាពិសេសនៃធនាគារអភិវឌ្ឍន៍អាស៊ី ។ ប្រភេទខ្លះនៃអំពើពុករលួយជាបញ្ហាផ្ទៃក្នុង ដែលបង្កជាឧបសគ្គចំពោះស្ថាប័នរដ្ឋាភិបាលក្នុងការជ្រើសរើស ឬគ្រប់គ្រងបុគ្គលិករបស់ខ្លួន ក្នុងការប្រើប្រាស់ធនធានរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ឬក្នុងការស៊ើបអង្កេតផ្ទៃក្នុងដោយពុំមានលំអៀង ។ អំពើពុករលួយខ្លះទៀតជាបញ្ហាកើតមាននៅខាងក្រៅស្ថាប័នដែលពាក់ព័ន្ធនឹងការចាត់ចែង ឬបង្ខិតបង្ខំឱ្យអតិថិជន ឬអ្នកផ្គត់ផ្គង់បង់ប្រាក់កម្រៃ ឬដើម្បីរកប្រយោជន៍ពីព័ត៌មានផ្ទៃក្នុងស្ថាប័ន ។ ក្រៅពីនេះ នៅមានការជ្រៀតជ្រែកដោយពុំមានការអនុញ្ញាតនៅក្នុងដំណើរការទីផ្សារ ដូចជាការប្រើអំណាចរដ្ឋ ដើម្បីដាក់កម្រិតលើការប្រកួតប្រជែង និងការបង្កលក្ខខណ្ឌទៅរកការទទួលសិទ្ធិផ្តាច់មុខជាដើម ។

១៩. ការឱ្យនិយមន័យតាមន័យចង្អៀតដល់អំពើពុករលួយច្រើនតែធ្វើឡើងទៅតាមប្រការចាំបាច់ដើម្បីឆ្លើយតប នឹងករណីជាក់លាក់ណាមួយនៃឥរិយាបថខុសបែបបទ ។ ជាក់ស្តែង ក្នុងក្របខ័ណ្ឌនៃអំពើគៃបន្លំផ្នែកលទ្ធកម្ម ធនាគារពិភពលោកបានឱ្យនិយមន័យនៃការប្រព្រឹត្តិអំពើពុករលួយថាជា "ជំនូន ការផ្តល់ឱ្យ ការទទួល ឬការសុំអ្វីម៉្យាងដែលមានតម្លៃសំដៅដាក់ឥទ្ធិពលទៅលើសកម្មភាពរបស់មន្ត្រីសាធារណៈ នៅក្នុងដំណើរការលទ្ធកម្ម ឬនៅក្នុងអំឡុងពេលនៃការអនុវត្តន៍កិច្ចសន្យា" ។ ការប្រព្រឹត្តអំពើគៃបន្លំមានន័យថាជាការកុហកបំភ្លៃខុសពីការជាក់ស្តែង ដើម្បីជំរុញឱ្យដំណើរការលទ្ធកម្ម ឬការប្រតិបត្តិកិច្ចសន្យា បង្កនូវការខូចខាតដល់ភាគីខ្ចីឥណទាន ហើយរួមមានការស៊ុំគ្រលំរវាងអ្នកចូលរួមដេញថ្លៃក្នុងគោលបំណងបង្កើតតម្លៃនៃការដេញថ្លៃក្លែងក្លាយ ដោយពុំមានការប្រកួតប្រជែងពិតប្រាកដ និងធ្វើឱ្យភាគីខ្ចីឥណទានបាត់បង់ផលប្រយោជន៍ដោយសារ ពុំមានការប្រកួតប្រជែងដោយសេរី និងចំហ[៦] ។

---

[៥] សូមអាន World Bank 1997, p .8 និង Transparency International. 1996. *The TI Sourcebook*, edited by Jeremy Pope. Berlin: TI, p .1. និយមន័យរបស់ធនាគារពិភពលោករួមមានទាំងសកម្មភាពរបស់ភ្នាក់ងារឯកជនដែលធ្វើវិទ្ធង្សនាប្រឆាំងគោលនយោបាយសាធារណៈ និងនីតិវិធីនានា ដើម្បីឆក់យកផលប្រយោជន៍ ពីការប្រកួតប្រជែង ។

[៦] ក្នុងយុទ្ធនាការសំរបសម្រួលរវាងបទដ្ឋានលទ្ធកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាមួយបទដ្ឋានរបស់ធនាគារពិភពលោក ក្រោមប្រធានបទនៃការប្រឆាំងអំពើពុករលួយបណ្តានិយមន័យ ទាំងនេះក៏អាចអនុម័តទទួលយកដោយធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ ។ សូមអានជំពូក VI ។

២០. ប្រការសំខាន់គឺត្រូវបែងចែករវាងអំពើពុករលួយទ្រង់ទ្រាយធំដែលពាក់ព័ន្ធដោយមន្ត្រីជាន់ខ្ពស់ដូចជាការធ្វើសេចក្តីសម្រេចសំខាន់ៗ ឬកិច្ចសន្យា និងការផ្តោះប្តូរទឹកប្រាក់ក្នុងបរិមាណដ៏ច្រើន និងអំពើពុករលួយកម្រិតតូចតាច ដែលមានការពាក់ព័ន្ធជាមួយមន្ត្រីថ្នាក់ទាប ដូចជា ការផ្តល់សេវាកម្មជាប្រចាំ និងការផ្តល់ទំនិញ ឬការផ្តោះប្តូរទឹកប្រាក់ក្នុងបរិមាណតិចតួច ។ ប្រការសំខាន់មួយទៀតគឺត្រូវបែងចែករវាងអំពើពុក រលួយជាយថាក្រម ដែលកើតឡើងនៅក្នុងរដ្ឋាភិបាល ឬក្រសួងទាំងមូល និងអំពើពុករលួយជាលក្ខណៈបុគ្គល ដែលកើតឡើងដាច់ដោយឡែក និង កើតឡើងម្តងម្កាលតែប៉ុណ្ណោះ ។ លើសពីនេះ គឺត្រូវបែងចែករវាងអំពើពុករលួយដែលមានលក្ខណៈជាអង្គការចាត់តាំង ដែលមានការកំណត់ប្រព័ន្ធតាមលំដាប់លំដោយសម្រាប់ទទួល និងបញ្ជូនសំណូក និងអំពើពុករលួយដែលពុំមានលក្ខណៈជាអង្គការចាត់តាំង ដែលក្នុងនោះបុគ្គលជាមន្ត្រីមួយចំនួន ទាមទារ ឬប្រជែងគ្នាក្នុងការទទួលសំណូកជាលក្ខណៈដោយឡែក និងពុំមានការសំរបសម្រួលគ្នា ។

## ប្រអប់ទី ១: តារាងបង្ហាញពីឥរិយាបទនៃអំពើពុករលួយ

- ការរៀបចំ ឬជ្រើសរើសយកគម្រោងដែលពុំផ្តល់ប្រសិទ្ធភាពសេដ្ឋកិច្ច ដោយសារមានឱកាសច្រើនសម្រាប់រកប្រាក់ចំណូលពីការឃោគយល់ និងបរិបាលកិច្ចនយោបាយ ។
- ការគៃបន្លំក្នុងលទ្ធកម្មមានទាំងការឃុបឃិតរួមគំនិត ការយកលើសតម្លៃពិតប្រាកដ ឬការជ្រើសរើសយកភាគីចុះកិច្ចសន្យាក្រុមហ៊ុនផ្គត់ផ្គង់ និងទីប្រឹក្សាដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខុសពីការណ៍ដែលថាអ្នកដែលហ៊ានដេញថ្លៃក្នុងកំរិតទាបបំផុត ហើយដែលត្រូវបានវាយតម្លៃថាត្រឹមត្រូវ គឺជាអ្នកឈ្នះ ។
- ការបង់ប្រាក់ក្រៅច្បាប់ឱ្យដល់មន្ត្រីរដ្ឋាភិបាល "ដើម្បីជួយសម្រួលដំនើរការឱ្យបានរហ័ស" សំដៅសុំឱ្យមានការសម្របសម្រួលទាន់ពេលនូវការផ្តល់ទំនិញ និងសេវាកម្ម ដែលសាធារណៈជនគ្រប់រូបមានសិទ្ធិដូចគ្នា ដូចជាក្នុងករណីនៃការផ្តល់លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណជាដើម ។
- ការបង់ប្រាក់ក្រៅច្បាប់ដល់មន្ត្រីរដ្ឋាភិបាល ដើម្បីសុំជួយសម្របសម្រួលក្នុងការទិញទំនិញ ឬទទួលសេវាកម្ម និង/ឬព័ត៌មានដែលត្រូវរក្សាទុកមិនឱ្យលេចឬជាសាធារណៈ ឬដើម្បីសុំលុបចោលសិទ្ធិរបស់សាធារណៈជនក្នុងការទទួលយកទំនិញ ឬសេវាកម្មដែលច្បាប់បានអនុញ្ញាតឱ្យប្រើប្រាស់ជាសារធារណៈ ។
- ការបង់ប្រាក់ក្រៅផ្លូវច្បាប់ ដើម្បីរាំងស្ទះមិនឱ្យមានការអនុវត្តន៍ច្បាប់ ឬបទបញ្ជាឱ្យបានត្រឹមត្រូវប្រកបដោយយុត្តិធម៌ ជាពិសេសក្នុងផ្នែកពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈ កិច្ចពង្រឹងការអនុវត្តន៍ច្បាប់ និងការប្រមូលចំណូលជូនរដ្ឋ ។
- ការបង់ប្រាក់ដល់មន្ត្រីរដ្ឋាភិបាលដើម្បីឱ្យជួយជំរុញ ឬធានាសិទ្ធិគ្រប់គ្រងផ្តាច់មុខ ឬសិទ្ធិគ្រប់គ្រងដោយមនុស្សមួយក្រុមតូច (អប្បជនាធិបតេយ្យ) លើទីផ្សារនៅពេលដែលពុំមានច្បាប់ណាមួយចែងអំពីការដាក់កំហិត ឬអនុញ្ញាតឱ្យមានការអនុវត្តសិទ្ធិបែបនេះ ។
- ការប្រើប្រាស់ខុសច្បាប់នូវពតិមានសំងាត់សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ដូចជាការប្រើប្រាស់ពតិមានស្តីពីគម្រោងប្រព័ន្ធដឹកជញ្ជូនសាធារណៈក្នុងគោលបំណងធ្វើវិនិយោគលើអចលនៈទ្រព្យ ដែលទំនងជានឹងកើនតម្លៃ ។
- ការផ្សព្វផ្សាយព័ត៌មានពុំត្រឹមត្រូវឬដោយមានចេតនាភូតកុហកអំពីស្ថានភាពហិរញ្ញវត្ថុរបស់បណ្តាក្រុមហ៊ុនសាជីវកម្មដែលបង្កការលំបាក មិនឱ្យបណ្តាអ្នកដែលមានបំណងមកវិនិយោគ អាចធ្វើការប៉ាន់ស្មានបានត្រឹមត្រូវនូវទំហំមូលនិធិសម្រាប់ការវិនិយោគ ដូចជា ការមិនបង្ហើបឱ្យដឹងអំពីទំហំបំណុលពិតប្រាកដ ឬការប៉ាន់តម្លៃទ្រព្យសម្បត្តិរបស់សហគ្រាស ដែលមានបំណងធ្វើឯកជន ភាវូបនីយកម្ម ក្នុងកំរិតទាបជាងតម្លៃពិតប្រាកដ ។
- អំពើលួច ឬបំភ្លៃទ្រព្យសម្បត្តិ ឬថវិការដ្ឋ ។
- ការលក់តំណែងមន្ត្រី តួនាទី ឬដំឡើងឋានន្តរសក្តិ បក្សពួកនិយម ឬបណ្តាសកម្មភាពផ្សេងទៀត ដែលបង្កជាឧបសគ្គដល់ការ កសាងស្ថាប័នស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងដែលមានការជ្រើសតាំងត្រឹមត្រូវ ។
- ការកៀបសង្កត់យកប្រាក់និងការរំលោភប្រើតួនាទីសាធារណៈដូចជាការគំរាមធ្វើសវនកម្មលើពន្ធដារ ឬការគំរាមដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ ដើម្បីទាក់ទាញឱ្យមានការអនុគ្រោះជាលក្ខណៈបុគ្គល ។
- ការបង្កភាពរាំងស្ទះដល់ដំណើរការយុត្តិធម៌ និងការជ្រៀតជ្រែកក្នុងមុខនាទីរបស់ស្ថាប័នទទួលបន្ទុកតាមដានរកស៊ើបអង្កេត និង កាត់ទោសឥរិយាបទខុសច្បាប់ ។

# IV. ការខាតបង់ដោយអំពើពុករលួយ

២១. ជួនកាលគេគិតថា អំពើពុករលួយមិនផ្តល់ឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍន៍ឡើយ ។ កាលពីទសវត្សមុនៗមានអំណះអំណាងថា អំពើពុករលួយអាចមានឥទ្ធិពលផ្តល់ជាប្រយោជន៍ទៅវិញ ។ នៅក្នុងបណ្តាប្រទេសដែលប្រាក់បៀវត្សរ៍ក្នុងស្ថាប័នសាធារណៈមានកម្រិតទាប ដែលក្នុងករណីខ្លះប្រាក់កម្រៃនោះ មិនទាំងគ្រប់គ្រាន់សម្រាប់ការចំណាយក្នុងជីវភាពប្រចាំថ្ងៃផងនោះ អ្នកខ្លះអះអាងថាជារឿងធម្មតាសម្រាប់មន្ត្រីសាធារណៈដែលរកបំពេញបន្ថែមលើប្រាក់បៀវត្សរ៍ខ្លួន ដោយប្រើប្រាស់មធ្យោបាយផ្សេង ។ គេបានលើកឡើងថា អំពើពុករលួយអាចជួយជំរុញប្រសិទ្ធភាពសេដ្ឋកិច្ច ព្រោះវាជួយស្តារតម្លៃក្លែងបន្លំដែលកំណត់តាមយន្តការរដ្ឋបាល ឱ្យទៅជាតម្លៃកំណត់ដោយយន្តការទីផ្សារ ។ក្រុម ផ្សេងទៀតអះអាងថា អំពើពុករលួយមានតួនាទីក្នុងការកែតម្រូវលើការបែងចែក និងផ្ទេរធនធានពីក្រុមបុគ្គល និងក្រុមហ៊ុនសាជីវកម្មដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ទៅឱ្យក្រុមដែលមានមធ្យោបាយខ្សត់ខ្សោយ ឬថាវាអាចដើរតួជាឧបករណ៍ក្នុងការធ្វើសមាហរណកម្មជាតិ ដោយបើកឱកាសឱ្យក្រុមមេដឹកនាំធ្វើការទាក់ទាញឬបង្រួបបង្រួមបណ្តាក្រុមនយោបាយ ជនជាតិ ឬសាសនាផ្សេងៗ ។ លើសពីនេះ អ្នកសិក្សាមួយចំនួនបាន អះអាងថា អំពើពុករលួយគឺជាដំណាក់កាលធម្មជាតិនៃការអភិវឌ្ឍន៍ ។ពួកគេកត់សម្គាល់ថា អំពើពុករលួយក៏ធ្លាប់កើតមានរាលដាលជាទូទៅ នៅក្នុងបណ្តាប្រទេសជឿនលឿនដែររហូតដល់ពេលថ្មីៗនេះ ដែលមានការកាត់បន្ថយ (ប៉ុន្តែមិនទាន់លុបបំបាត់បាននៅឡើយ) តាមរយៈកំណែទម្រង់នយោបាយជាបន្តបន្ទាប់ នៅក្នុងសតវត្សកន្លងមកនេះ ។

២២. លោក Robert Klitgaard ដែលជាមនុស្សម្នាក់ក្នុងចំណោមអ្នកសិក្សាដែលឈ្លាសវៃជាងគេ ក្នុងការស្វែងយល់អំពីអំពើពុករលួយក្នុង កិច្ចអភិវឌ្ឍន៍បានកត់សម្គាល់ថា អំណះអំណាងទាំងនោះមានលក្ខណៈរួមជាច្រើន[៧] ។ទីមួយ អំណះអំណាងទាំងនោះលើកឡើងពីផលប្រយោជន៍ កើតចេញពីសកម្មភាពខុសច្បាប់ និងពុំបានពិចារណាពីផលប៉ះពាល់សរុបនៃអំពើពុករលួយឡើយ ។ ទោះបីមានករណី ឬកិច្ចការខ្លះ ផ្តល់ផលប្រយោជន៍ជាវិជ្ជមានក្តី តែវាក៏អាចបង្កើតឱ្យមាននូវកត្តាខាងក្រៅអវិជ្ជមាន ដែលធ្វើឱ្យគុណភាពនៃដំណើរការរបស់ប្រព័ន្ធនោះកាន់តែ ទន់ខ្សោយជាទូទៅ និងធ្វើឱ្យខូចខាតដល់ប្រសិទ្ធភាពនៃចលនាសេដ្ឋកិច្ចសម្រាប់អនាគតយូរអង្វែង ។

២៣. ទីពីរ ភាគច្រើននៃអ្វីដែលគេហៅថាជាផលប្រយោជន៍កើតពីអំពើពុករលួយ ដូចជាការជួយសម្រួលទំនាក់ទំនងជាមួយប្រព័ន្ធរដ្ឋាភិបាល ឬលើកស្ទួយប្រាក់កម្រៃមន្ត្រីស៊ីវិល អាចនឹងកើតឡើងមែន ប៉ុន្តែមានរូបភាពផ្ទុយនឹងគោលការណ៍នៃស្ថាប័នសាធារណៈ ហើយក៏ឆ្លុះបញ្ចាំងពីភាពបរាជ័យរបស់ស្ថាប័ននោះក្នុងការអនុវត្តការងារឱ្យមានប្រសិទ្ធភាពដែរ ។បទពិសោធន៍ខាងផ្នែកសេដ្ឋកិច្ចដូចជាប្រទេសសិង្ហបុរី បានបង្ហាញថា ការខំប្រឹងប្រែងប្រកបដោយភាពអត់ធ្មត់ និងយូរអង្វែងក្នុងការកែលម្អការងារគ្រប់គ្រងស្ថាប័នសាធារណៈ ដូចជាតាមរយៈការកែសម្រួលបែបបទពន្ធ ឬតាមរយៈការផ្តល់ប្រាក់កម្រៃដែលមានកម្រិតប្រហាក់ប្រហែលនឹងស្ថាប័នឯកជន ទំនងជានឹងនាំមកនូវផលប្រយោជន៍កាន់តែកើនឡើងជាជាង ការអត់អោនឱ្យមានអំពើពុករលួយទ្រង់ទ្រាយធំ សម្រាប់ជាការទូទាត់នឹងចំនុចខ្វះខាតទាំងនោះ ។

២៤. ទីបី អំពើពុករលួយជាកត្តាលើកទឹកចិត្តមនុស្សឱ្យគេចវេសពីបទបញ្ជា ទាំងបទបញ្ជាត្រឹមត្រូវ និងបទបញ្ជាមិនត្រឹមត្រូវ ។ គេពុំអាចធានាថា ក្រុមហ៊ុនអហារណកម្មមួយ ដែលសូកប៉ាន់មន្ត្រីគយឱ្យសម្រួលការត្រួតពិនិត្យឱ្យបានរួសរាន់ សម្រាប់ការនាំចូលថ្នាំពេទ្យដែលមិនត្រូវការ ចាំបាច់ នឹងមិនសូកប៉ាន់មន្ត្រីទាំងនោះដើម្បីឱ្យជួយសម្រួលការដឹកជញ្ជូនគ្រឿងញៀននៅពេលក្រោយនោះឡើយ ។

២៥. កិច្ចការវាយតម្លៃផលប៉ះពាល់បណ្តាលពីអំពើពុករលួយចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសមួយ គឺជាការងារស្មុគស្មាញបំផុតដែលបច្ចុប្បន្នកំពុងតែមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងពីសំណាក់អ្នកសិក្សា ។ ទោះបីមានកាលៈទេសៈខ្លះដែលអំពើខុសច្បាប់អាចលើកស្ទួយអត្រាកំនើនខាងផ្នែកសេដ្ឋកិច្ចក៏ដោយ ក៏ភ័ស្តុតាងជាច្រើនបង្ហាញថាអំពើពុករលួយនាំមានការខាតបង់ច្រើនជាងផលចំណេញ ។ ជាក់ស្តែងការសិក្សាករណីអំពើពុករលួយក្នុងប្រទេសមួយនៅទ្វីបអាហ្វ្រិកបានបង្ហាញថា អំពើពុករលួយបង្កឱ្យមានភាពតានតឹងកាន់តែខ្លាំងឡើងនូវជំលោះជាតិសាសន៍បានបំផ្លាញប្រសិទ្ធភាពរបស់អាជ្ញាធរក្រុង និងស្ថាប័ននានារបស់សហព័ន្ធ ធ្វើឱ្យប្រព័ន្ធចាត់តាំងមន្ត្រី និងការដំឡើងឋានន្តរសក្តិ លែងមានឥទ្ធិពល និងបង្កើតឱ្យមានបរិយាកាសបាត់ការជឿទុកចិត្តនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល" ។ ការសិក្សានៅប្រទេសទ្វីបអាស៊ីមួយបានឱ្យដឹងថា នៅក្នុងគ្រប់ករណីនៃអំពើពុករលួយទាំងអស់ដែលគេបានពិនិត្យ ប្រាក់ដែលប្រមូលបានតាមរយៈអំពើពុករលួយ "ពុំត្រូវបានយកទៅវិនិយោគដោយផ្ទាល់ និងប្រកបដោយប្រសិទ្ធភាពនោះឡើយ"[៨] ។ ការសិក្សាលម្អិតយ៉ាងទូលំទូលាយក្នុងប្រទេស មួយទៀតនៅអាស៊ីបានសន្និដ្ឋានថា :

---

[៧] Robert Klitgaard. 1988. *Controlling corruption*. Berkeley and Los Angeles: University of California Press, p. 32.

[៨] ឯកសារយោងករណីសិក្សានៅទ្វីបអាហ្វ្រិកគឺ Herbert Werlin. 1979. "The Consequences of Corruption: The Ghanaian Experience," in Monday U. Ekpo. ed. *Bureaucrati Corruption in Sub-Saharan Africa: Toward a Search for Causes and Consequences.* Washington DC: University Press of America, p . 253 . ឯកសារយោងករណីសិក្សាទីពីរគឺ Kang Sintaek. 1978. "Conclusions and Recommendations," in a paper prepared for the Fourth Working Meeting on Bureaucratic Behaviour and Development, Hong Kong, August, cited in Klitgaard. 1988. p. 37.

អំពើល្មើសច្បាប់ និងពុករលួយមានឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងក្លាលើកិច្ចប្រឹងប្រែងសម្រាប់ការអភិវឌ្ឍន៍ ដែលបំភាន់ឱ្យឃើញពីអ្វីដែល គេហៅថា "សម្មតិកម្មសេរីនិយម" ដែលមានជាទូទៅនៅបណ្ដាប្រទេសលោកខាងលិច ហើយដែលចាត់ទុកអំពើពុករលួយថាជាជំហានចាំបាច់មួយក្នុងដំណើរអភិវឌ្ឍន៍ ឬជាមធ្យោបាយបង្កើនល្បឿននៃការអភិវឌ្ឍន៍ ។ ផ្ទុយទៅវិញ ឱ្យការស្រាវជ្រាវរបស់យើង បង្ហាញឱ្យឃើញថា អំពើពុករលួយធ្វើឱ្យមានការអន្តរាយដល់ផលិតករដែលពុំមានសមត្ថភាពបង្កើតស្ថានភាពអយុត្តិធម៌ និងអសមធម៌ក្នុងការចែកចាយធនធានសាធារណៈដែលមានតិចតួច និងការបាត់បង់ចំណូលសម្រាប់រដ្ឋាភិបាលទៅក្នុងដៃឯកជន។ ផលវិបាកប្រយោលផ្សេងទៀត ដែលប្រកបដោយឥទ្ធិពលបំផ្លិចបំផ្លាញ គឺអំពើពុករលួយនាំបាត់បង់ភាពជឿជាក់ចំពោះរដ្ឋាភិបាល[៩] ។

២៦. ប្រសិនបើពិនិត្យដោយហ្មត់ចត់អំពើពុករលួយជាច្រើនដែលត្រូវបានអះអាងថានាំមកនូវផលប្រយោជន៍ខាងផ្នែកនយោបាយប្រសិទ្ធភាព និងការចែកចាយធនធានបានល្អនោះ គ្រាន់តែជាការស្រមើស្រមៃតែប៉ុណ្ណោះ ។ មិនត្រឹមតែមិនបានបង្កើតឱ្យមានសមភាពក្នុងការចែកចាយចំណូលប៉ុណ្ណោះទេ អំពើពុករលួយបង្វែរធនធានការគ្រោងចំណាយធនធានសង្គមដល់អ្នកដែលមានសិទ្ធិទទួលស្របច្បាប់ ហើយបង្វែរធនធានទាំងនោះទៅសម្រាប់ក្រុមអ្នកមានទ្រព្យធន អ្នកមានអំណាច និងអ្នកដែលមានខ្សែជិតស្និទ្ធជាមួយអ្នកនយោបាយ ។ ដោយមិនទូទាត់បន្ថែមលើកម្រិតទាបនៃប្រាក់បៀវត្សរ៍របស់មន្ត្រីសាធារណៈ អំពើពុករលួយបង្កមហន្តរាយដល់ប្រព័ន្ធចាត់តាំងមន្ត្រីដែលផ្អែកលើគុណភាពការងារ និងធ្វើឱ្យខូចខាតដល់សេវាកម្មផ្អែកលើវិជ្ជាជីវៈ និងស្មារតីសមូហភាព ។ ក្នុងករណីជាច្រើន វាអាចបង្កឱ្យមានអប្រសិទ្ធភាពបន្ថែមទៀតនៅក្នុងស្ថាប័នសាធារណៈ[១០] ។ ជំនួសឱ្យការពង្រឹងភក្ដីភាពនយោបាយ អំពើពុករលួយច្រើនតែបង្កើតឱ្យមានការមន្ទិលសង្ស័យ និងការមិនពេញចិត្តជាសាធារណៈចំពោះការអនុវត្ត នយោបាយ និងបណ្ដាគោលការណ៍ច្បាប់ពាក់ព័ន្ធ ។

២៧. ការសិក្សាជាច្រើនអំពីកម្រិតនៃការខាតបង់បណ្ដាលពីអំពើពុករលួយទៅតាមករណីដោយឡែកៗពីគ្នាបង្ហាញឱ្យឃើញនូវទិដ្ឋភាពគួរ ឱ្យព្រួយបារម្ភពីការបាត់បង់ធនធាន បណ្ដាលមកពីភាពខ្ជះខ្ជាយ ឬការប្រើប្រាស់ធនធានដែលមិនអាចទទួលលទ្ធផលបានប្រសើរ :

(i) ការគណនាជាច្រើនបានប៉ាន់ប្រមាណថា ទឹកប្រាក់ជំនួយទៅបណ្ដាប្រទេសនៅទ្វីបអាហ្វ្រិកមានរហូតដល់ ៣០ ពាន់ លានដុល្លារ ត្រូវបានគេកែបន្លំ ដើម្បីបង្វិលចូលទៅក្នុងគណនេយ្យផ្ទាល់ខ្លួននៅឯធនាគារបរទេស ។ បរិមាណនេះ មានចំនួនពីរដងនៃផលទុនក្នុងស្រុកប្រចាំឆ្នាំសរុបរួមគ្នារបស់ប្រទេសហ្គាណា កិនយ៉ា និងអ៊ូហ្គង់ដា[១១] ។

(ii) ក្នុងកំឡុងពេល២០ ឆ្នាំចុងក្រោយ ប្រទេសមួយនៅអាស៊ីបូព៌ាត្រូវបានគេប្រមាណថាធ្វើឱ្យបាត់បង់ប្រាក់៤៨ពាន់លានដុល្លារ ដោយសារអំពើពុករលួយដែលជាចំនួនច្រើនជាងបំណុលបរទេសសរុបរបស់ប្រទេសនោះដែលមាន ៤០,៦ ពាន់លានដុល្លារ[១២] ។

(iii) របាយការណ៍ផ្ទៃក្នុងរបស់រដ្ឋាភិបាលប្រទេសមួយផ្សេងទៀតនៅអាស៊ីកឃើញថា នៅក្នុងកំឡុងពេលទសវត្សមុន តម្លៃនៃទ្រព្យសម្បត្តិរដ្ឋបានថយចុះជាង ៥០ ពាន់លានដុល្លារ ជារួមដោយសារមន្ត្រីពុករលួយបានកំណត់បញ្ចុះតម្លៃទ្រព្យសម្បត្តិទាំងនោះដោយចេតនានៅក្នុងការលក់អចលនៈទ្រព្យទៅឱ្យឯកជន ឬទៅឱ្យវិនិយោគិនបរទេស ដើម្បីជាថ្នូរនឹងសំណូក[១៣] ។

(iv) នៅប្រទេសអាស៊ីខាងត្បូងមួយ របាយការណ៍ថ្មីៗនេះរបស់រដ្ឋាភិបាលបង្ហាញថា មានការកែបន្លំទឹកប្រាក់ប្រមាណ ៥០ លានដុល្លារក្នុងមួយថ្ងៃ ដោយសារកំហុសក្នុងការគ្រប់គ្រង និងអំពើពុករលួយ ។ ថ្មីៗនេះ នាយករដ្ឋមន្ត្រី បានធ្វើសេចក្ដី ថ្លែងការណ៍ ជាសាធារណៈថា ភាគច្រើននៃមន្ត្រីក្នុងរដ្ឋាភិបាល និងយន្តការគ្រប់គ្រងរដ្ឋបាលពោរពេញ ដោយអំពើពុករលួយ១៤ ។

(v) ក្នុងទីក្រុងមួយនៅទ្វីបអាមេរិចខាងជើង បណ្ដាក្រុមហ៊ុនជំនួញនានាមានលទ្ធភាពកាត់បន្ថយចំណាយប្រមាណ ៣៣០ លានដុល្លារពីក្នុងវិក័យប័ត្រចំណាយលើការគ្រប់គ្រងសំណល់ប្រចាំឆ្នាំដែលមានកម្រិត ១,៥ ពាន់លានដុល្លារ តាមរយៈការរំដោះឧស្សាហកម្មគ្រប់គ្រងសំណល់ឱ្យចេញផុតពីឥទ្ធិពលគ្របសង្កត់ដោយពួកម៉ាហ្វីយ៉ា[១៥] ។

---

៩ Ledvina V. Carino and Josie H. de Leon. 1983. *Final Report for the Study of Graft and Corruption, Red Tape and Inefficiency in Government*, cited in Klitgaard. 1988. p. 38.

១០ ឧទាហរណ៍នៅក្នុងប្រទេសមួយនៅទ្វីបអាហ្វ្រិករាល់ប្រអប់កុងតឺន័រនីមួយៗដែលនាំចូលមកក្នុងប្រទេស ត្រូវបានទទួលការត្រួតពិនិត្យបីលើកដោយមន្ត្រីគយ ពីព្រោះតែពួកគេចង់ឆកយក ឱកាសប្រព្រឹត្តអំពើពុករលួយ និងទទួលការបង់ប្រាក់ក្រៅផ្លូវច្បាប់ដើម្បីជួយសម្រួលនីតិវិធី តែគេមិនធ្វើការត្រួតពិនិត្យដោយចោះៗតែម្ដងនៅនឹងកន្លែង ដោយផ្អែកលើប្រវត្តិរបស់ក្រុមហ៊ុន និហរណកម្ម ដូចដែលប្រទេសភាគច្រើនអនុវត្តនោះទេ ។

១១ Michelle Celarier 1996. “The Search for the Smoking Gun,” *Euromoney* (September): 49.

១២ ការប៉ាន់ប្រមាណរបស់រដ្ឋាភិបាលប្រទេសហ្វីលីពីនយោងតាម *Reuter Newswire*. 1997. “Philippines Corruption a ‘Nightmare’ – Ramos,” 11 January. See also *Philippines Star*. 1997. “Commission on Audit: P1.2 B Lost to Graft Each Year,” 12 June.

១៣ Internal report, cited from Business Week. 1993. “The Destructive Costs of Greasing Palms,” 6 December, p. 133.

១៤ *The News*. 1997. 28 March.

១៥ *The Financial Time*. 1997. 6 June.

(vi) ការសិក្សាជាច្រើនពីផលប៉ះពាល់នៃអំពើពុករលួយទៅលើនយោបាយលទ្ធកម្មរបស់រដ្ឋាភិបាល ក្នុងបណ្តាប្រទេសមួយចំនួននៅអាស៊ីបង្ហាញឱ្យឃើញថា រដ្ឋាភិបាលទាំងនេះបានចំណាយពី ២០ ទៅ ១០០ ភាគរយបន្ថែម សម្រាប់ទំនិញ និងសេវាថ្លៃជាងតម្លៃពិតប្រាកដ ដែលត្រូវចំណាយក្នុងករណីគ្មានអំពើពុករលួយ [១៦] ។

(vii) រដ្ឋាភិបាលនៃប្រទេសជាច្រើនអាចខាតបង់ប្រមាណ ៥០% នៃប្រាក់ចំណូលបានពីការប្រមូលពន្ធប្រចាំឆ្នាំ ។ ក្រោយពេលដែលមន្ត្រីគយក្នុងប្រទេសមួយនៅទ្វីបអាមេរិចឡាទីន ត្រូវបានគេអនុញ្ញាតឱ្យមានសិទ្ធិទទួលយកភាគរយនៃប្រាក់ពន្ធដែលពួកគេប្រមូលបាន គេសង្កេតឃើញថា ប្រាក់ចំណូលប្រចាំឆ្នាំបានពីការប្រមូលពន្ធបានកើនឡើងរហូតដល់ទៅ ៦០% [១៧] ។

(viii) ការប៉ាន់ប្រមាណខ្លះទៀតពីឥទ្ធិពលនៃអំពើពុករលួយក្នុងប្រទេសមួយនៅទ្វីបអឺរ៉ុបបានសន្និដ្ឋានថា វាបានធ្វើឱ្យបំណុលសរុបដែលមិនទាន់សងរបស់ប្រទេសនេះកើនឡើងរហូតដល់ ១៥% ឬត្រូវជា ២០០ ពាន់លានដុល្លារ ។ ក្នុងទីក្រុងមួយ កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយបានកាត់បន្ថយថ្លៃកសាងហេដ្ឋារចនាសម្ព័ន្ធ ពី ៣៥ ទៅ ៤០% ដែលបើកឱកាសឱ្យរដ្ឋាភិបាលទីក្រុងនោះ ពង្រីកការចំណាយសម្រាប់ជួសជុលសាលារៀន ផ្លូវថ្នល់ គោមភ្លើងតាមដងផ្លូវ និងសេវាសង្គម [១៨] ។

២៨. ទោះបីគេស្ទើរតែមិនអាចវាយតម្លៃបានត្រឹមត្រូវអំពីការខាតបង់ដោយប្រយោលបណ្តាលពីអំពើពុករលួយក្តី ក៏ជារឿយៗ ការខាតបង់នេះធំជាងការខាតបង់ដោយផ្ទាល់ ធនធានដែលមានតិចតួចច្រើនតែត្រូវចំណាយដោយខ្ជះខ្ជាយទៅលើគម្រោងដែលពុំផ្តល់ប្រយោជន សេដ្ឋកិច្ច ដោយសារគម្រោងទាំងនោះមានឱកាសផ្តល់ចំណូលផ្ទាល់ខ្លួនយ៉ាងច្រើន រីឯផ្នែកដែលត្រូវចាត់ទុកជាអាទិភាព ដូចជាវិស័យអប់រំ និង សុខាភិបាល ត្រូវរងគ្រោះដោយសារវិសមាមាត្រនៃការផ្តល់ថវិកា ។ សកម្មភាពសហគ្រាសស្របច្បាប់ត្រូវរាំងស្ទះ ឬទទួលរងការកៀបសង្កត់ ។ សុវត្ថិភាព សាធារណៈត្រូវប្រឈមគ្រោះថ្នាក់ដោយសារការប្រើប្រាស់ ផលិតផល និងសំណង់ដែលមានគុណភាពទាបជាងកម្រិតស្តង់ដា ។ មូលនិធិត្រូវបាន ប្រើប្រាស់ដើម្បីបង្វែរទិសសម្រាប់ការវិនិយោគលើផ្នែកដែលមានតម្លាភាពជាងមុន និងដែលអាចព្យាករណ៍បាន ។ បណ្តាបុគ្គលដែលប្រហែលជា នឹងមិនចូលរួមពាក់ព័ន្ធក្នុងការប្រព្រឹត្តអំពើខុសច្បាប់ យល់ថាខ្លួនពុំមានជំរើសផ្សេងទៀតឡើយ ចំណែកធនធានខាងបញ្ញាត្រូវបានបង្វែរចេញពីសកម្មភាព ដែលផ្តល់ប្រយោជន៍ច្រើន ដើម្បីរិះរកមធ្យោបាយ "ចៀសចេញពីប្រព័ន្ធនេះ" ។ ក្នុងករណីធ្ងន់ធ្ងរមួយចំនួន ភាពស្របច្បាប់នៃស្ថាប័ន សាធារណៈខ្លួនឯង ក៏ត្រូវចោទជាសំណួរ ចំណែករដ្ឋាភិបាលក៏អាចប្រឈមនឹងអតុល្យភាពនយោបាយ ឬត្រូវដួលរលំ ។

២៩. ទោះបីអំពើពុករលួយនាំឱ្យមានការខាតបង់ច្រើន ក៏ផលប៉ះពាល់នៃអំពើពុករលួយទៅលើការអភិវឌ្ឍន៍មិនដូចគ្នាទេ ។ ប្រទេសខ្លះអាចអត់ធ្មត់នឹងអំពើពុករលួយទ្រង់ទ្រាយធំពាក់ព័ន្ធនឹងការទទួលសំណូក និងការកែបន្លំ ហើយអាចនៅបន្តធានាឱ្យសេដ្ឋកិច្ចលូតលាស់ក្នុងកម្រិតសមរម្យមួយ ។ ប្រទេសខ្លះទៀតមិនអាចធ្វើតាមករណីបែបនេះ ។ មានកត្តាជាច្រើនដែលជះឥទ្ធិពលដល់វិសាលភាពនៃអំពើពុករលួយ និងកំណត់ចំណុចដែលអំពើពុករលួយក្លាយទៅជាឧបសគ្គពន្យឺតដំណើរការអភិវឌ្ឍន៍ ។ ទីមួយ មូលដ្ឋានធនធានធម្មជាតិរបស់រដ្ឋ និងប្រភពនានានៃគុណសម្បត្តិរបស់ប្រទេសនោះ មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនសមត្ថភាពទាក់ទាញការវិនិយោគ [១៩] ។ កត្តាទីពីរ គឺទម្រង់នៃទម្លាប់ក្នុងការប្រព្រឹត្តអំពើពុករលួយ ។ ក្នុងប្រទេសខ្លះ អំពើពុករលួយត្រូវបានប្រព្រឹត្តទៅក្រោមរូបភាពជាសកម្មភាពប្រចាំថ្ងៃ ។ ការបង់ប្រាក់កម្រៃក្រៅផ្លូវការត្រូវបានគេបង្ហើបឱ្យដឹងជាមុន និងផ្តោតលើមន្ត្រីជាន់ខ្ពស់តាមរូបភាព "ច្រកតែមួយ" សម្រាប់ទទួលសំណូក ។ វិធីបែបនេះ អាចជួយកាត់បន្ថយការចំណាយសម្រាប់ធ្វើទំនាក់ទំនង និងផ្តល់ពត៌មានជាមុនសម្រាប់ការព្យាករណ៍មុនពេលធ្វើសេចក្តីសម្រេចលើការធ្វើវិនិយោគ ធ្វើឱ្យប្រទេសនេះមានភាពទាក់ទាញ ជាងប្រទេសផ្សេងទៀតដែលមានមន្ត្រីជាច្រើនអាចទាមទារឱ្យបង់ប្រាក់តាមចំនួនមិនកំណត់ជាក់លាក់ និងដែលវិនិយោគិនមិនបានគ្រោងទុកជាមុន ។ ចុងក្រោយបំផុតគឺបញ្ហាដែលថា តើបរិមាណទឹកប្រាក់អាចស្ថិតនៅក្នុងប្រទេសនិងប្រើប្រាស់សម្រាប់វិនិយោគក្នុងសកម្មភាពសេដ្ឋកិច្ចមានប្រយោជន៍ ឬក៏វាត្រូវផ្ញើចេញទៅគណនេយ្យនៅធនាគារក្រៅប្រទេសនោះ ក៏ជាកត្តាដែលនឹងជះឥទ្ធិពលដល់ភាពអត់ធ្មត់នឹងអំពើពុករលួយ ទ្រង់-ទ្រាយធំក្នុងប្រទេសនោះ និងការរក្សាបាននូវស្ថេរភាពនៃការរីកចំរើនខាងសេដ្ឋកិច្ច ក្នុងអត្រាសមស្របមួយដែរ ។

---

[១៦] Thinapan Nakata. 1978. "Corruption in the Thai Bureaucracy: Who Gets What, How and Why in its Public Expenditures, "*Thai Journal of Public Administration* 18 (January): 102-28; Clive Gray. 1979. "Civil Service Compensation in Indonesia. *Bulletin of Indonesian Economic Studies* 15 (March): 85–113; and Robert Wade. 1982. "The System of Administrative and Political Corruption: Canal Irrigation in India."*Journal of Development Studies* 18 (April): 287-328. Cited in Klitgaard. 1988. pp. 39–40.

[១៧] *Business Week*. 1993."The Destructive Costs of Greasing Palms ." 6 December, pp . 134–135 .

[១៨] *Business Week*. 1993."The Destructive Costs of Greasing Palms ." 6 December, pp . 134–135 .

[១៩] ជាទូទៅ បណ្តារដ្ឋដែលមានធនធានធម្មជាតិមានតម្លៃ ឬកម្រ អាចទាក់ទាញឱ្យមានការវិនិយោគបានច្រើនជាងបណ្តារដ្ឋដែលព្យាយាមប្រកួតប្រជែងតាមរយៈផលិតកម្មដែលផ្តល់ប្រាក់ បៀវត្សរ៍ទាប និងប្រើប្រាស់កំលាំងពលកម្មច្រើន ។ ជារឿងដែលគួរឱ្យហួសចិត្ត បណ្តារដ្ឋដែលសំបូរដោយធនធានជាញឹកញាប់មានការរីកចំរើនក្នុងកម្រិតទាបជាងបណ្តាប្រទេសមួយចំនួន ដែលមានធនធាន តិចតួច ។ សូមអាន Philip R . Lane and Aaron Tornell . 1996 . "Power, Growth and the Voracity Effect." *Journal of Economic Growth*,1 (June): 213–241

៣០. ទោះបីជាមានការព្រមានបែបនេះក្តី ការសិក្សាស្រាវជ្រាវថ្មីៗនេះដែលផ្អែកលើការពិសោធន៍ជាក់ស្តែងបង្ហាញថា ទោះបីជាមានការកែតម្រូវកត្តាជាច្រើន ដូចជាកំណែប្រសិទ្ធភាពនៃប្រព័ន្ធរដ្ឋបាលក្តី ក៏បណ្តាប្រទេសដែលអត់ធ្មត់នឹងអំពើពុករលួយទ្រង់ទ្រាយធំ ពុំទំនងជាអាចទទួលជោគជ័យធំធេងដូច ដែលប្រទេសនោះអាចនឹងទទួលបាន ប្រសិនបើពុំមានពាក់ព័ន្ធនឹងអំពើពុករលួយទេនោះ ។ នៅក្នុងការសិក្សាសម្រាប់បណ្តាប្រទេសជាង 70 ក្នុងអំឡុងចុងទសវត្សឆ្នាំទី 70 និងដើមទសវត្សឆ្នាំទី 80 អ្នកជំនាញសេដ្ឋកិច្ចនៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ គឺលោក Paolo Mauro បានរកឃើញថា អំពើពុករលួយ "មានការពាក់ព័ន្ធជាអវិជ្ជមានក្នុងកម្រិតខ្ពស់នៅក្នុងការវិនិយោគ ទោះបីជាមានភាពស្មុគស្មាញនៅក្នុងប្រព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាលក៏ដោយ" ។ គំរូម៉ូដែលរបស់លោក Mauro បង្ហាញថា កំណែលម្អលើគម្លាតនៃស្តង់ដានៅក្នុង "សន្ទស្សន៍ អំពើពុករលួយ" អាចនឹងនាំឱ្យមានកំនើនផលទុនក្នុងស្រុកសរុប 2,9% ក្នុងអត្រានៃការវិនិយោគ និងកំនើន 1,3% ក្នុងអត្រានៃកំណើនផលទុន ក្នុងស្រុកប្រចាំឆ្នាំសម្រាប់បុគ្គលម្នាក់ៗ [២០] ។

៣១. ការវិភាគខាងលើនេះ បានទទួលការគាំទ្រពីការសិក្សានានាជាច្រើនដែលបានធ្វើនៅពេលថ្មីៗនេះ ។ ដោយប្រើប្រាស់ទិន្នន័យបានពីប្រទេសឧស្សាហកម្ម និងប្រទេសកំពុងអភិវឌ្ឍចំនួន 39 ដែលត្រួតពិនិត្យលើចំណូលវិស័យអប់រំ និងការបំភ្លែនយោបាយ អ្នកស្រាវជ្រាវពីររូប មកពីធនាគារពិភពលោក បានរកឃើញថា បណ្តាប្រទេសដែលគេយល់ថាមានអំពើពុករលួយកម្រិតទាប អាចមានលទ្ធភាពទាក់ទាញការវិនិយោគបានច្រើនជាងបណ្តាប្រទេសដែលគេយល់ថាងាយនឹងមានសកម្មភាពខុសច្បាប់ និងអំពើពុករលួយ ។ លទ្ធផលនេះបង្ហាញនូវភាពពិត ទាំងចំពោះបណ្តា ប្រទេស ដែលអំពើពុករលួយមានទម្រង់ជាអង្គការចាត់តាំង និងដែលអាចព្យាករណ៍បាន និងទាំងសម្រាប់បណ្តាប្រទេសដែលអំពើពុករលួយមានទម្រង់តាមបែបផ្សេង [២១] ។ ការសិក្សាថ្មីមួយផ្សេងទៀត ដែលផ្អែកលើការវិភាគទិន្នន័យសេដ្ឋកិច្ច ដើម្បីពិនិត្យផលប៉ះពាល់ដោយផ្ទាល់ បណ្តាលពីអំពើពុករលួយចំពោះការវិនិយោគបរទេសនៅអាស៊ីបូព៌ា បង្ហាញថា ការកត់សម្គាល់ដឹងពីអំពើពុករលួយមានផលប៉ះពាល់យ៉ាងខ្លាំងក្លា និងជាអវិជ្ជមានទៅលើការវិនិយោគបរទេស ។ យោងតាមលទ្ធផលរកឃើញក្នុងការសិក្សានេះ ស្ថានភាពបែបនេះនៅអាស៊ីបូព៌ា មានសភាពមិនខុសពីស្ថានភាពនៅភូមិភាគដទៃទៀតឡើយ [២២] ។

---

[២០] Paolo Mauro. 1995. "Corruption and Growth." *Quarterly Journal of Economics*. 681 (August): 681–711. The citations are from page 695 and 683, respectively. គួរកត់សម្គាល់ដែរថាភាគច្រើននៃការសិក្សាវិភាគសេដ្ឋកិច្ចអន្តរប្រទេសទាំងនេះមានមូលដ្ឋានលើការកត់ សម្គាល់ (ជាជាងសកម្មភាពជាក់ស្តែង) អំពើពុករលួយហើយការសិក្សាបែបនេះអាចមានបញ្ហាក្នុងការបែងចែករវាងផលវិបាកនៃអំពើពុករលួយកើតចេញពីកត្តាពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងគុណភាពនៃអភិបាលកិច្ច ។

[២១] ការវិភាគធ្វើដោយ ប្រ៊ុសរ ដ៉ោរដ្យ រួមផ្សំជាមួយរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ 1997. See World Bank 1997 . *World Development Report 1997*, Washington DC: World Bank, pp . 102–109.

[២២] Shang-jin Wei. 1997. "How Taxing is Corruption on International Investors." *Working Paper 6030*, National Bureau of Economic Research, Cambridge, MA.

# V. គោលជំហររបស់ធនាគារអភិវឌ្ឍន៍អាស៊ីចំពោះការប្រឆាំងអំពើពុករលួយ

៣២. ផ្អែកលើសេចក្តីអធិប្បាយខាងលើ ធនាគារអភិវឌ្ឍន៍អាស៊ីអះអាងថា ឥរិយាបទខុសច្បាប់ និងពុករលួយ គឺជាឧបសគ្គយ៉ាងធ្ងន់ធ្ងរចំពោះដំណើរការអភិវឌ្ឍន៍ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបដិសេធអំណះអំណាងដែលថា ផលប្រយោជន៍បានពីអំពើពុករលួយមានទំហំធំជាងផលវិបាកជាអវិជ្ជមាន ឬដែលថាវាមិនមែនជាប្រការសមស្របទេដែលស្ថាប័នហិរញ្ញវត្ថុអន្តរជាតិព្យាយាមដោះស្រាយបញ្ហាទាំងនេះ ។ ធនាគារអភិវឌ្ឍន៍អាស៊ី កត់សម្គាល់ថាបទពិសោធន៍ទទួលបានពីតំបន់អាស៊ី និងមហាសាគរប៉ាស៊ីភិចក៏ដូចជាពីតំបន់ផ្សេងទៀតបង្ហាញថាគេអាចធ្វើឱ្យមានភាពជឿនលឿនច្រើនក្នុងការប្រឆាំងនឹងអំពើពុករលួយ ប្រសិនបើមានការកែទម្រង់សមស្របផ្នែកច្បាប់ ស្ថាប័ន និងនយោបាយនៅក្នុងប្រទេស ។ ធនាគារអភិវឌ្ឍន៍ អាស៊ីស្វាគមន៍ជានិច្ចនូវកំនើននៃការយកចិត្តទុកដាក់ ចំពោះបញ្ហាប្រឆាំងអំពើពុករលួយដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដ៏ខ្លាំងក្លារបស់ខ្លួន ដើម្បីលើកស្ទួយគោលការណ៍តម្លាភាព ភាពអាចព្យាករណ៍បាន ការទទួលខុសត្រូវ និងការចូលរួមចំណែកពីគ្រប់ភាគី នៅក្នុងគោលនយោបាយអភិបាលកិច្ចរបស់ខ្លួន ។

៣៣. ក្នុងក្របខ័ណ្ឌទូលាយ គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រឆាំងនឹងអំពើពុករលួយ មានបំណងកាត់បន្ថយនូវបន្ទុក ដែលអំពើពុករលួយដ៏រាលដាល និងមានលក្ខណៈជាយថាក្រម បានដាក់ទៅលើរដ្ឋាភិបាល និងសេដ្ឋកិច្ចក្នុងតំបន់ ក៏ដូចជាទៅលើការអភិវឌ្ឍន៍នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកនៃធនាគារអភិវឌ្ឍន៍អាស៊ី ។ ដោយផ្អែកលើមាត្រាទី 36(2) នៃធម្មនុញ្ញរបស់ខ្លួន កិច្ចប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងឈរយ៉ាងរឹងមាំលើមូលដ្ឋាននៃគោលការណ៍សេដ្ឋកិច្ច និងការយកចិត្តទុកដាក់លើការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ឱ្យបានត្រឹមត្រូវ ។ គោលការណ៍ទាំងនេះនឹងមិនជ្រៀតជ្រែកក្នុងកិច្ចការនយោបាយនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ឬទទួលការរងឥទ្ធិពលពីចរិត នយោបាយនៃបណ្តាប្រទេសទាំងនោះឡើយ ។

៣៤. ដាក់ស្តែង វិធីសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីផ្តោតលើគោលបំណងបីជាមូលដ្ឋាន :

(i) ជួយទ្រទ្រង់ទីផ្សារដែលមានការប្រកួតប្រជែង និងប្រព័ន្ធរដ្ឋបាលសាធារណៈប្រកបដោយសមត្ថភាព ប្រសិទ្ធភាព ការទទួលខុសត្រូវ និងតម្លាភាព ដែលជាផ្នែកមួយនៃកិច្ចការដ៏ទូលំទូលាយរបស់ខ្លួននៅក្នុងបញ្ហាអភិបាលកិច្ច និងការកសាងសមត្ថភាព ។

(ii) ជួយទ្រទ្រង់កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយដែលអាចមានជោគជ័យ តាមករណីដោយឡែកនីមួយៗ និងលើកកម្ពស់គុណភាពនៃការពិភាក្សារវាងធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ស្តីពីបញ្ហាអភិបាលកិច្ចនានា ព្រមទាំងបញ្ហាអំពើពុករលួយ ។

(iii) ធានាថា បណ្តាគម្រោង និងបុគ្គលិកបម្រើការក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គោរពបាននូវស្តង់ដានៃក្រមសីលធម៌ខ្ពស់បំផុត ។

---

## ក. គោលបំណងទី ១ : ទ្រទ្រង់ទីផ្សារដែលមានការប្រកួតប្រជែង និងប្រព័ន្ធរដ្ឋបាលសាធារណៈប្រកបដោយសមត្ថភាព ប្រសិទ្ធភាពមាន ការទទួលខុសត្រូវ និងតម្លាភាព

---

៣៥. ដោយសារនេះជាគោលនយោបាយកំលាំងជំរុញជាចម្បង នៃកិច្ចប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការប្រឆាំងអំពើពុករលួយនឹងដោះស្រាយបញ្ហានេះ ក្នុងក្របខ័ណ្ឌជាផ្នែកមួយនៃការងាររួមរបស់ខ្លួនស្តីពីអភិបាលកិច្ច និងការកសាងសមត្ថភាព ។ វិធីដោះស្រាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានលក្ខណៈប្រតិសកម្ម និងផ្តោតការយកចិត្តទុកដាក់ជាបន្ថែមពីលើកិច្ចប្រឹងប្រែងដែលមានស្រាប់បច្ចុប្បន្ន ដើម្បីពង្រឹងប្រសិទ្ធភាពទីផ្សារ និងគុណភាពនៃស្ថាប័នសាធារណៈទាំងមូល ។ កិច្ចផ្តោតការយកចិត្តទុកដាក់លើវិធានការការពារជាមុន ជាជាងការជំរះក្តីឆ្លុះបញ្ចាំងឱ្យឃើញថា ភាគច្រើននៃគំនិតផ្តួចផ្តើមជាអាទិភាពលើផ្នែកអភិបាលកិច្ច បង្កើតឱ្យមានកត្តាខាងក្រៅវិជ្ជមានសំខាន់នៅក្នុងកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ ។ ជោគជ័យសម្រាប់អនាគតរយៈពេលវែងទំនងជាកើតឡើង ដោយសារភាពអត់ធ្មត់ និងការព្យាយាមឱ្យមានកំណែទម្រង់ ផ្នែកសេដ្ឋកិច្ច ច្បាប់ និងផ្នែកស្ថាប័ន ជាជាងការប្រើវិធានការរយៈពេលខ្លី និងការខិតខំប្រឹងប្រែងដែលជាទូទៅមានលក្ខណៈប្រតិកម្មសម្រាប់ដាក់ ទោសដល់បុគ្គលដែលមានកំហុស [២៣] ។

---

[២៣] ការតាមដានរកឱ្យឃើញ និងជំរះក្តីសកម្មភាពខុសច្បាប់ ធ្លាប់បានទទួលជោគជ័យនៅក្នុងកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ ។ ប៉ុន្តែ វិធីសាស្ត្រដែលមានប្រសិទ្ធភាពជាងគឺការអនុវត្តន៍ វិធានការណ៍ចំរុះដោយការជំរះក្តី និងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើកិច្ចការពារទុកជាមុន ។ តាមបទពិសោធន៍ជាក់ស្តែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីផ្ទាល់ កិច្ចការពារទុកជាមុន មានគុណសម្បត្តិយ៉ាងច្រើន ។

៣៦. មានចំនុចជាអាទិភាពពីរ ដែលធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តោតការយកចិត្តទុកដាក់នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនស្តីពីអភិបាលកិច្ច គឺៈ ការពិភាក្សានយោបាយដើម្បីទម្រង់ទិសទៅបង្កើតឱ្យមានសេរីភាវូបនីយកម្មសេដ្ឋកិច្ច និងកំណែទម្រង់រដ្ឋបាលសាធារណៈ ។ ពាក់ព័ន្ធនឹងចំនុចទីមួយខាងដើម ធនាគារអភិវឌ្ឍន៍អាស៊ីអាចបើកយុទ្ធនាការពិភាក្សាជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិករបស់ខ្លួន ដើម្បីលើកជាអនុសាសន៍គោលនយោបាយ ដែលជួយលុបបំបាត់ការកៀបសង្កត់លើកំលាំងទីផ្សារ និងកាត់បន្ថយឱកាសកេងយកផលចំណេញនាពេលបច្ចុប្បន្នពីសំណាក់ក្រុម-ហ៊ុន ឬមន្ត្រីរដ្ឋាភិបាល ។នយោបាយបើកទូលាយនូវការផ្តល់អាជ្ញាប័ណ្ណ ការបើកឱ្យមានទីផ្សារប្តូររូបិយវត្ថុអន្តរជាតិ ការកាត់បន្ថយន្តការគ្រប់គ្រងតម្លៃនៅទីផ្សា ការពង្រីកឱកាសផ្តល់ឥណទានដល់កសិករក្រីក្រ និងអ្នករកស៊ីតូចតាច ការលុបចោលជំនួយទ្រទ្រង់ដោយរដ្ឋាភិបាល និង ផ្តល់ប្រាក់កម្ចីអនុគ្រោះដល់បណ្តាក្រុមហ៊ុនដែលខ្លួនពេញចិត្ត ព្រមទាំងការកំណត់ឱ្យច្បាស់នូវភាពខុសគ្នារវាងមុខនាទីផលិតកម្ម និងនីតិកម្ម ។ល។ ទាំងអស់នេះសុទ្ធសឹងជាមធ្យោបាយដែលនៅក្នុងនោះកំណែទម្រង់គោលនយោបាយនានាអាចលើកស្ទួយតួនាទីតាមផ្នែកនីមួយៗ និងកាត់បន្ថយឱកាសសម្រាប់ប្រព្រឹត្តអំពើពុករលួយ និងបណ្តាអំពើគៃបន្លំ ។ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងតែអនុវត្តជាបណ្តើរៗនូវគំនិត ផ្តួចផ្តើមជាច្រើនក្នុង ចំណោម ចំនុចថែងខាងលើតាមរយៈកិច្ចចរចាជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិករបស់ខ្លួន ( ប្រអប់ទី 2) ។

## ប្រអប់ទី ២ : ឧទាហរណ៍ស្តីពីការផ្តល់ឥណទាន និងជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ ទ្រទ្រង់សេរីភាវូបនីយកម្មទីផ្សារ និងកំណែទម្រង់នយោបាយ

**Loan 1444 and TA 2587:** គម្រោងស្តារផ្លូវថ្នល់ និងពង្រឹងស្ថាប័នគ្រប់គ្រងផ្លូវគមនាគមន៍នៅប្រទេសគីរហ្គីសៈ នៅខែមិថុនា ឆ្នាំ ១៩៩៦ ក្រុមប្រឹក្សាភិបាល បានអនុម័តប្រាក់កម្ចីចំនួន ៥០ លានដុល្លារ ដល់សាធារណរដ្ឋគីរហ្គីស សម្រាប់ការជួសជុលផ្លូវគមនាគមន៍ ។ ផ្នែកមួយនៃគម្រោងនេះ និងជំនួយបច្ចេកទេសពាក់ព័ន្ធ(TA) ត្រូវបានរៀបចំឡើង ដើម្បីបើកឱកាសឱ្យមានការប្រកួតប្រជែងក្នុងផ្នែកដឹកជញ្ជូន សំដៅឱ្យអតិថិជនអាចធ្វើការជ្រើសរើសរវាងជំរើសនានា ដោយផ្អែកលើថ្លៃ និង គុណភាពនៃសេវាកម្ម និងដោយពុំមានភាពលំអៀងពីសំណាក់រដ្ឋាភិបាល ( តាមរយៈបទបញ្ជាការត្រួតត្រាថ្លៃ ភាពលំអៀង ក្នុងការចេញអាជ្ញាប័ណ្ណ ឬអន្តរាគមន៍ផ្សេងៗទៀត) រវាងសេវាកម្មដឹកជញ្ជូនរបស់រដ្ឋាភិបាល និងរបស់ក្រុមហ៊ុនឯកជន ។

**Loan 1506:** កម្មវិធីគ្រប់គ្រងធនធានស្ថាប័នសាធារណៈនៅរដ្ឋគុជរាត : នៅខែ ធ្នូ ឆ្នាំ ១៩៩៦ ក្រុមប្រឹក្សា ភិបាលបានអនុម័ត : ប្រាក់កម្ចីចំនួន ២៥០ លានដុល្លារ និងជំនួយបច្ចេកទេសជាបន្ថែម សម្រាប់រដ្ឋគុជរាតនៃប្រទេសឥណ្ឌា ដើម្បីលើកកម្ពស់គុណភាព នៃការគ្រប់គ្រងស្ថាប័នសាធារណៈ និងជួយទ្រទ្រង់សហគ្រាសមួយចំនួនដែលបោះបង់ចោលគម្រោង វិនិយោគមួយចំនួននៅក្នុងរដ្ឋ និងដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ ។ គោលបំណងជាសំខាន់នៃកិច្ចពិភាក្សាគោលនយោបាយ របស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺការប្រែត្រលប់ផលប៉ះពាល់នៃគោលនយោបាយ និងបទបញ្ញត្តិចាស់ ដែល មានភាពលំអៀងប្រឆាំងនឹងការចូលរួមពីសំណាក់ស្ថាប័នឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ រួមទាំងកង្វះតម្លាភាពនៅក្នុងប្រព័ន្ធធ្វើសេចក្តីសម្រេចអវត្តមាន នៃបទបញ្ញត្តិពាក់ព័ន្ធនឹងការសុំចូលដេញថ្លៃនិងការវាយតម្លៃដំនើរការដេញថ្លៃ បញ្ហាពាក់ព័ន្ធនឹងការកំនត់ថ្លៃ និង បញ្ហា ច្បាប់ទាក់ទងនឹងលក្ខខណ្ឌទទួលសិទ្ធិផ្តាច់មុខ ភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់ ការដោះស្រាយជំលោះ និងការវិនិច្ឆ័យ តាមរយៈអាជ្ញាកណ្តាល ។ គោលដៅនៃគម្រោងការនេះគឺកាត់បន្ថយសកម្ម-ភាពជ្រៀតជ្រែកពីស្ថាប័នសាធារណៈ ក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាកម្មដោយផ្ទាល់តាមរយៈការបង្វែរទិស និងពង្រឹងតួនាទីផ្នែកច្បាប់របស់ស្ថាប័នសាធារណៈ ដើម្បីធានាឱ្យស្ថាប័នឯកជនមានតួនាទីសកម្មនៅក្នុងការងារនេះ ។

៣៧. មានវិធីច្រើនបែប ដែលអាចឱ្យកិច្ចការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការកែទម្រង់សហគ្រាស និងអភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុ រួមជាមួយនឹងប្រតិបត្តិការខាងផ្នែកវិស័យឯកជនរបស់ខ្លួន ចូលរួមចំណែកបង្កើនភាពប្រកួតប្រជែង តម្លាភាព និងការទទួលខុសត្រូវ ។ ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងជួយគាំទ្រកំណែទម្រង់គោលនយោបាយនៅតាមបណ្តាប្រទេសជាច្រើន ដែលមានបំណងកែប្រែបទបញ្ជាគ្រប់គ្រងធនាគារដើម្បីបើកឱកាសឱ្យមានការប្រកួតប្រជែងជាងមុន និង កាត់បន្ថយការឱ្យខ្ចីឥណទានដោយបញ្ជាព្រមជាមួយនឹងការពង្រឹងសមត្ថភាពរបស់ស្ថាប័នធ្វើបទបញ្ជា ។ ការងារដូចគ្នានេះក៏មានធ្វើនៅក្នុងផ្នែកទីផ្សារទុន ដែលធនាគារអភិវឌ្ឍន៍អាស៊ីកំពុងព្យាយាមស្នើឱ្យកែលម្អលើការបើកចំហឱ្យដឹងនូវបណ្តាព័ត៌មានពាក់ព័ន្ធ និងកែលម្អការអង្កេតទីផ្សារ ។ តាមរយៈអង្គភាពប្រតិបត្តិផ្នែកស្ថាប័នឯកជនរបស់ខ្លួនធនាគារអភិវឌ្ឍន៍អាស៊ីវិនិយោគលើ គម្រោងកាតាលីករជាច្រើន ដូចជាស្ថាប័នកំណត់តម្លៃនានា ដែលផ្តល់តម្លាភាពក្នុងផ្សារទុន តាមរយៈការបោះពុម្ពផ្សាយអំពីការវិនិច្ឆ័យឯករាជ្យ ទាក់ទងនឹងគុណភាពនៃការវិនិយោគក្នុងបរិធានបំណុល ។ ទង្វើបែបនេះអាចជួយបណ្តាវិនិយោគិនឱ្យធ្វើសេចក្តីសម្រេចដោយផ្អែកលើពត៌មានគ្រប់គ្រាន់ ។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏មានចំណែកកាន់តែច្រើនឡើង ក្នុងការជួយពង្រឹងអភិបាលកិច្ចក្នុងសាជីវកម្មនៃក្រុមហ៊ុនឯកជន និងក្នុងការពង្រឹងមូលនិធិវិនិយោគណា ដែលខ្លួនមានការចាប់អារម្មណ៍ដាក់ភាគហ៊ុន ។ ក្នុងស្ថានភាពនៃវិបត្តិហិរញ្ញវត្ថុ ដែលកើតមានក្នុងបណ្តាប្រទេសជា ច្រើនក្នុងតំបន់អាស៊ី និងមហាសាគរប៉ាស៊ីភិច កិច្ចប្រឹងប្រែងបែបនេះកំពុងតែមានការវិវត្តន៍រីកចំរើនយ៉ាងឆាប់រហ័ស ។ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏ពិចារណាផងដែរលើការទ្រទ្រង់គំនិតផ្តួចផ្តើមថ្មីៗទៀត ដូចជាក្នុងផ្នែកលុបបំបាត់ការផ្ទេរប្រាក់បានពីមុខជំនួញខុសច្បាប់ជាដើម ។

៣៨. ការយកចិត្តទុកដាក់ជាពិសេសត្រូវផ្តោតលើការធ្វើឯកជនភាវូបនីយកម្ម ។ តាមធម្មតា តែងតែមានហេតុផលដ៏ខ្លាំងក្លាខាង ផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដែលធ្វើឱ្យរដ្ឋាភិបាលលុបចោលបណ្តាសកម្មភាពដែលផ្តល់ប្រយោជន៍តិចតួច ។ ការស្រាវជ្រាវជំហានដំបូងបង្ហាញថា ឯកជនភាវូបនីយកម្ម ក៏អាចជួយកាត់បន្ថយអំពើពុករលួយផងដែរ ប្រសិនបើដំណើរការនោះប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ ។ ប៉ុន្តែ នៅក្នុងប្រទេសជាច្រើនដំណើរការឯកជនភាវូបនីយកម្មច្រើនតែមានការបន្លំ ដោយមានការចោទប្រកាន់ពីការទទួលសំណូក លួច និងកេងប្រវ័ញ្ច ។ ដើម្បីជៀសវាងបញ្ហាទាំងនេះ ប្រការចាំបាច់ ត្រូវធានាឱ្យមានការប្រើប្រាស់នីតិវិធីដែលមានតម្លាភាព មិនលំអៀង និងមានលក្ខណៈប្រកួតប្រជែង ក្នុងការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ក្នុងករណីដែលការលក់ដូរជាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលផ្តាច់មុខដោយជៀសពុំរួចប្រការសំខាន់ត្រូវបង្កើតស្ថាប័ននីតិកម្ម ឯករាជ្យមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ត្រួតពិនិត្យឱ្យបានត្រឹមត្រូវមុនពេលធ្វើឯកជនភាវូបនីយកម្ម ។ បញ្ហាទាក់ទងនឹងក្រមអនុវត្តប្រសើរបំផុត នៅក្នុងអភិបាលកិច្ចសាជីវកម្ម ក៏ជាសមាសភាគដ៏សំខាន់មួយនៃកម្មវិធីឥណទាន និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលពាក់ព័ន្ធនឹងបញ្ហាឯកជនភាវូបនីយកម្ម ការធ្វើសាជីវកម្ម និងការគ្រប់គ្រងសហគ្រាសសាធារណៈ ។

៣៩. កំណែទម្រង់រដ្ឋបាលសាធារណៈសំខាន់ៗជាច្រើននៅចុងសតវត្សទី ១៩ និងដើមសតវត្សទី ២០ បានកើតឡើងជាការឆ្លើយតបនឹងអំពើ ទុច្ចរិតជាផ្លូវការ ។ ដោយចាត់ទុកការកែទម្រង់ស្ថាប័នសាធារណៈយ៉ាងពេញលេញថា ជាអាទិភាពទីមួយ ធនាគារអភិវឌ្ឍន៍អាស៊ីអាចជួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកឱ្យមានការកែប្រែ ដែលនឹងបង្កការលំបាកកាន់តែខ្លាំងដល់ការប្រព្រឹត្តអំពើពុករលួយ និងដើម្បីឱ្យមានភាពងាយស្រួលក្នុងការតាមដានរកឱ្យឃើញនៅពេលដែលវាកើតឡើង ។ ការអធិប្បាយលម្អិតអំពីគំនិតផ្តួចផ្តើមកែទម្រង់ ដែលមានសមាសភាគប្រឆាំងអំពើពុករលួយសំខាន់ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធ[២៤] ។

៤០. ពិនិត្យមើលទៅស្ថាប័ននីតិប្រតិបត្តិមុនគេ ។ មានវិស័យអាទិភាពមួយចំនួន ដែលកិច្ចប្រឹងប្រែងដើម្បីលើកកម្ពស់គុណភាពផ្នែករដ្ឋបាលសាធារណៈរបស់ប្រទេសមួយ នឹងផ្តល់នូវផលចំណេញក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ កិច្ចប្រឹងប្រែងពង្រឹងប្រព័ន្ធព័ត៌មាន ជាពិសេសចំពោះប្រព័ន្ធព័ត៌មានទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែជំរុញឱ្យមានតម្លាភាព និងការទទួលខុសត្រូវ ហើយពង្រឹងសមត្ថភាពរដ្ឋាភិបាលក្នុងការតាមដានរាល់ការចំណាយ ។ បណ្តាវិធានការណ៍ពង្រឹងតួនាទីសវនកម្មផ្ទៃក្នុង និងដើម្បីធានាឱ្យមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើរាល់ការបញ្ចេញសាច់ប្រាក់សម្រាប់ចំណាយនានា អាចបំពេញតួនាទីពីរក្នុងពេលតែមួយ គឺការជួយតាមដាននិងកែលម្អការអនុវត្តន៍ ហើយក៏ធ្វើឱ្យរាល់អំពើកិបកេង និងគៃបន្លំ អាចត្រូវតាមដានរកឃើញដោយងាយ ។ ការកែទម្រង់លទ្ធកម្មដែលធនាគារអភិវឌ្ឍន៍អាស៊ីកំពុងតែដាក់ឱ្យអនុវត្ត នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកមួយចំនួន អាចជួយកាត់បន្ថយថ្លៃចំណាយ ហើយក្នុងពេលជាមួយគ្នានេះដែរ ធ្វើឱ្យរាល់ការប្រព្រឹត្តបទល្មើស និងបទរំលោភច្បាប់ មានការលំបាកជាងមុន ។

៤១. ផ្នែកមួយផ្សេងទៀតដែលអាចធ្វើឱ្យមានការជឿនលឿនប្រព្រឹត្តទៅបាន គឺការកែទម្រង់ក្របខ័ណមន្ត្រីសាធារណៈ ។ ឯកសាររបស់ក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍អាស៊ីឈ្មោះ *អភិបាលកិច្ច : ការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ដ៏ត្រឹមត្រូវ* កត់សម្គាល់ថា ផលប៉ះពាល់សរុបបណ្តាលពីការទទួលប្រាក់បៀវត្សរ៍ទាប សីលធម៌ក្នុងវិជ្ជាជីវៈនិងផលិតភាពការងារទាប ភាពមិនច្បាស់លាស់នៃការវិវត្តន៍អាជីពទៅអនាគត និងភាពទន់ខ្សោយ នៃប្រព័ន្ធដំឡើងមុខតំណែងមន្ត្រីដែលផ្អែកលើគុណភាពការងារ ជាប្រការដែលធ្វើឱ្យកើនឡើងនូវផលអវិជ្ជមាននៃអំពើពុករលួយ ក្នុងចំណោមមន្ត្រី នៃស្ថាប័នសាធារណៈ ។

៤២. ធនាគារអភិវឌ្ឍន៍អាស៊ីអាចជួយទ្រទ្រង់គំនិតផ្តួចផ្តើមមួយចំនួនដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ បណ្តាវិធានការដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រង និងការត្រួតពិនិត្យតួនាទីនៃមន្ត្រីក្នុងស្ថាប័នស៊ីវិល នឹងជួយធានាថាពុំមាន "មន្ត្រីខ្មោច" នៅក្នុងបញ្ជីទទួលប្រាក់បៀវត្សរ៍ឡើយ ។ កិច្ចខិតខំ ប្រឹងប្រែងកែលម្អកាំប្រាក់បៀវត្សរ៍ រួមនឹងការលើកកម្ពស់លក្ខខណ្ឌការងារ នឹងជួយកាត់បន្ថយទម្លាប់ និងឥរិយាបទនៃការប្រព្រឹត្តិខុសច្បាប់ ។ បណ្តាគំនិតផ្តួចផ្តើមដើម្បីកាត់បន្ថយករណីលើកលែង និងប្រាក់ឧបត្ថម្ភពិសេស នឹងធ្វើឱ្យប្រព័ន្ធប្រាក់បៀវត្សរ៍មានតម្លាភាពជាងមុន ។ បណ្តាវិធានការកែលម្អ នីតិវិធីជ្រើសរើសមន្ត្រី និងការដំឡើងមុខតំណែងគួរតែប្រព្រឹត្តទៅដោយប្រាសចាកបទរំលោភពីថ្នាក់លើបក្សពួកនិយម និងការយោគយល់ និងជួយជំរុញការបង្កើតស្ថាប័នស៊ីវិលឯករាជ្យមួយ ប្រកបដោយប្រព័ន្ធចាត់តាំងដែលផ្អែកលើសមត្ថភាព និងស្នាដៃ ។ កិច្ចប្រឹងប្រែងធ្វើសេចក្តីព្រាង និងដាក់ឱ្យអនុវត្តក្រមសីលធម៌ នឹងបង្ហាញឱ្យឃើញនូវការរំពឹងទុករបស់មន្ត្រីស៊ីវិល ព្រមទាំងធានាឱ្យមានការប្រកាន់ខ្ជាប់នូវនិយាមនៃឥរិយាបទដែលសមស្រប ។

៤៣. ជាចុងក្រោយ វិធីមួយផ្សេងទៀតដែលអាចជួយលើកកម្ពស់គុណភាព និងប្រសិទ្ធភាពស្ថាប័នសាធារណៈផង និងអាចជួយកាត់បន្ថយឱកាសនៃការប្រព្រឹត្តិអំពើពុករលួយផងនោះ គឺការបង្រួមវិសាលភាពនៃអន្តរាគមន៍របស់វា ។ នៅក្នុងក្រសួង ស្ថាប័ន និងនាយកដ្ឋាន វិធីដោះស្រាយដ៏ប្រសើរបំផុតមួយគឺការរៀបចំចាត់ចែងឡើងវិញនូវរបៀបដំណើរការក្នុងការងាររបស់ស្ថាប័ននោះ ។ នៅពេលដែលនីតិវិធីនៃការប្រតិបត្តិត្រូវបានកែលម្អ និងមានភាពងាយស្រួលជាងមុន ភាពចាំបាច់ឱ្យបង់ប្រាក់ដើម្បីជួយសម្រួលកិច្ចការរដ្ឋបាលក៏នឹងត្រូវបំបាត់ផងដែរ ។ ក្នុងក្របខ័ណ្ឌនយោបាយទូលាយ ការលុបចោលបទបញ្ជា

---

២៤ Daniel Kaufmann and Paul Siegelbaum. 1996. "Privatization and Corruption in Transition Economies." *Journal of International Affairs* 50 (2): 419–458.

ពាណិជ្ជភាវូបនីយកម្ម និងឯកជនភាវូបនីយកម្ម អាចសម្រេចបាននូវគោលបំណងប្រហាក់ប្រហែលគ្នានេះដែរ ។ នៅពេលដែលវិស័យដែលរដ្ឋលូកដៃចូលធ្វើអន្តរាគមន៍កាន់តែថយចុះ ជាទូទៅឱកាសនៃការទាមទារឱ្យបង់ប្រាក់សំណូកក៏ នឹងថយចុះផងដែរ ។

៤៤. ការផ្តួចផ្តើមគំនិតមួយចំនួនអំពី "អភិបាលកិច្ចល្អ" ពាក់ព័ន្ធនឹងស្ថាប័ននីតិប្រតិបត្តិ និងតុលាការ ក៏អាចជួយប្រឆាំងអំពើពុករលួយផងដែរ ។ មធ្យោបាយសំខាន់មួយដើម្បីលើកស្ទួយការទទួលខុសត្រូវ គឺត្រូវពង្រឹងតួនាទីរបស់សភាក្នុងការត្រួតពិនិត្យ និងកែលម្អសមត្ថភាពបណ្តាស្ថាប័នសភា ដូចជាស្ថាប័នសវនកម្មកំពូលជាដើម ឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព ។ បណ្តាវិធានការកែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ ដូចជា ការកាត់បន្ថយភាពកកស្ទះនៃការងារតុលាការ តាមរយៈការប្រើវិធីផ្សេងទៀតសម្រាប់ដោះស្រាយទំនាស់ ឬការលើកកម្ពស់ការគ្រប់គ្រងសាលា ជំនុំជំរះក្តីដើម្បីធានាថាបណ្តឹករណើនៃពាក្យបណ្តឹងត្រូវទទួលការជំនុំជំរះតាមពេលវេលាកំណត់ ឬការលើកកម្ពស់ឯករាជ្យភាពនិងវិជ្ជាជីវៈនៃតុលាការ ជាដើម អាចនឹងនាំមកនូវកត្តាខាងក្រៅវិជ្ជមានជាបន្ថែមនៅក្នុងការប្រឆាំងនឹងអំពើពុករលួយ ។កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពខ្វះចន្លោះនៅ ក្នុងមុខជំនាញសំខាន់ៗ ដូចជាផ្នែកសវនកម្ម និងគណនេយ្យជាដើម ក៏អាចនឹងនាំមកនូវប្រសិទ្ធភាពស្រដៀងគ្នាដែរ ។

៤៥. បណ្តាកិច្ចផ្តួចផ្តើមទាំងអស់នេះមិនបង្កឱ្យមានវាទប្បដិវាទឡើយ ហើយត្រូវបានទទួលស្គាល់ជាទូទៅថា ជាមូលដ្ឋានដ៏សំខាន់ សម្រាប់ការគ្រប់គ្រងស្ថាប័នសាធារណៈដ៏រឹងមាំ។ បច្ចុប្បន្ន ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងតែដាក់ឱ្យអនុវត្តបណ្តាវិធានការមួយចំនួនក្នុងក្របខ័ណ្ឌនៃកម្មវិធីប្រាក់កម្ចី និងជំនួយបច្ចេកទេស ( ប្រអប់ទី ៣) ។ កម្មវិធីទាំងនេះនឹងជួយជាមូលដ្ឋានក្នុងកិច្ចប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីប្រឆាំង នឹងអំពើពុករលួយដែលជាផ្នែកមួយនៃកម្មវិធីទូលាយរបស់ខ្លួនក្នុងការពង្រឹងអភិបាលកិច្ច និងការកសាងសមត្ថភាព ។

## ប្រអប់ទី ៣ : ឧទាហរណ៍ស្តីពីការផ្តល់ប្រាក់ឥណទាន និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់កម្មវិធីអភិបាលកិច្ចល្អ ដោយមានសមាសភាគប្រឆាំងអំពើពុករលួយ

**RETA 5688 : កម្មវិធីបណ្តុះបណ្តាលរយៈពេលវែងក្នុងតំបន់ស្តីពីសវនកម្ម សម្រាប់បណ្តាសមាជិកនៃអង្គការស្ថាប័នសវនកម្មកំពូលនៅអាស៊ី :** កិច្ចផ្តួចផ្តើមដែលមានតម្លៃ 1,0 លានដុល្លារនេះ បានទទួលការអនុម័តដោយក្រុមប្រឹក្សាភិបាល នៅខែ មិថុនា ឆ្នាំ 1996 ។ វាជាកម្មវិធីសម្រាប់រយៈពេលប្រាំឆ្នាំ ដើម្បីពង្រឹងកម្មវិធីបណ្តុះបណ្តាលប្រចាំតំបន់ សម្រាប់ស្ថាប័នសវនកម្មកំពូល និងដើម្បីលើកកម្ពស់ការបណ្តុះបណ្តាល ព្រមទាំងទេពកោសល្យក្នុងបច្ចេកទេសសវនកម្ម នៅក្នុងស្ថាប័នសវនកម្មនីមួយៗ ។

**TA 2186: ពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងរដ្ឋបាលទីចាត់ការគយ នៃសាធារណរដ្ឋប្រជាមានិតចិន :** កម្មវិធីជំនួយបច្ចេកទេសមានតម្លៃ ៦៤៦.000 ដុល្លារនេះ បានទទួលការអនុម័តដោយក្រុមប្រឹក្សាភិបាល នៅខែ តុលា ឆ្នាំ ១៩៩៤ ។ កម្មវិធីនេះមានគោលបំណងជួយអគ្គរដ្ឋបាលទីចាត់ការគយក្នុង : (i) ការលើកស្នើច្បាប់ និងបទបញ្ញត្តិថ្មីដែលមានប្រសិទ្ធភាពពាក់ព័ន្ធនឹងការត្រួតពិនិត្យសិទ្ធិលើទ្រព្យសម្បត្តិអន្តរជាតិនៅតាមព្រំដែន ការយកពន្ធគយ វិធានការប្រឆាំងអំពើគៃបន្លំក្នុងពាណិជ្ជកម្ម និងសវនកម្មឯករាជ្យ (ii) បង្កើតប្រព័ន្ធពត៌មានពាក់ព័ន្ធនឹងច្បាប់ និងបទបញ្ញត្តិ និង (iii) បណ្តុះបណ្តាលមន្ត្រីអគ្គរដ្ឋបាលទីចាត់ការគយ ដើម្បីអនុវត្តវិធានការទាំងនោះ ។

**TA 2616: ការកែទម្រង់រដ្ឋបាលសាធារណៈនៅប្រទេសស្រីលង្កា :** នៅខែកក្កដា ឆ្នាំ ១៩៩៦ ប្រធានធនាគារបានអនុម័តជំនួយឥតសំណងចំនួន ២៧៥,000 ដុល្លារ ដល់រដ្ឋាភិបាលប្រទេសស្រីលង្កា ដើម្បីជួយត្រឡប់ស្ថានការណ៍នៃការបន្តធ្លាក់ចុះខាងផ្នែកគុណភាព និងសមត្ថភាពស្ថាប័នសាធារណៈ ។ គោលដៅចម្បងពីរក្នុងចំណោមគោលដៅដទៃទៀតនៃការផ្តួចផ្តើមនេះ គឺដើម្បីធ្វើសនិទានកម្មក្របខ័ណ្ឌស្ថាប័នសាធារណៈនិងលើកកម្ពស់ការទទួលខុសត្រូវរបស់និយោជិករដ្ឋាភិបាលតាមរយៈ ការណែនាំឱ្យប្រើប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងដែលផ្អែកលើលទ្ធផលការងារ ។

**Loan 1513: ការទ្រទ្រង់កម្មវិធីកែទម្រង់ស្ថាប័នសាធារណៈ ក្នុងសាធារណរដ្ឋនៃកោះម៉ារសាល់ :** នៅខែ មករា ឆ្នាំ ១៩៩៧ ក្រុមប្រឹក្សាភិបាលបានអនុម័តប្រាក់កម្ចីចំនួន ១២ លានដុល្លារ ដើម្បីជួយទ្រទ្រង់ការអនុវត្តន៍កម្មវិធីកែទម្រង់ស្ថាប័នសាធារណៈ ដែលមានគោលបំណងធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមានស្ថេរភាព លើកកម្ពស់ប្រសិទ្ធភាពស្ថាប័នសាធារណៈ ព្រមទាំងលើកស្ទួយសមត្ថភាពរបស់ប្រទេសនេះក្នុងការផ្តល់និងបង្កបរិយាកាសប្រកបដើម្បីជំរុញការលូតលាស់វិស័យឯកជន ។ លក្ខខណ្ឌទីបីក្នុងកម្មវិធីឥណទាននេះផ្តោតលើការតាក់តែងនីតិវិធីផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម និងវិនិយោគបរទេសឱ្យមានតម្លាភាពជាងមុន និងដែលអាចព្យាករណ៍បាន ។ កម្មវិធីនេះ ក៏ជួយផងដែរដល់ការបង្កើតការិយាល័យស៊ើបអង្កេតបណ្តឹងដើម្បីធានាឱ្យមានមជ្ឈត្តកម្មឯករាជ្យ និងយុត្តិធម៌ ក្នុងការដោះស្រាយទំនាស់រវាងរដ្ឋាភិបាល និងសាធារណៈជនជាទូទៅ ។

## ខ. គោលបំណងទី ២: ទ្រទ្រង់កិច្ចប្រឹងប្រែងក្នុងការប្រឆាំងអំពើពុករលួយដែលអាចនឹងមានជោគជ័យតាមករណី ដោយឡែកនីមួយៗ និងលើកកម្ពស់គុណភាពនៃការពិភាក្សាអំពីបញ្ហាអភិបាលកិច្ច

៤៦. ធនាគារអភិវឌ្ឍន៍អាស៊ី ក៏អាចទទួលយកនូវការអំពាវនាវពីសំណាក់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក ឱ្យជួយទ្រទ្រង់ក្នុងកម្មវិធីប្រឆាំងអំពើពុករលួយដោយចំហផងដែរ ។ ជំនួយបែបនេះអាចរួមមាន កិច្ចប្រឹងប្រែងរៀបចំយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ បង្កើនសមត្ថភាពតុលាការក្នុងការជំរះក្តីពាក់ព័ន្ធនឹងអំពើពុករលួយ,ការឆ្លើយតបនឹងសំណើជំនួយផ្នែកច្បាប់ ឬជំនួយបច្ចេកទេសពីសំណាក់អ្នកច្បាប់ និងមន្ត្រីរដ្ឋាភិបាលក្នុងការធ្វើសេចក្តីព្រាងលក្ខន្តិកៈប្រឆាំងអំពើពុករលួយ ឬក្រមប្រតិបត្តិក្នុងវិជ្ជាជីវៈ ការពង្រឹងយន្តការច្បាប់សម្រាប់ត្រួតពិនិត្យសកម្មភាពរដ្ឋបាល (ឧទាហរណ៍ការបង្កើតក្រុមអធិការកិច្ច ឬលក្ខខណ្ឌសម្រាប់ត្រួតពិនិត្យប្រព័ន្ធតុលាការ) ឬការកែលម្អសមត្ថភាពស្ថាប័នប្រឆាំងអំពើពុករលួយក្នុងការស៊ើបអង្កេត ឬជំរះក្តីករណីនៃការប្រព្រឹត្តិតិរិយាបទខុសច្បាប់ ។

៤៧. ធនាគារអភិវឌ្ឍន៍អាស៊ីនឹងពិចារណាដោយប្រុងប្រយ័ត្ន ចំពោះសំណើសុំជំនួយបង្កើតយន្តការប្រឆាំងអំពើពុករលួយពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ។ ដោយសារសកម្មភាពទាំងនេះទំនងជាមានសភាពផុយស្រួយខាងផ្នែកនយោបាយ និងត្រូវការពតិមានលម្អិតស្តីពីស្ថានភាពជាក់លាក់ជុំវិញករណីនីមួយៗ នោះធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់បុគ្គលិកដែលធ្វើការដោយប្រុងប្រយ័ត្ន និងបត់បែនតាមស្ថានការណ៍ជាក់ស្តែងក្នុងការអនុវត្តន៍គំនិតផ្តួចផ្តើមបែបនេះ ដោយផ្អែកលើមូលដ្ឋាននៃករណីនីមួយៗដោយឡែកពីគ្នា ។ ជំនួយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវតែអនុវត្តតាមគោលការណ៍បីដូចខាងក្រោម : (i) ជំនួយអន្តរាគមន៍ពីធនាគារអភិវឌ្ឍន៍អាស៊ីត្រូវមានការស្នើសុំពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក (ii) សំណើសុំអន្តរាគមន៍នោះត្រូវតែស្របនឹងយុទ្ធ-សាស្ត្រប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ប្រទេសនោះ និងស្របគ្នាជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដែលកំពុងអនុវត្តក្នុងផ្នែកអភិបាលកិច្ច និងកសាងសមត្ថភាពបច្ចេកទេស និង (iii) សំណើនេះត្រូវតែស្ថិត ក្នុងវិស័យដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចផ្តល់ ឬមានជំនាញគ្រប់គ្រាន់ ។

៤៨. តាមរូបភាពដូចគ្នានេះដែរ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងពិចារណាជួយទ្រទ្រង់ការខំប្រឹងប្រែងប្រឆាំងអំពើពុករលួយក្នុងតំបន់ តាមរយៈសិក្ខាសាលា កិច្ចប្រជុំ សកម្មភាពបណ្តុះបណ្តាល ការស្រាវជ្រាវនិងបោះពុម្ពផ្សាយទាក់ទងនឹងបញ្ហាអំពើពុករលួយ និងលទ្ធភាពធ្វើសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដែលមានបេសកកម្ម និងកម្មវិធីការងារក្នុងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមនេះ ។

៤៩. បុគ្គលិកធនាគារគួរតែមានការប្រុងប្រយ័ត្នក្នុងការឆ្លើយតបទៅនឹងកិច្ចផ្តួចផ្តើមមួយចំនួន ដែលស្ថិតនៅក្រៅវង្វង់សមត្ថកិច្ចនៃការចូលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ការងារទាំងនោះរួមមាន កិច្ចប្រឹងប្រែងជំរុញឱ្យមានការជជែកវែកញែកក្នុងស្រុក នៅក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ឬគំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយ កម្មវិធីប្រឆាំងអំពើ ពុករលួយដែលមានចរិតនយោបាយខ្លាំងពេក និងដែលផ្តោតលើបុគ្គលឬគណៈបក្ស នយោបាយណាមួយ និងគំនិតផ្តួចផ្តើមដែលគ្រាន់តែបង្ហាញឱ្យឃើញតែរូបភាពក្រៅ ហើយត្រូវរៀបចំឡើងសម្រាប់គ្រាន់តែបំភាន់ជារូបភាពថាមានការរីកចំរើន តែពុំមានខ្លឹមសារពិតប្រាកដ ។ ធនាគារអភិវឌ្ឍន៍អាស៊ីមិនត្រូវផ្តល់ជំនួយចំពោះវិធានការប្រឆាំងអំពើពុករលួយណាឡើយ ប្រសិនបើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកពុំយល់ពីធម្មជាតិ វិសាលភាព និងសារៈសំខាន់នៃកិច្ចការផ្តួចផ្តើមទាំងនោះ ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមនៃបណ្តាប្រទេសទាំងនោះ ។

៥០. ធនាគារអភិវឌ្ឍន៍អាស៊ី មានយន្តការមួយចំនួនសម្រាប់ធ្វើការចរចាជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិកអំពីបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ច (រួមទាំងអំពើពុករលួយ) ដែលរួមមាន យុទ្ធសាស្ត្រប្រតិបត្តិសម្រាប់បណ្តាប្រទេសក្នុងតំបន់ និងការពិភាក្សាកម្មវិធីជំនួយសម្រាប់បណ្តាប្រទេសបេសកកម្ម វាយតម្លៃកម្មវិធីរួមនៅក្នុងប្រទេស ការវាយតម្លៃសំណើគម្រោង ការអនុវត្តគម្រោង និងបេសកកម្មវាយតម្លៃគម្រោង ។ បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី ដែលទទួលបន្ទុកយុទ្ធសាស្ត្រសម្រាប់ប្រទេសនីមួយៗ និងទទួលបន្ទុករៀបចំកម្មវិធី រួមទាំងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រប្រតិបត្តិសម្រាប់ប្រទេស និងឯកសារកម្មវិធីជំនួយសម្រាប់ប្រទេស ក៏ដូចជាបុគ្គលិកទទួលបន្ទុកផ្នែកគម្រោងឥណទាន ឬជំនួយឥតសំណងត្រូវតែដោះស្រាយនូវបញ្ហាទាក់ទងនឹងអំពើពុករលួយក្នុងបរិបទដ៏ទូលំទូលាយនៃបញ្ហាអភិបាលកិច្ច និងការកសាងសមត្ថភាពបច្ចេកទេស ។ ពួកគេគួរតែយល់អំពីបញ្ហាអំពើពុករលួយ និងផលវិបាករបស់វានៅក្នុងភូមិសាស្ត្រ និង/ឬតាមវិស័យដែលពួកគេទទួលបន្ទុកការងារ ។ ពួកគេត្រូវប្រើយន្តការនេះដើម្បីពិភាក្សា និងលើកសំណើវិធីសាស្ត្រ ដែលអាចឱ្យធនាគារអភិវឌ្ឍន៍អាស៊ីជួយអនុវត្តគោលការណ៍សម្រាប់គ្រប់គ្រងការអភិវឌ្ឍឱ្យបានត្រឹមត្រូវ រួមទាំងវិធានការដែលអាចជួយប្រឆាំងអំពើពុករលួយនៅក្នុងបណ្តាប្រទេស ដែលអំពើពុករលួយជះឥទ្ធិពលអវិជ្ជមានដល់បណ្តាគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងដល់សេចក្តីសង្ឃឹមរួមរបស់ប្រទេស ក្នុងការធ្វើឱ្យមានកំនើនសេដ្ឋកិច្ច ។

៥១. បេសកកម្មវាយតម្លៃកម្មវិធីប្រចាំប្រទេស និងបេសកកម្មវាយតម្លៃគម្រោង ផ្តល់នូវឱកាសសម្រាប់ពិភាក្សាអំពីគោលនយោបាយ និងការអនុវត្តនានា ដែលជាកត្តាបង្អាក់ដំណើរនៃការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ក្នុងកាលៈទេសៈ ភាគច្រើន

នៅពេលបុគ្គលិកសង្ស័យថាមានអំពើពុករលួយកើតមានរួចមកហើយ ឬកំពុងតែកើតមាននៅក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គេត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងវាក្យខ័ណ្ឌ ៦៤ នៃឯកសារនេះ និងត្រូវធ្វើសេចក្តីរាយការណ៍អំពីបញ្ហានេះទៅការិយាល័យអគ្គសវនករ ដែលនឹងចាត់វិធានការដោះស្រាយឱ្យបានសមស្របទៅតាមស្ថានភាពនៃបញ្ហា ។ ក្នុងករណីកម្រខ្លះ នៅពេលដែលត្រូវការឱ្យមានចំណាត់វិធានការចាំបាច់ជាបន្ទាន់ បុគ្គលិករូបនោះអាចដោះស្រាយបញ្ហាទាំងនោះដោយចំហជាមួយស្ថាប័នពាក់ព័ន្ធជាមួយស្ថាប័នប្រតិបត្តិ ឬជាមួយស្ថាប័នទទួលបន្ទុកស្រាវជ្រាវករណីបែបនេះ បន្ទាប់ពីបានទទួលការអនុញ្ញាតពីនាយករបស់គេនិងពីការិយាល័យអគ្គក្រុមប្រឹក្សា ។ ប៉ុន្តែរាល់ការពិភាក្សាជាមួយ ក្រុមហ៊ុន ឬស្ថាប័នណាមួយក្នុងរដ្ឋាភិបាល ត្រូវតែផ្តោតតែលើបញ្ហាពាក់ព័ន្ធនឹងការងារប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីតែប៉ុណ្ណោះ ។

៥២. ដោយឱ្យមានការស៊ីសង្វាក់គ្នាជាមួយ *គោលការណ៍ណែនាំស្តីពីការផ្សព្វផ្សាយពត៌មាន* របស់ធនាគារអភិវឌ្ឍន៍អាស៊ី អគ្គនាយក អគ្គនាយករង និងបណ្ណាប្រធានការិយាល័យ ឬនាយកដ្ឋាន អាចជំរាបជូនអ្នកយកពត៌មានអំពីបញ្ហាអំពើពុករលួយតាមការយល់ឃើញ ផ្ទាល់ខ្លួនថាជាការចាំបាច់ក្នុងក្របខ័ណ្ឌនៃក្រមប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ បុគ្គលិកផ្សេងទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានសេរីភាពពេញលេញក្នុងការពិភាក្សាបញ្ហាអំពើពុករលួយក្នុងន័យទូទៅដោយត្រូវអនុលោមទៅតាមនីតិវិធីដែលមានចែងក្នុង *គោលការណ៍ណែនាំស្តីពីការផ្សព្វផ្សាយពត៌មាន* ។ ប៉ុន្តែពួកគេមិនត្រូវនិយាយទៅកាន់អ្នកយកពត៌មានអំពីករណីជាក់លាក់ណាមួយនៃអំពើពុករលួយ ក្នុងចំណោមអ្នកផ្តត់ផ្គង់ដល់ធនាគារអភិវឌ្ឍន៍អាស៊ី ឬក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ឬអំពីកម្រិតទូទៅនៃអំពើពុករលួយនៅក្នុងក្រុមហ៊ុន ឬប្រទេសណាមួយ ដោយពុំមានការអនុញ្ញាតពីអគ្គនាយករង ដែលទទួលបន្ទុកកិច្ចការផ្តល់ពត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬនៅពេលអវត្តមានរបស់គាត់ឡើយ ។

## គ. គោលបំណងទី ៣ : ធានាថាបណ្តាគម្រោង និងបុគ្គលិកបម្រើការក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គោរពតាមបទដ្ឋានក្រមសីលធមិការងារខ្ពស់បំផុត

៥៣. ប្រសិនបើការព្យាយាមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការកាត់បន្ថយឥរិយាបទនៃទម្លាប់ខុសច្បាប់ក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការ ត្រូវតែអាចឱ្យជឿបាននោះប្រការចាំបាច់គឺត្រូវធានាថារាល់បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីអនុវត្តឱ្យបានត្រឹមត្រូវឥតខ្ចោះទៅតាមគោលការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ឯបទបញ្ជាផ្ទៃក្នុង និងនីតិវិធីនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវតែផ្អែកលើស្តង់ដានៃក្រមសីលធមិក្នុងកម្រិតខ្ពស់បំផុត ។ ក្នុងន័យនេះ មូលដ្ឋានគ្រឹះទីបីនៃនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រឆាំងអំពើពុករលួយអំពាវនាវឱ្យចាត់វិធានការផ្ទៃក្នុងយ៉ាងតឹងតែងបំផុត ដើម្បីពង្រឹងគោលការណ៍ប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឱ្យបានពេញលេញ ផ្អែកលើមូលដ្ឋានសំខាន់ៗប្រាំ គឺ : (i) រក្សានូវភាពសុចរិតនៃប្រតិបត្តិការកម្មវិធីឥណទាន និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ii) ពង្រឹងគោលនយោបាយលទ្ធកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (iii) កែលម្អជាប្រចាំនូវក្រមបែបបទការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងបង្កើតយន្តការឯករាជ្យសម្រាប់ធ្វើរបាយការណ៍ផ្ទៃក្នុង ដើម្បីដោះស្រាយការចោទប្រកាន់ស្តីពីអំពើពុករលួយក្នុងចំណោមមន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី ឬនៅក្នុងការងារប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (iv) លើកកម្ពស់គុណភាពនៃការត្រួតពិនិត្យកម្មវិធីឥណទាន និងជំនួយបច្ចេកទេស និងជំនួយបច្ចេកទេសផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី និង (v) ធានាថា បុគ្គលិកទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី មានការយល់ដឹងច្បាស់លាស់អំពីគោលនយោបាយប្រឆាំងអំពើពុករលួយ និងប្រកាន់ឥរិយាបទស្របទៅតាមអត្ថបទជាលាយលក្ខណ៍អក្សរនិងស្មារតីនៃគោលនយោបាយ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

### 1. រក្សានូវភាពសុចរិតនៃប្រតិបត្តិការកម្មវិធីឥណទាន និងជំនួយបច្ចេកទេស របស់ធនាគារអភិវឌ្ឍន៍

៥៤. ប្រសិនបើមានភ័ស្តុតាងយកជាការបាន ទាក់ទងនឹងអំពើពុករលួយនៅក្នុងកម្មវិធីឥណទាន ឬជំនួយបច្ចេកទេសដែលផ្តល់ហិរញ្ញវត្ថុ ដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារនេះនឹងដោះស្រាយបញ្ហានេះតាមរយៈការចរចាជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ក្នុងអំឡុងពេលបេសកកម្មពិនិត្យគម្រោង ឬបេសកកម្មពិនិត្យកម្មវិធីប្រចាំប្រទេស ។ ក្នុងករណីដែលរកឃើញថា មានអំពើរំលោភលើបទបញ្ជា ឬកិច្ចព្រមព្រៀងណាមួយក្នុងក្របខ័ណ្ឌឥណទាន ក្រុមប្រឹក្សាគ្រប់គ្រងនៃធនាគារអភិវឌ្ឍន៍អាស៊ីអាចនឹងធ្វើសេចក្តីសម្រេចបដិសេធជារៀងរហូតនូវក្រុមហ៊ុនដែលមានការពាក់ព័ន្ធ អាចពន្យាពេលការផ្តល់ហិរញ្ញវត្ថុ ឬលុបចោលគម្រោងឥណទាននោះ ។

៥៥. អនុលោមតាមក្រឹត្យក្រមការងាររបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ក្រុមប្រឹក្សាគ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងពិចារណាអំពីបញ្ហាអំពើពុករលួយដោយចំហនៅក្នុងការរៀបចំយុទ្ធសាស្ត្រប្រតិបត្តិការប្រចាំប្រទេស និងនៅក្នុងកម្មវិធីជំនួយដល់បណ្តាប្រទេសនានា ។ ករណីនៃអំពើពុករលួយមួយចំនួនអាចកើតមានឡើងក្នុងកម្រិតដែលអាចបង្កភាពរាំងស្ទះដល់សុចរិតភាព នៃការប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬនាំឱ្យគោលដៅអភិវឌ្ឍន៍ជាមូលដ្ឋាននៃបណាប្រទេសទទួលជំនួយមិនអាចសម្រេចទៅបាន ។ ក្នុងកាលៈទេសៈបែបនេះ ក្រុមប្រឹក្សាគ្រប់គ្រងអាចសម្រេច

តាមរយៈការបោះឆ្នោតដើម្បីកាត់បន្ថយ ឬពន្យារពេលការផ្តល់ឥណទាន និងជំនួយបច្ចេកទេសដល់ប្រទេសនោះ ក្រោយពេលបានពិភាក្សាជាមួយប្រទេសនោះ និងជាមួយក្រុមប្រឹក្សាភិបាល ។

៥៦. ម៉្យាងទៀត អាចមានស្ថានភាពផ្ទុយគ្នាពីករណីខាងលើ នៅពេលដែលប្រទេសណាមួយបានធ្វើឱ្យមានភាពជឿនលឿនជាក់លាក់ ក្នុងការលើកស្ទួយសមត្ថភាព ប្រសិទ្ធភាព និងភាពសុចរិតនៃស្ថាប័នសាធារណៈ និងឯកជន នៅក្នុងប្រទេសរបស់ខ្លួន ។ ក្នុងកាលៈទេសៈបែបនេះក្រុមប្រឹក្សាគ្រប់គ្រងអាចធ្វើសេចក្តីសម្រេច ក្នុងការសម្រួលឱ្យកម្មវិធីផ្តល់ឥណទានប្រព្រឹត្តទៅបានឆាប់រហ័ស ឬផ្តល់ធនធានជាបន្ថែមក្រោមរូបភាពជាជំនួយបច្ចេកទេស ដើម្បីជួយធានានិរន្តភាពនៃដំណើរការកែទម្រង់ ។

៥៧. ដោយសារអំពើពុករលួយមានសភាពស្មុគស្មាញ និងមានសណ្ឋានខុសប្លែកគ្នាជាខ្លាំង ក្រុមប្រឹក្សាគ្រប់គ្រង និងបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវមានគោលការណ៍បត់បែនបានក្នុងកម្រិតសមស្របមួយ ដើម្បីអាចដោះស្រាយករណីដោយឡែកៗពីគ្នានៃអំពើពុករលួយដោយរក្សាបាន នូវការគោរពតាមក្របខ័ណ្ឌនៃខសំខាន់ៗ ដែលមានចែងនៅក្នុងគោលនយោបាយនេះ ។ ដោយទទួលស្គាល់អំពីតម្រូវការខាងផ្នែកយុត្តិធម៌ និង ភាពស៊ីសង្វាក់គ្នានៅក្នុងកិច្ចប្រតិបត្តិការ និងដោយអះអាងយ៉ាងដាច់អហង្ការចំពោះភាពចាំបាច់នៃនយោបាយ "គ្មានការយោគយល់" នៅពេលដែលមានភស្តុតាងយកជាការបានដែលបង្ហាញថា មានអំពើពុករលួយនៅក្នុងចំណោមបុគ្គលិក ឬគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារនេះកត់សម្គាល់ថា គេត្រូវចាត់វិធានការខុសៗពីគ្នាសម្រាប់ដោះស្រាយប្រភេទផ្សេងគ្នានៃអំពើពុករលួយ ។ គេចាំបាច់ត្រូវធ្វើការសម្រេចដោយប្រុងប្រយ័ត្នបំផុតដោយផ្អែកលើពតិមានច្បាស់លាស់ និងលក្ខណៈពិសេសនានានៃស្ថានភាព ។ កិច្ចប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការប្រឆាំងអំពើពុករលួយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការអនុវត្តន៍វិធានការជាក់ស្តែង និងវិធានការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន និងការពារជាមុន ដែលជាវិធានការត្រូវចំណាយតិចតែមានប្រសិទ្ធភាពទៅតាមទម្រង់ដែលស្របគ្នានឹងគោលការណ៍ធម្មនុញ្ញស្តីពី "សេដ្ឋកិច្ច និង សមិទ្ធិផល" ។

## 2. ការកែទម្រង់លទ្ធកម្ម

៥៨. នៅពេលថ្មីៗនេះ ក្រុមការងារប្រឆាំងអំពើពុករលួយ ដែលមានការិយាល័យសេវាកម្មប្រតិបត្តិកណ្តាលជាប្រធាន បានកោះប្រជុំដើម្បីត្រួតពិនិត្យឡើងវិញនូវគោលនយោបាយលទ្ធកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ក្រុមការងារនេះបានពិចារណាវិធានការប្រឆាំងអំពើពុករលួយផ្សេងៗ ដែលបានអនុម័តដោយធនាគារពិភពលោក នៅខែ កក្កដា ឆ្នាំ ១៩៩៦ ដែលក្នុងវិធានការទាំងនោះ មានការដាក់កំហិតឱ្យភាគីខ្ចីឥណទាន អ្នកចូលរួមដេញថ្លៃ អ្នកផ្គត់ផ្គង់និងអ្នកម៉ៅការ "គោរពតាមបទដ្ឋានក្រមសីលធម៌ការងារខ្ពស់បំផុត" នៅក្នុងពេលដេញថ្លៃនិងពេលអនុវត្តកិច្ចសន្យា[២៥] ។ ក្នុងដំណើរការអនុវត្តវិធានការនេះ ធនាគារពិភពលោកនឹង :

(i) បដិសេធសំណើផ្តល់កិច្ចសន្យា ប្រសិនបើធនាគារពិភពលោករកឃើញថា ក្រុមហ៊ុនដែលមានការស្នើឱ្យទទួលកិច្ចសន្យា ធ្លាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ឬអំពើគៃបន្លំ នៅក្នុងការដេញថ្លៃដើម្បីប្រកួតយកកិច្ចសន្យានោះ ។

(ii) លុបចោលចំណែកនៃឥណទានដែលបម្រុងទុកសម្រាប់កិច្ចសន្យាផ្តល់សំភារៈ ឬការងារ ប្រសិនបើនៅពេលណាមួយធនាគាររកឃើញថា បណ្តាអ្នកតំណាងឱ្យភាគីខ្ចីឥណទាន ឬអ្នកទទួលផលប្រយោជន៍ពីកម្មវិធីប្រាក់កម្ចី មានជាប់ពាក់ព័ន្ធជាមួយអំពើពុករលួយ និងគៃបន្លំនៅក្នុងដំណើរការដេញថ្លៃ ឬនៅក្នុងដំណើរការប្រតិបត្តិកិច្ចសន្យានោះ ប្រសិនបើភាគីខ្ចីឥណទានមិនបានចាត់វិធានការសមស្របសម្រាប់កែខៃស្ថានភាពនោះឱ្យបានទាន់ពេល និងដែលអាចធនាគារពិភពលោកទទួលយកបាន ។

(iii) ប្រកាសយ៉ាងដាច់អហង្ការ នូវការដកហូតសិទ្ធិជារៀងរហូត ឬសម្រាប់ចន្លោះពេលណាមួយជាកំណត់ក្នុងការទទួលកិច្ចសន្យាផ្តល់ហិរញ្ញវត្ថុដោយធនាគារពិភពលោក ប្រសិនបើនៅពេលណាក៏ដោយធនាគារពិភពលោករកឃើញថា ក្រុមហ៊ុននោះមានពាក់ព័ន្ធនឹងអំពើពុករលួយ ឬគៃបន្លំ នៅក្នុងការប្រជែងដេញថ្លៃ ឬក្នុងពេលប្រតិបត្តិកិច្ចសន្យា ដែលផ្តល់ហិរញ្ញវត្ថុ ដោយធនាគារពិភពលោក ។ និង

(iv) មានសិទ្ធិទាមទារឱ្យចែងនៅក្នុងកិច្ចសន្យា ដែលផ្តល់ឥណទានហិរញ្ញវត្ថុដោយធនាគារពិភពលោក នូវខដែលតម្រូវឱ្យក្រុមហ៊ុនផ្គត់ផ្គង់ និងភាគីម៉ៅការអនុញ្ញាតឱ្យធនាគារពិភពលោកត្រួតពិនិត្យលើគណនេយ្យ និងរាល់កំណត់បញ្ជីទាក់ទងនឹងការអនុវត្តកិច្ចសន្យាព្រមទាំងធ្វើសវនកម្មលើគណនេយ្យ និងបញ្ជីទាំងនោះដោយសវនករដែលជ្រើសរើសដោយធនាគារពិភពលោក ។

៥៩. បណ្តាខប្រហែលគ្នានេះក៏មានដាក់បញ្ចូលក្នុង *គោលការណ៍ណែនាំសម្រាប់ការជ្រើសរើស* និង*ជួលទីប្រឹក្សា* របស់ធនាគារពិភពលោក ផងដែរ ។ នៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ក្រុមប្រឹក្សាភិបាលធនាគារពិភពលោកបានឯកភាពធ្វើវិសោធនកម្មលើគោលការណ៍ណែនាំស្តីពីលទ្ធកម្ម ដើម្បីធានាឱ្យមានចុះ "ការសន្យាគ្មានសំណូក" នៅក្នុងពាក្យសុំដេញថ្លៃ ដែលអាចដាក់បញ្ចូលទៅក្នុងគម្រោងការដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារពិភពលោកតាមការស្នើសុំរបស់ភាគីខ្ចីឥណទាន និងដាក់ជាកាតព្វកិច្ចសម្រាប់បណ្តាក្រុមហ៊ុនឱ្យគោរពតាមច្បាប់ក្នុងស្រុក ដែលនៅជាធរមានពាក់ព័ន្ធ នឹងការសូកប៉ាន់មន្ត្រីរដ្ឋាភិបាល ។

[២៥] R96-112/1: សំណើវិសោធនកម្មក្នុងឯកសារផ្តល់ប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សំដៅធ្វើឱ្យឯកសារទាំងនោះមានប្រសិទ្ធភាពក្នុងការប្រឆាំងអំពើគៃបន្លំ និងអំពើពុករលួយ ធនាគារអន្តរជាតិសម្រាប់ការស្តារ និងអភិវឌ្ឍន៍ ថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1996 ។

៦០. ក្រុមការងារបានពិចារណាលើបណ្តាវិធានការទាំងនេះ និងវិធានការផ្សេងៗទៀត ដោយមានការពិភាក្សាជាមួយក្រុមប្រឹក្សាគ្រប់គ្រង ធនាគារ ។ យោងតាមអនុសាសន៍ផ្តល់ដោយក្រុមបណ្តាប្រទេសឧស្សាហកម្មទាំងប្រាំពីរ និងដោយពិចារណាផងដែរអំពីផលប្រយោជន៍នៃការធ្វើឱ្យការប្រតិបត្តិមានភាពចុះសំរុងគ្នារវាងធនាគារអភិវឌ្ឍន៍ពហុភាគីទាក់ទងនឹងលទ្ធកម្ម និងការជ្រើសរើសទីប្រឹក្សា ធនាគារអភិវឌ្ឍន៍អាស៊ីនឹងដាក់បញ្ចូលបណ្តាខដែលចែងពីវិធានការប្រឆាំងអំពើពុករលួយឱ្យមានប្រសិទ្ធភាពប្រហាក់ប្រហែលនឹងបណ្តាខដែលអនុម័តដោយធនាគារពិភព-លោកដែរ សម្រាប់ការពិចារណាបដិសេធសំណើគម្រោង ការប្រកាសដកហូតសិទ្ធិ និងសិទ្ធិធ្វើអធិការកិច្ច ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៥៨ ។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏នឹងដាក់បញ្ចូលជំរើស "ការសន្យាគ្មានសំណូក" ទៅក្នុងពាក្យសុំដេញថ្លៃ ដែលមានទម្រង់ប្រហាក់ប្រហែលនឹងគោលការណ៍របស់ធនាគារពិភពលោកដែរ ។ បន្ទាប់ពីក្រុមប្រឹក្សាភិបាលអនុម័តលើឯកសារគោលនយោបាយប្រឆាំងអំពើពុករលួយ រាល់សំណើផ្លាស់ប្តូរនឹងដាក់បញ្ចូលជាបន្ថែមទៅក្នុង *គោលការណ៍ណែនាំស្តីពីលទ្ធកម្ម* និង *គោលការណ៍ណែនាំស្តីពីការជួលទីប្រឹក្សាដោយធនាគារអភិវឌ្ឍន៍អាស៊ី និងភាគីខ្ចីឥណទានពីធនាគារនេះ* ហើយនឹងដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីសុំការអនុម័ត ។ អត្ថបទស្តីពីសំណើកែប្រែមានចែងក្នុងឧបសម្ព័ន្ធ ២ ។ បន្ទាប់មក គោលការណ៍ទាំងនេះនឹងមានភ្ជាប់ជាមួយបណ្តាខនានា ដែលមានចែងក្នុង *បទបញ្ជាខ្ចីឥណទាន* របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលជាការបើកឱកាសឱ្យធនាគារអភិវឌ្ឍន៍អាស៊ីអាចលុបចោលគម្រោងខ្ចីឥណទាន ក្នុងករណីមានភ័ស្តុតាងអំពីអំពើពុករលួយ ឬគៃបន្លំ ពាក់ព័ន្ធនឹងការផ្តល់កិច្ចសន្យា អនុវត្តគម្រោងដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី [២៦] ។ អត្ថបទសំណើកែប្រែមានចែងក្នុងឧបសម្ព័ន្ធ ៣ ។

៦១. បន្ថែមពីលើការដាក់បញ្ចូលវិធានការថ្មីៗទាំងនោះ គោលការណ៍បច្ចុប្បន្នរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវដាក់ឱ្យអនុវត្តយ៉ាងម៉ឹងម៉ាត់ និងជាយថាក្រម ដើម្បីធានាឱ្យមានយុត្តិធម៌ និងតម្លាភាពកម្រិតខ្ពស់នៅក្នុងដំណើរការលទ្ធកម្ម ។ ការយកចិត្តទុកដាក់ជាពិសេស នឹងផ្តោតជាសំខាន់លើការលុប បំបាត់ការពន្យារពេល និងសំណើសុំបន្តពេលនៅក្នុងដំនាក់កាលវាយតម្លៃលើជំនាញការវាយតម្លៃដំណើរការដេញថ្លៃ ការផ្តល់ កិច្ចសន្យា ការបង់ប្រាក់ជាមុន ការចាប់ផ្តើមគម្រោង និងនៅក្នុងការផ្ទេរប្រាក់តាមដំនាក់កាលនីមួយៗ ។ កិច្ចប្រឹងប្រែងជាងនេះទៀត នឹងផ្តោតលើការពិនិត្យពិច័យលើចំនួន និងកម្រិតនៃការកែប្រែចំនុចនានាក្នុងគម្រោងផ្សេងពីលំនាំដើម ដោយរួមមានការធ្វើសវនកម្មចោះៗ ក្នុងគោលបំណងធានាឱ្យមានការអនុវត្តបានត្រឹមត្រូវតាមបណ្តាសំណើទាំងនោះ ។ ក្នុងករណីដែលកិច្ចសន្យាត្រូវផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ទាំងស្រុង ឬដោយផ្នែកនៅក្នុងឯកសារកិច្ចសន្យាត្រូវមានដាក់បញ្ចូលការសន្យាដោយភាគីម៉ៅការថាពុំមានខ្ទង់ចំណាយជាប្រាក់កម្រៃប្រាក់ទឹកតែ ការបង្វិលប្រាក់សង អំណោយ កម្រៃជើងសារ ឬការចំណាយណាផ្សេងទៀតដែលពុំមានចែងក្នុងឯកសារដេញថ្លៃ នឹងត្រូវផ្តល់ឱ្យ ឬទទួលយក ពាក់ព័ន្ធជាមួយដំណើរការដេញថ្លៃ ឬក្នុងការប្រតិបត្តិកិច្ចសន្យាឡើយ ។

៦២. ពាក់ព័ន្ធនឹងកិច្ចការផ្នែកស្ថាប័នឯកជនរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បញ្ហាដេញថ្លៃច្រើនមានការពាក់ព័ន្ធនៅក្នុងការផ្តល់ ហិរញ្ញវត្ថុសម្រាប់បណ្តាគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធ ។អនុលោមតាមឯកសារការងារ *ការពិនិត្យឡើងវិញនូវដំណើរប្រតិបត្តិនៃស្ថាប័នឯកជន*រដ្ឋាភិបាលដែលជាអ្នកទទួលគម្រោង ត្រូវតែជ្រើសរើសអ្នកធានាអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដោយឈរលើគោលការណ៍តម្លាភាព តាមរយៈ ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែង ។ប្រសិនបើវាជាគម្រោងដែលមានការចរចាជាមុនការងារវិស្វកម្ម ការផ្តល់កិច្ចសន្យា និងការសាងសង់ ត្រូវ តែឆ្លងកាត់ការដេញថ្លៃ ជាលក្ខណៈប្រកួតប្រជែងជាចាំបាច់ ។

### 3. ការកែសម្រួលក្រុមការងារ និងបង្កើតយន្តការឯករាជ្យសម្រាប់រាយការណ៍ផ្ទៃក្នុង

៦៣. ឆ្លងតាមការពិគ្រោះយោបល់ជាមួយនាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង ការិយាល័យអគ្គក្រុមប្រឹក្សា បានធ្វើសេចក្តីព្រាងវិសោធនកម្មលើជំពូកទី ៤ នៃបទបញ្ជារដ្ឋបាលលេខ ២.0២ ដើម្បីបង្កើនវិសាលភាពនៃបទបញ្ជានេះសម្រាប់អនុវត្តចំពោះបញ្ហាពាក់ព័ន្ធនឹងចំណងទាក់ទងក្នុងមុខជំនួញ និងសកម្មភាពឯកជន ផលប្រយោជន៍ខាងផ្នែកហិរញ្ញវត្ថុ សកម្មភាពវិនិយោគ និងពាណិជ្ជកម្ម និងការបើកចំហឱ្យដឹងអំពីផ្នែកហិរញ្ញវត្ថុនិងផលប្រយោជន៍ក្នុងមុខជំនួញ ។គោលបំណងនៃការធ្វើវិសោធនកម្មនេះគឺដើម្បីការពារកុំឱ្យកើតមានទំនាស់ ឬការលេចឡើងជាសាធារ-ណៈនូវទំនាស់បែបនេះក្នុងចំណោមបុគ្គលិកពាក់ព័ន្ធនឹងផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួន ជាមួយមុខនាទីនិងការទទួលខុសត្រូវរបស់ពួកគេ។ នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ក្រុមប្រឹក្សាគ្រប់គ្រងបានអនុម័តគាំទ្រសំណើកែប្រែទាំងនេះ ហើយបច្ចុប្បន្ន ជំពូកទី ៤ បានក្លាយទៅជាក្រមអនុវត្តការងារយ៉ាងពេញលេញ សម្រាប់ឱ្យបុគ្គលិកទាំងអស់នៃធនាគារអភិវឌ្ឍន៍អាស៊ីប្រតិបត្តិតាម ។

៦៤. គេនៅត្រូវការបណ្តាវិធានការចាំបាច់បន្ថែមទៀតដើម្បីធានាថា គោលនយោបាយផ្ទៃក្នុង និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការដោះស្រាយបញ្ហាឥរិយាបទគៃបន្លំ និងអំពើពុករលួយមានភាពស៊ីសង្វាក់គ្នាជាមួយបណ្តាគោលការណ៍របស់ធនាគារអភិវឌ្ឍន៍ ពហុភាគីផ្សេងទៀត និងធានាឱ្យមានការវិវត្តន៍ទៅរកក្រឹត្យក្រមដែលល្អបំផុត ។ បច្ចុប្បន្ន នៅពុំទាន់មានខ្សែបណ្តាញឯករាជ្យណាមួយ ដែលអាចប្រើប្រាស់សម្រាប់រាយការណ៍ពីករណីនៃអំពើពុករលួយ និងឱ្យមានការស៊ើបអង្កេតករណីនោះនៅឡើយទេ ។ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយនេះ ការិយាល័យ អគ្គសវនករនឹងមាននាទីជាកន្លែងទទួលពាក្យបណ្តឹងផ្ទៃក្នុងទាក់ទងនឹងការគៃបន្លំ និងអំពើពុករលួយក្នុងចំណោមគម្រោង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ដោយការពិគ្រោះយោបល់ជាមួយការិយាល័យយុទ្ធសាស្ត្រនិងគោលនយោបាយ ការិយាល័យអគ្គក្រុមប្រឹក្សា នាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង ការិយាល័យប្រតិបត្តិសេវាកម្មកណ្តាល

---

[២៦] OGC 1986. *Ordimary Operation Loan Regulations*. ADB, Manila. OGC. 1982. *Special Operations Loan Regulations*. ADB, Manila.

និងនាយកដ្ឋានពាក់ព័ន្ធដទៃទៀតនោះ ការិយាល័យអគ្គសវនករ នឹងពិចារណា ចាត់វិធានការសមស្រប ក្នុងក្របខ័ណ្ឌនៃគោលនយោបាយខាងលើនេះ ដើម្បីធានាថា គ្រប់បុគ្គលិក និងគម្រោងនានា អនុវត្តតាមស្តង់ដានៃក្រមការងារកម្រិតខ្ពស់បំផុត ។

៦៥. ក្នុងករណីដែលបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី ឬភាគីខាងក្រៅនានា ពុំយល់ព្រមជាមួយនឹងលទ្ធផលនៃការរកឃើញរបស់ការិយាល័យអគ្គសវនករលើករណីណាមួយ នោះពួកគេអាចលើកករណីនេះទៅជូនក្រុមប្រឹក្សាគ្រប់គ្រងរបស់ធនាគារ ដែលនឹងធ្វើសេចក្តីសម្រេចថាតើករណីបែបនេះត្រូវដាក់ជូនទៅការិយាល័យអគ្គសវនករវិញដើម្បីឱ្យបន្តពិនិត្យឡើងវិញតទៅទៀត បញ្ជូនសំណុំរឿងទៅអ្នកស៊ើបអង្កេតឯករាជ្យ ឬ ក្រុមហ៊ុនសវនកម្មឬមួយ សម្រេចថាត្រូវបញ្ឈប់ ប្រសិនបើពិនិត្យឃើញថាពុំមានហេតុផលចាំបាច់ត្រូវចាត់វិធានការបន្តទៀត ។ សំណុំរឿងរងនៃករណីមួយចំនួនក៏អាចទទួលការពិនិត្យដោយគណៈកម្មាធិការអធិការកិច្ចផងដែរ ប្រសិនបើសំណុំរឿងរងនោះឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យសម្រាប់អធិការកិច្ច ដូចមានចែងក្នុងឯកសារស្តីពីការបង្កើតមុខនាទីអធិការកិច្ច និងក្នុងឯកសារស្តីពីនីតិវិធីអធិការកិច្ច ដែលអនុម័តដោយគណៈកម្មាធិការ អធិការកិច្ច នៅថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៩៦ [២៧] ។

4. **លើកកម្ពស់គុណភាពនៃការត្រួតពិនិត្យ**

៦៦. ធនាគារអភិវឌ្ឍន៍អាស៊ីនឹងចាត់វិធានការមួយចំនួន ដើម្បីលើកកម្ពស់គុណភាពតាមដាន និងសវនកម្ម សម្រាប់គម្រោងនានា ។ បណ្តាវិធានការទាំងនេះនឹងកែលម្អគុណភាព និងប្រសិទ្ធភាពជាទូទៅនៃគម្រោងការផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ ធ្វើរបៀបនេះ នឹងធានាបាននូវភាពសុចរិតនៃដំណើរប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធ្វើឱ្យឥរិយាបទក្លែងបន្លំ និងពុករលួយកាន់តែមានការលំបាកប្រព្រឹត្ត និងអាចងាយរកឃើញ នៅពេលមានករណីបែបនេះកើតឡើង ។

៦៧. សមត្ថភាពរបស់ការិយាល័យអគ្គសវនករនឹងត្រូវពង្រឹងជាបន្ថែម ដើម្បីឱ្យការិយាល័យនេះមានសមត្ថភាពដោះស្រាយបញ្ហាប្រឆាំងនឹងអំពើពុករលួយឱ្យមានប្រសិទ្ធភាព ។ ការបណ្តុះបណ្តាលជាពិសេសលើផ្នែកគណនេយ្យនីតិក្រម និងបច្ចេកទេសស៊ើបអង្កេតផ្សេងទៀត ក៏នឹងមានផ្តល់ជូនផងដែរ ហើយការបណ្តុះបណ្តាលបែបនេះនឹងត្រូវពង្រីកដល់បណ្តាអ្នកធ្វើវិភាគផ្នែកហិរញ្ញវត្ថុនិងមន្ត្រីអនុវត្តគម្រោងផងដែរ ។ធនាគារនឹងជួលបុគ្គលិកដែលមានជំនាញពិសេសនៅក្នុងវិស័យនេះបន្ថែមទៀត ។ ធនាគារនឹងបន្តកិច្ចខំប្រឹងប្រែងបច្ចុប្បន្នរបស់ការិយាល័យអគ្គសវនករ ដើម្បីកែសម្រួលទម្រង់បែបបទការងារផ្ទៃក្នុងក្នុងគោលបំណងផ្តល់ធនធានជាបន្ថែមទៀតសម្រាប់ធ្វើសវនកម្មនៃគម្រោង ក្នុងវិស័យដែលមានស្ថានភាពប្រថុយគ្រោះថ្នាក់ និងផលប៉ះពាល់ខ្ពស់ ។ ដោយសហការជាមួយស្ថាប័នសវនកម្មកំពូលនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ការិយាល័យអគ្គសវនកម្មក៏នឹងចាប់ផ្តើមធ្វើសវនកម្មដោយចោះៗ នៅក្នុងគម្រោងនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីពិនិត្យមើលការគោរពតាមបទបញ្ជាហិរញ្ញវត្ថុ និងការរីកចំរើនជារូបវ័ន្ត ។ ការិយាល័យអគ្គសវនករនឹងពង្រឹងការផ្លាស់ប្តូរពត៌មានជាមួយបណ្តាស្ថាប័នកំពូលនានាផ្នែកសវនកម្ម នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិកហើយរួមសហការជាមួយនាយកដ្ឋានផ្សេងទៀតនៃធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីដើរតួនាទីយ៉ាងសកម្មក្នុងការវាយតម្លៃអំពីសេចក្តីត្រូវការពង្រឹងសមត្ថភាពធ្វើសវនកម្មរបស់ស្ថាប័នទាំងនោះ ។ ការិយាល័យអគ្គសវនករក៏នឹងពិចារណាផងដែរអំពីមធ្យោបាយដែលអាចធ្វើឱ្យរបាយការណ៍សវនកម្មគម្រោងមានភាពងាយយល់ និង ងាយប្រើប្រាស់ សម្រាប់បុគ្គលិកផ្នែកប្រតិបត្តិ ។ ប្រសិទ្ធភាពនៃវិធានការទាំងនេះនឹងត្រូវទទួលការវាយតម្លៃឡើងវិញ ក្រោយពីដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំដំបូង ហើយកិច្ចការបន្ថែមនឹងត្រូវលើកយកមកពិចារណាតាមការចាំបាច់ ។

៦៨. នៅក្នុងបរិបទនៃបណ្តាអនុសាសន៍របស់ក្រុមការងារស្តីពីការលើកកម្ពស់គុណភាពគម្រោង ធនធានជាច្រើនត្រូវបានត្រៀមទុកជាបន្ថែមរួចហើយសម្រាប់ការងារចុះបំពេញបេសកកម្មរដ្ឋបាលត្រួតពិនិត្យគម្រោង ដោយគិតទាំងគុណភាព រយៈពេលចុះត្រួតពិនិត្យ និងភាពញឹកញាប់ នៃការចុះត្រួតពិនិត្យ [២៨] ។គេនឹងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការពង្រីកជំនាញបច្ចេកទេសនៃបេសកកម្មទាំងនេះ និងធានាថា បុគ្គលិកដែលចូលរួមក្នុងបេសកកម្ម សុទ្ធសឹងមានជំនាញសមស្រប ជាពិសេស លើផ្នែកហិរញ្ញវត្ថុ គ្រប់គ្រង និងគោលនយោបាយ ។ ទោះបីជាគេ មិនទំនងជាអាចពង្រឹងគុណភាពនៃការត្រួតពិនិត្យសម្រាប់គ្រប់គម្រោងទាំងអស់ក្តី ក៏គេនឹងផ្តល់ធនធានជាបន្ថែមទៀតសម្រាប់លើកកម្ពស់ ការត្រួតពិនិត្យបណ្តាគម្រោងដែលមានការប្រថុយប្រថានកម្រិតខ្ពស់ និងសម្រាប់បង្កើតកម្មវិធីធ្វើសវនកម្មដោយចោះៗលើគម្រោងខ្លះៗ ដើម្បី តាមដានការអនុវត្តគម្រោងទាំងនោះ [២៩] ។

៦៩. ជំពូកពាក់ព័ន្ធមួយចំនួនដែលមានចែងក្នុងឯកសារ *បទបញ្ជារដ្ឋបាលសម្រាប់គម្រោង* និង *សៀវភៅណែនាំអំពីការផ្តល់ប្រាក់កម្ចី* នឹងត្រូវកែសម្រួលនៅពេលខាងមុខនេះ ដើម្បីទាមទារឱ្យស្ថាប័នប្រតិបត្តិ ឬស្ថាប័នអនុវត្តគម្រោង ជ្រើសរើសគណនេយ្យករដែលមានសមត្ថភាពគ្រប់គ្រាន់ និងទាមទារឱ្យមានប្រព័ន្ធសម្រាប់គ្រប់គ្រងការងារផ្ទៃក្នុង និងប្រព័ន្ធគណនេយ្យរឹងមាំសម្រាប់គម្រោងការមុនពេលដែលធនាគារអភិវឌ្ឍន៍អាស៊ី អាចនឹងផ្តល់ឥណទានជូន ។ គេត្រូវពិចារណាលើការកំណត់យកបណ្តាសន្ទស្សន៍ប្រសិទ្ធភាពសមស្រប សម្រាប់ប្រើប្រាស់ក្នុងការតាមដានភាពជឿនលឿន នៃការអនុវត្តន៍គម្រោង និងការអនុវត្តន៍ផ្នែកហិរញ្ញវត្ថុជាទៀងទាត់ប្រចាំត្រីមាស ហើយគេត្រូវតែពន្យល់ពីហេតុផលនៃភាពខុសគ្នារវាងទង្វើក្នុងផែនការ និងទង្វើជាក់ស្តែង ។ គុណភាពនៃប្រព័ន្ធគ្រប់គ្រង

---

[២៧] Doc. R225-95, *Establishment of an Inspection Function.* 10 November 1995. ដោយសារអំពើពុករលួយ អាចនឹងកើតមាននៅក្នុងផ្នែកជាច្រើននៃការងារ (ដូចជា សវនកម្ម ឬការជ្រើសរើសទីប្រឹក្សា) ដែលស្ថិតនៅក្រៅអំណាចទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យនៃធនាគារអភិវឌ្ឍន៍អាស៊ី នោះបុគ្គលិកនានារំពឹងថានឹងមានករណីមួយចំនួន តូចប៉ុណ្ណោះដែលទំនងជាត្រូវបានគេលើកឡើងសម្រាប់ការពិចារណានៅក្នុងគណៈកម្មាធិការនេះ ។

ពត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវពង្រឹងជាបន្ថែម ដើម្បីផ្តល់ជូនដល់អ្នកគ្រប់គ្រង នូវព័ត៌មានទាន់ពេលវេលាសម្រាប់តាមដានដំណើរការនៃគម្រោង ការគ្រប់គ្រងឥណទាន និងពីស្ថានភាពនៃការប្រើប្រាស់ថវិកាសម្រាប់បេសកកម្ម ។

៧០. ក្នុងកាលៈទេសៈដែលមានភ័ស្តុតាងអាចទុកចិត្តបាន ដែលបង្ហាញថាមានសកម្មភាពពុករលួយ និងកែបន្លំ បន្ថយបង្អាក់ដល់ប្រសិទ្ធភាពនៃគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬធ្វើឱ្យអត្រាទាញចំនួលថយចុះ គេត្រូវកត់ត្រាបញ្ហានេះបានច្បាស់លាស់នៅក្នុងឯកសាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី រួមទាំងរបាយការណ៍ណែនាំយោបល់ចំពោះគម្រោង របាយការណ៍បញ្ចប់គម្រោង របាយការណ៍វាយតម្លៃគម្រោងរបាយការណ៍ អនុវត្តសវនកម្ម និងបណ្តាឯកសារពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យធនាគារអភិវឌ្ឍន៍អាស៊ីអាចពិចារណាចាត់វិធានការកែតម្រូវឱ្យបានសមស្រប ។ អ្នកគ្រប់គ្រង និងបុគ្គលិក គួរជៀសវាងការប្រើប្រាស់ពាក្យឱ្យគ្រាន់តែពិរោះ ឬមិនច្បាស់លាស់ ដែលបិទបាំងទិដ្ឋភាពជាក់ស្តែងនៃបញ្ហា[៣០] ។

## 5. ពង្រឹងការយល់ដឹងរបស់បុគ្គលិក

៧១. វិធានការទាំងនេះនឹងពុំមានប្រសិទ្ធភាពទេ ប្រសិនបើបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីមិនបានយល់ច្បាស់អំពីបណ្តាខនានាដែលមានចែងនៅក្នុងគោលនយោបាយប្រឆាំងអំពើពុករលួយ និងក្រមអនុវត្តការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬពុំបានអនុវត្តតាមគោលការណ៍ដែលមានចែងដោយសារការធ្វេសប្រហែសនៅក្នុងការបំពេញភារៈកិច្ចតាមមុខនាទីរបស់ពួកគេ ។ ទោះបីគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ពុំមានចេតនាដោយផ្ទាល់ក្នុងការធ្វើឱ្យបុគ្គលិករបស់ខ្លួនក្លាយទៅជា "មន្ត្រីនគរបាល" ឬធ្វើឱ្យគោលបំណងនៃការកាត់បន្ថយអំពើពុករលួយ មានឧត្តមភាពលើគោលដៅផ្សេងទៀតនៃការអភិវឌ្ឍក្តី ក៏គ្រប់នាយកដ្ឋាន និងបុគ្គលិកនៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី មានកាតព្វកិច្ចចាំបាច់ក្នុងការធានានូវភាពសុចរិតនៃកិច្ចប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរៀងៗខ្លួន ។ បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវតែយល់ដឹងឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃគោលនយោបាយនេះ និងគោលការណ៍ណែនាំសម្រាប់បុគ្គលិក ហើយត្រូវត្រៀមខ្លួនជាស្រេច ដើម្បីចាត់វិធានការសមស្របតាមការចាំបាច់ ។

៧២. ភាពសុចរិតនៃបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាទ្រព្យសម្បត្តិដ៏សំខាន់មួយរបស់ស្ថាប័ននេះ ហើយការរំលោភបំពានពីសំណាក់បុគ្គលិកធនាគារទៅលើក្រមនៃការប្រតិបត្តិ ឬគោលការណ៍ណែនាំដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវដោះស្រាយដោយវិធានការម៉ឺងម៉ាត់ជាទីបំផុត ។ រាល់ការចោទប្រកាន់ទាក់ទងនឹងឥរិយាបទនៃអំពើពុករលួយ ឬកែបន្លំដោយបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវដាក់ជូនទៅការិយាល័យអគ្គសវនករ ដែលនឹងសហការជាមួយនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀតនៃធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីធ្វើសេចក្តីសម្រេច ពីភាពទុកចិត្តបាននៃពាក្យចោទ និងអំពីភាពចាំបាច់នៃការស៊ើបអង្កេតជាបន្តទៀត ។ ការទាមទារដែលគួរឱ្យជឿទុកចិត្តបាននឹងត្រូវស៊ើបអង្កេត ជាបន្ទាន់ ដោយហ្មត់ចត់ និងរក្សាជាការសំងាត់ ដោយការិយាល័យអគ្គសវនករ និងដោយនាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រងដែលអាចប្រើប្រាស់អ្នកជំនាញការនៅក្នុង ឬមកពីក្រៅធនាគារអភិវឌ្ឍន៍អាស៊ី តាមការចាំបាច់ ។ អនុលោមតាមនីតិវិធីវិន័យចែងក្នុងបទបញ្ជារដ្ឋបាល លេខ ២.០៤ បុគ្គលិកដែលមានកំហុសក្នុងការប្រព្រឹត្តឥរិយាបទបែបនេះ នឹងត្រូវទទួលការដាក់ទណ្ឌកម្មមួយចំនួន រួមមានទាំងការផ្លាស់ប្តូរតួនាទី ការទម្លាក់ឋានៈ ការព្យួរការងារដោយឥតប្រាក់បៀវត្សរ៍ ការឱ្យសងនិង/ឬការបាត់សិទ្ធិទទួលប្រាក់បំណាច់ ការបញ្ឈប់ពីការងារ និងការបណ្តេញ ចេញពីការងារ[៣១] ការដាក់ទណ្ឌកម្មទាំងនេះអនុវត្តដោយស្មើភាពគ្នាក្នុងគ្រប់ស្ថានភាព ដែលបុគ្គលិកបង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួនដោយពុំត្រឹមត្រូវ និងពុំស្របច្បាប់ និង/ឬសម្រាប់បណ្តាអ្នកពាក់ព័ន្ធជិតស្និទ្ធ និងចំពោះកាលៈទេសៈដែលបុគ្គលិកទាំងនោះអន្ទងអ្នកដទៃឱ្យប្រព្រឹត្ត ។

៧៣. ដើម្បីពង្រឹងការយល់ដឹងរបស់បុគ្គលិក ការិយាល័យយុទ្ធសាស្ត្រនិងគោលនយោបាយ ការិយាល័យអគ្គក្រុមប្រឹក្សា ការិយាល័យអគ្គសវនករ និងនាយកដ្ឋានថវិកាបុគ្គលិក និងប្រព័ន្ធគ្រប់គ្រង នឹងត្រូវសហការគ្នាក្នុងការចាត់ចែងបើកសិក្ខាសាលាក៏ដូចជាវគ្គបណ្តុះបណ្តាល ដើម្បីផ្តល់ពត៌មានដល់បុគ្គលិកអំពីគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងដើម្បីដោះស្រាយបញ្ហានានា និងបណ្តាជម្រើសដែលពាក់ព័ន្ធនឹងការជួយដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិកក្រុមហ៊ុនផ្គត់ផ្គង់ និងភាគីម៉ៅការ ក្នុងការប្រឆាំងអំពើពុករលួយ ។

---

[២៨] Asian Development Bank. 1995. *Report of the Task Force on Improving Project Quality.* Manila, pp. 22–26.

[២៩] ធនាគារអភិវឌ្ឍន៍អាស៊ីនឹងចេញគោលកាណ៍ណែនាំសម្រាប់អនុវត្តគោលនយោបាយប្រឆាំងអំពើពុករលួយដែលស្នើឡើងនេះ ។ មុននឹងចេញគោលការណ៍ណែនាំនេះ បណ្តាបុគ្គលិកត្រូវពិនិត្យ រកមើលវិធី ដែលកិច្ចប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី អាចនឹងសំរបសម្រួល និងអាចដាក់បញ្ចូលបន្ថែមនូវបណ្តាវិធានការដែលមានប្រសិទ្ធភាពខាងផ្នែកសេដ្ឋកិច្ច សម្រាប់តាមដាន និង ដឹកនាំការគ្រប់គ្រងគម្រោង ។

[៣០] ឧទាហរណ៍ដ៏ល្អមួយ អំពីរបៀបដែលប្រធានបទនៃអំពើពុករលួយអាចដោះស្រាយដោយឥតលាក់លៀមនិងតាមរបៀបការទូតនៅក្នុងឯកសាររបស់ ធនាគារអភិវឌ្ឍន៍អាស៊ី សូមអាន : Post Evaluation Office. 1997. *Special Study on Issues Pertaining to the Engagement of Consultants in Bank Loan Projects and Their Effect on Project Performance*. ADB, Manila.

[៣១] ជំពូកទី 5 នៃបទបញ្ជារដ្ឋបាលលេខ 2.04 បើកឱកាសឱ្យមាននីតិវិធីបណ្តឹងឧទរណ៍ ទៅគណកម្មការដោះស្រាយថ្នាក់ឧទរណ៍ និងចុងក្រោយបំផុតទៅសាលាជំរះក្តីរដ្ឋបាល ។

# VI. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

៧៤. ឯកសារនេះលើកស្នើនូវវិធានការដាក់លាក់មួយចំនួន សម្រាប់កសាងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រឆាំងនឹងអំពើពុករលួយ ។ វិធានការទាំងនេះអាចចែកចេញជាបីផ្នែកសំខាន់ៗដូចតទៅ : សំណើកែសម្រួលគោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី គំនិតផ្តួចផ្តើមលើការគ្រប់គ្រងគម្រោង និងការបង្កើតកម្មវិធីថ្មី និងការកែប្រែផ្នែករដ្ឋបាលផ្ទៃក្នុង ។

៧៥. អនុសាសន៍គោលនយោបាយខាងក្រោមនេះ ត្រូវបានដាក់ជូនទៅក្រុមប្រឹក្សាភិបាល សម្រាប់ការពិចារណា និងអនុម័ត :

(i) ទទួលយករបៀបដោះស្រាយ និងអនុសាសន៍ដែលមាននៅក្នុងឯកសារនេះ ដោយចាត់ទុកជាឯកសារគោលនយោបាយ និងជាសេចក្តីបង្គាប់ការគ្រប់គ្រង ក្រោមរូបភាពជាបទបញ្ជាសម្រាប់បុគ្គលិក ។

(ii) អនុម័តលើការសេចក្តីកែសម្រួលគោលការណ៍លទ្ធកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងស្តីពីការប្រើប្រាស់ទីប្រឹក្សា ព្រមទាំងសំណើវិសោធនកម្មលើបទបញ្ជាទូទៅ និងពិសេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការប្រតិបត្តិក្នុងផ្នែកផ្តល់ប្រាក់កម្ចី ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ និង ៣ ។

(iii) ពិចារណាលើការកែប្រែជាបន្ថែមលើ *បទបញ្ជារដ្ឋបាលសម្រាប់គម្រោង* និង*សៀវភៅណែនាំស្តីពីការផ្តល់ប្រាក់កម្ចី* ដើម្បីពង្រឹងការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ និងកែលម្អនីតិវិធីធ្វើរបាយការណ៍ ។

៧៦. ឯកសារនេះលើកស្នើឱ្យមានការកែប្រែមួយចំនួនដូចខាងក្រោម នៅក្នុងការរៀបចំកម្មវិធី និងការគ្រប់គ្រងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី :

(i) បន្តពង្រីកជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់បញ្ហាអភិបាលកិច្ច និងការកសាងសមត្ថភាព ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះការជំរុញសេរីភាវូបនីយកម្មទីផ្សារ និងកែទម្រង់រដ្ឋបាលសាធារណៈ ។

(ii) ផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការពង្រឹងស្ថាប័នគន្លឹះនានា ដើម្បីបង្កើតតម្លាភាព និងការទទួលខុសត្រូវនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក (ដូចជាស្ថាប័នសវនកម្មកំពូល ស្ថាប័នលទ្ធកម្ម ស្ថាប័ននីតិ បញ្ញត្តិ ការិយាល័យត្រួតពិនិត្យ ។ល។) ដែលជាចំណែកមួយនៃការយកចិត្តទុកដាក់រួមរបស់ធនាគារក្នុងផ្នែកអភិបាលកិច្ច និង ការកសាងសមត្ថភាព ។

(iii) ក្នុងករណីសមស្រប គាំទ្រគំនិតផ្តួចផ្តើម និងស្រាវជ្រាវថ្នាក់តំបន់ លើការពង្រឹងកិច្ចទទួលខុសត្រូវ និងតម្លាភាពក្នុងតំបន់អាស៊ី និងមហាសាគរប៉ាស៊ីភិច តាមរយៈជំនួយបច្ចេកទេសឥតសំណង ។

(iv) លើកកម្ពស់គុណភាពដឹកនាំគ្រប់គ្រងក្នុងពេលអនុវត្តគម្រោង និងពង្រឹងឱ្យមានបេសកកម្មត្រួតពិនិត្យការអនុវត្តគម្រោង ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះបណ្តាគម្រោងដែលមានលក្ខណៈប្រថុយប្រថានកម្រិតខ្ពស់ ។

(v) បង្កើតឱ្យមានការបណ្តុះបណ្តាល និងសិក្ខាសាលានានា ស្តីពីគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការប្រឆាំងអំពើពុករលួយ និងវិធីដែលបុគ្គលិកអាចជំរុញភាពសុចរិតក្នុងប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងក្នុងការងារសហប្រតិបត្តិការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ។

(vi) បោះពុម្ពផ្សាយកូនសៀវភៅងាយៗ និងឯកសារពត៌មាននានា ដែលអធិប្បាយអំពីគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រឆាំងអំពើពុករលួយ សម្រាប់ចែកផ្សព្វផ្សាយជាសាធារណៈ ។

៧៧. ចំណុចចុងក្រោយនៃឯកសារនេះ ស្នើឱ្យមានការកែប្រែផ្នែករដ្ឋបាលក្នុងកិច្ចប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងកម្រិតការិយាល័យ/នាយកដ្ឋាន :

(i) ពង្រឹងការអនុវត្តន៍គោលការណែនាំបច្ចុប្បន្នស្តីពីលទ្ធកម្មឱ្យបានម៉ឺងម៉ាត់ ដើម្បីជៀសវាងការពន្យារពេលការសុំបន្តពេល និងការកែប្រែចំនុចនានាក្នុងគម្រោងផ្សេងពីលំនាំដើមខ្លាំងពេក ។

(ii) តែងតាំងការិយាល័យអគ្គសវនករចំនុចចាប់ផ្តើម សម្រាប់ធ្វើទំនាក់ទំនងទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ ក្នុងចំណោមគម្រោង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងចេញបញ្ជាឱ្យការិយាល័យនេះរៀបចំនីតិវិធីសមស្រប សម្រាប់បំពេញករណីកិច្ចបែបនេះដោយពិគ្រោះយោបល់ជាមួយនាយកដ្ឋានពាក់ព័ន្ធនៃធនាគារអភិវឌ្ឍន៍អាស៊ី ។

(iii) ដោយឆ្លងតាមការពិគ្រោះយោបល់ជាមួយនាយកដ្ឋានថវិកា បុគ្គលិកនិងប្រព័ន្ធគ្រប់គ្រងពិចារណាលើលទ្ធភាពបន្ថែមបុគ្គលិកក្នុងការិយាល័យអគ្គសវនករ ដើម្បីឱ្យការិយាល័យនេះមានសមត្ថភាពបំពេញការទទួលខុសត្រូវតាមគោលនយោបាយនេះ ឱ្យបានប្រសើរជាងមុន ។

(iv) ដោយឆ្លងតាមការពិគ្រោះយោបល់ជាមួយនាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង និងការិយាល័យប្រតិបត្តិ សេវាកម្មកណ្តាល ពិចារណាវិធីដែលមានប្រសិទ្ធភាពខាងផ្នែកសេដ្ឋកិច្ច ដើម្បីប្រើប្រាស់ក្នុងកិច្ចពង្រឹងការងារ តាមដាន និងដឹកនាំគ្រប់គ្រងគម្រោង និងស្វែងរកធនធានជាបន្ថែមទៀតដែលអាចត្រូវការចាំបាច់សម្រាប់បំពេញកិច្ចការទាំងនេះ ។

(v) ដាក់បញ្ជាឱ្យការិយាល័យអគ្គសវនករ និងនាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង សហការគ្នាក្នុងការរៀបចំការបណ្តុះបណ្តាលស្តីពីនីតិក្រមគណនេយ្យ និងបច្ចេកទេសស៊ើបអង្កេតនានា ដើម្បីជ្រើសរើសបុគ្គលិកសម្រាប់ការិយាល័យ អគ្គសវនករ អ្នកវិភាគហិរញ្ញវត្ថុ និងមន្ត្រីអនុវត្តគម្រោង ។

(vi) ដាក់បញ្ជាឱ្យការិយាល័យអគ្គសវនករ និងនាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង ឱ្យរៀបចំសិក្ខាសាលានិង/ឬ សកម្មភាពក្រៅផ្លូវការផ្សេងៗទៀតនៅកម្រិតអន្តរជាតិ ដើម្បីជូនពត៌មានដល់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី អំពីការកែប្រែនៅក្នុងបទបញ្ជារដ្ឋបាលលេខ ២០.២ ជំពូក ៤ ស្តីពីក្រមប្រតិបត្តិរបស់បុគ្គលិក ដែលទទួលការអនុម័តដោយក្រុមប្រឹក្សាគ្រប់គ្រង នៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៨ ។

៧៨. ដើម្បីតាមដាន និងសំរបសម្រួលកិច្ចប្រឹងប្រែងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទាក់ទងនឹងគំនិតផ្តួចផ្តើម និងការរៀបចំកម្មវិធីប្រឆាំងអំពើពុករលួយ នាយកដ្ឋាន និងបុគ្គលិកពាក់ព័ន្ធនឹងត្រូវតែផ្តល់ដល់ការិយាល័យយុទ្ធសាស្ត្រនិងគោលនយោបាយ ការិយាល័យអគ្គសវនករ និង ការិយាល័យអគ្គក្រុមប្រឹក្សាភិបាល នូវឯកសារស្តីពីក្របខ័ណ្ឌច្បាប់ និងបញ្ហាច្បាប់ពាក់ព័ន្ធនឹងបណ្តុសកម្មភាពនានាដទៃទៀត ដោយត្រូវមានការវាយតម្លៃជាទៀងទាត់អំពីវិធីសម្រាប់អនុវត្តបណ្តាខដែលមានចែងក្នុងគោលនយោបាយ ។

៧៩. ក្រោយពេលដែលក្រុមប្រឹក្សាភិបាលអនុម័តគោលនយោបាយប្រតិបត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីបញ្ហាប្រឆាំងអំពើពុករលួយរួចមក ឯកសាររបស់ក្រុមប្រឹក្សាភិបាលនេះនឹងត្រូវចែកផ្សាយតាមកាលកំណត់ ដើម្បីវិភាគលើបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីលើគោលនយោបាយប្រឆាំងអំពើពុករលួយ ស្នើឱ្យមានការកែប្រែវិធីសាស្ត្រប្រតិបត្តិតាមការចាំបាច់ និងការប៉ាន់ប្រមាណថវិកា និងធនធានចាំបាច់ដទៃទៀតឱ្យបានជាក់លាក់ជាងមុន ។

# VIII. ឧបសម្ព័ន្ធ

១ ការអធិប្បាយលម្អិតអំពីគំនិតផ្តួចផ្តើមលើអភិបាលកិច្ច និងការកសាងសមត្ថភាព ដែលមានសមាសភាគប្រឆាំងអំពើពុករលួយ

២ សំណើកែប្រែនៅក្នុងគោលការណ៍ណែនាំស្តីពីសវនកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ

៣ សំណើវិសោធនកម្មចំពោះបទបញ្ជាទូទៅ និងបទបញ្ជាពិសេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីការប្រើប្រាស់ប្រាក់កម្ចី

ឧបសម្ព័ន្ធ ១

# ការអធិប្បាយលម្អិតអំពីគំនិតផ្តួចផ្តើមលើអភិបាលកិច្ច និងការកសាងសមត្ថភាព ដែលមានសមាសភាគប្រឆាំងអំពើពុករលួយ

| ស្ថាប័នគោលដៅ | ប្រភេទអន្តរាគមន៍ | ឧទាហរណ៍ |
|---|---|---|
| ស្ថាប័នប្រតិបត្តិ<br>គណ:កម្មការសេវាកម្មស៊ីវិល | • កែប្រែប្រាក់បៀវត្សរ៍ និងប្រាក់ឧបត្ថមនានាដើម្បីធានាភាពអាចប្រៀបធៀបគ្នាបានជាមួយជំរើសផ្សេងទៀតនៃឱកាស ក្នុងការជ្រើសរើសការងារ<br>• ពង្រឹងវិធានការសម្រាប់បង្កើតការតាមដាន និងត្រួតពិនិត្យ<br>• រៀបចំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវក្រមសីលធម៌ សេវាកម្មស៊ីវិល | TA 2616 ផ្តល់ដល់ប្រទេសសេរីលង្កា សម្រាប់ធ្វើការកែទម្រង់រដ្ឋបាលសាធារណ: |
| ក្រសួងហិរញ្ញវត្ថុ/ក្រសួង អភិវឌ្ឍន៍ | • ពង្រឹងកិច្ចត្រួតពិនិត្យការគ្រប់គ្រង និងប្រព័ន្ធពត៌មាន<br>• ពង្រឹងការតាមដាន និងត្រួតពិនិត្យការចំណាយ | TA 2538 ការលើកស្ទួយកិច្ចការ គ្រប់គ្រងថវិកាក្នុងប្រទេសមីក្រូនេស៊ី<br>Loan 1506 សម្រាប់រដ្ឋគុជរាដប្រទេស ឥណ្ឌា ក្នុងកម្មវិធីគ្រប់គ្រងធនធាន ស្ថាប័នសាធារណ: |
| | • គាំទ្រការពង្រឹងគោលការណ៍លទ្ធកម្ម | TA 2701 ការពង្រឹងស្ថាប័នក្នុង ការិយាល័យជាតិ ទទួលបន្ទុកវាយតម្លៃលទ្ធកម្មនៅប្រទេសវៀតណាម |
| ក្រសួង ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធនានា | • សម្របសម្រួលនិងបង្កើតឡើងវិញនូវដំណើរការជំនួញ ដើម្បីកាត់បន្ថយឱកាសសូកប៉ាន់សម្រាប់ការជួយសម្រួលកិច្ចការរដ្ឋបាល | TA 2186 ការពង្រឹងក្របខ័ណ្ឌច្បាប់ សម្រាប់ផ្នែករដ្ឋបាលក្នុងទីចាត់ការគយ នៅសាធារណរដ្ឋប្រជាមានិតចិន |
| **ស្ថាប័ននីតិបញ្ញត្តិ**<br>ស្ថាប័នសវនកម្មកំពូល | • រៀបចំវិធានការដើម្បីធ្វើឱ្យទំនាក់ទំនងរវាងស្ថាប័ន និងប្រជាពលរដ្ឋមានតម្លាភាព និងមានភាពងាយស្រួលជាងមុន ដូចជាប្រើផ្លាកឈ្មោះ ការតម្រូវឱ្យចងក្រងរាល់កំណត់ហេតុ ទុកជាឯកសារ ការតម្រូវឱ្យបង់ប្រាក់តាមកាលកំណត់ ។ល ។ | TA 2459 ជំនួយបច្ចេកទេសដល់ ប្រទេសនេប៉ាល់សម្រាប់បង្កើនប្រសិទ្ធភាព នៃការប្រតិបត្តិរបស់ស្ថាប័នគយ |
| | • លើកកម្ពស់សមត្ថភាព និងឯករាជ្យភាពនៃ ស្ថាប័នសវនកម្មកំពូល | RETA 5688 កម្មវិធីបណ្តុះបណ្តាលសវនកម្មប្រចាំ តំបន់សម្រាប់រយ:ពេលវែងសម្រាប់បណ្តសមាជិកនៃ អង្គការស្ថាប័នសវនកម្មកំពូលនៅអាស៊ី<br>TA 2463 សម្រាប់ពង្រឹងស្ថាប័ននៃការិយាល័យអគ្គសវនករនៅប្រទេសហ្វីជី |
| ស្ថាប័នស្រាវជ្រាវសភា | • ពង្រឹងសមត្ថភាពសភាដើម្បីបំពេញនាទី តាមដានដោយឯករាជ្យ | USAID/CRS កិច្ចប្រឹងប្រែងដើម្បីពង្រឹង សមត្ថភាពសភាក្នុងដំណាក់កាលសេដ្ឋកិច្ចអន្តរកាល |
| ការិយាល័យអធិការកិច្ច ។ល ។ | • ពង្រឹងសិទ្ធិឯករាជ្យភាពរបស់ប្រជាពលរដ្ឋ ក្នុងការជួយកែតម្រូវអំពើអយុត្តិធម៌ | TA 2599 ការអនុវត្តកិច្ចការកែទម្រង់ស៊ីវិលសម្រាប់ កោះម៉ារសាល់ គម្រោង UNDP អំពីការសំរបសម្រួលគោល នយោបាយ និងអភិបាលកិច្ចនៅប៉ាស៊ីភិចខាងត្បូង |
| **ស្ថាប័នតុលាការ**<br>កាត់បន្ថយការពន្យាពេលជំរះក្តី | • បង្កើតយន្តការថ្មីៗសម្រាប់ដោះស្រាយទំនាស់ ដោយរបៀបផ្សេង | TA 2779 សម្រាប់យន្តការថ្មីដើម្បីដោះស្រាយទំនាស់ដោយរបៀបផ្សេងនៅប្រទេសឥណ្ឌា |
| ពង្រឹងស្ថាប័នបឋម : ស្ថាប័នតុលាការ និងក្រសួងយុត្តិធម៌ | • បន្តការអប់រំសម្រាប់ចៅក្រម និងមេធាវី | TA 2727 កំណែទម្រង់រចនាសម្ព័ន្ធ និងកសាង សមត្ថភាព ក្នុងក្រសួងយុត្តិធម៌នៃប្រទេសម៉ុងគោលី |
| ពង្រឹងស្ថាប័នមធ្យម : សាលាច្បាប់ និងការស្រាវជ្រាវផ្នែកច្បាប់នៅ មូលដ្ឋាន | • ការបញ្ចូលប្រព័ន្ធគ្រប់គ្រងតុលាការ និង ប្រព័ន្ធពត៌មានថ្មីទាន់សម័យ | |
| **សង្គមស៊ីវិល**<br>ក្រុមប្រឹក្សាជំនួញ-រដ្ឋាភិបាល | • ផ្តល់ប្រព័ន្ធទាក់ទងរវាងអ្នកជំនួញ និង រដ្ឋាភិបាលលើបញ្ហាទូទៅស្តីពីអភិបាលកិច្ចល្អ | |

ឧបសម្ព័ន្ធ ២

# សំណើកែប្រែនៅក្នុងគោលការណ៍ណែនាំស្តីពីសវនកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទាប់ទងនឹងការប្រឆាំងអំពើពុករលួយ [៣៨]

ដើម្បីធានាឱ្យដើរទាន់ការវិវត្តន៍នៃក្រុមអនុវត្តន៍ប្រសើរបំផុតក្នុងចំណោមបណ្ដាធនាគារអភិវឌ្ឍន៍ពហុភាគីជំពូក ២.១៤ ២.១៥ និង ២.១៦ នៃគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវកែសម្រួលដូចខាងក្រោម :

## ការគៃបន្លំ និងអំពើពុករលួយ

២.១៤ គោលការណ៍របស់ធនាគារអភវឌ្ឍន៍អាស៊ីតម្រូវឱ្យបណ្ដាភាគីខ្ចីឥណទាន (រួមទាំងបណ្ដាអ្នកទទួលប្រយោជន៍ពីប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី) ក៏ដូចជាក្រុមហ៊ុនដេញថ្លៃ/ក្រុមហ៊ុនផ្គត់ផ្គង់/ភាគីម៉ៅការ ដែលស្ថិតនៅក្រោមកិច្ចសន្យាផ្ដល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍ អាស៊ីគោរពនូវបទដ្ឋានសីលធម៌ការងារខ្ពស់បំផុត ក្នុងពេលលទ្ធកម្ម និងប្រតិបត្តិកិច្ចសន្យាទាំងនោះ ។ អនុលោមតាម គោលនយោបាយនេះធនាគារអភិវឌ្ឍន៍អាស៊ី :

(ក) កំណត់ សម្រាប់គោលបំណងនៃខដែលមានចែងនៅទីនេះ នូវនិយមន័យនៃបណ្ដាពាក្យដូចតទៅ :

(i) "ការប្រព្រឹត្តអំពើពុករលួយ" មានន័យថា ជាឥរិយាបទនៃមន្ត្រីនៅក្នុងស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ដែលប្រព្រឹត្តមិនត្រឹមត្រូវ និងខុសច្បាប់ ដើម្បីទាញយកនូវប្រយោជន៍ផ្ទាល់ខ្លួន និង/ឬសម្រាប់មនុស្សជិតស្និទ្ធ ឬអន្ទង អ្នកដទៃឱ្យប្រព្រឹត្តដូចនេះ ដោយប្រើប្រាស់ឋានៈរបស់ខ្លួនពុំត្រឹមត្រូវ ។ ហើយអំពើទាំងនោះរួមមាន ជំនូន ការផ្ដល់ឱ្យ ការទទួល ឬការសុំអ្វីម្យ៉ាងដែលមានតម្លៃ សំដៅដាក់ឥទ្ធិពលទៅលើសកម្មភាពរបស់មន្ត្រីទាំងនោះ នៅក្នុងដំណើរការលទ្ធកម្ម ឬនៅក្នុងអំឡុងពេលនៃការអនុវត្តន៍កិច្ចសន្យា ។

(ii) "ការប្រព្រឹត្តអំពើគៃបន្លំ" មានន័យថា ជាការកុហកបំភ្លៃខុសពីការពិតជាក់ស្ដែង ដើម្បីជំរុញឱ្យដំណើរការលទ្ធកម្ម ឬការប្រតិបត្តិកិច្ចសន្យាបង្កនូវការខូចខាតដល់ភាគីខ្ចីឥណទាន ហើយរួមមានការសុំគ្រលំរវាងអ្នកចូលរួមដេញថ្លៃ (មុន ឬក្រោយពេលដាក់ពាក្យសុំដេញថ្លៃ) ក្នុងគោលបំនងបង្កើតតម្លៃនៃការដេញថ្លៃក្លែងក្លាយ ដោយពុំមានការប្រកួតប្រជែងពិតប្រាកដ និងធ្វើឱ្យភាគីខ្ចីឥណទានបាត់បង់ផលប្រយោជន៍ ដោយសារពុំមានការប្រកួតប្រជែងដោយសេរី និងចំហ ។

(ខ) នឹងបដិសេធសំណើផ្ដល់កិច្ចសន្យា ប្រសិនបើធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថាក្រុមហ៊ុនដេញថ្លៃដែលបានស្នើឱ្យផ្ដល់កិច្ចសន្យា មានការពាក់ព័ន្ធក្នុងអំពើពុករលួយ ឬការគៃបន្លំនៅក្នុងការប្រកួតប្រជែងដេញថ្លៃ ។

(គ) នឹងលុបចោលផ្នែកណាមួយនៃគម្រោងប្រាក់កម្ចី ដែលបម្រុងទុកសម្រាប់ចុះកិច្ចសន្យាផ្ដល់សំភារៈ ឬការងារ ប្រសិនបើនៅពេលណាមួយធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថា អំពើពុករលួយ ឬគៃបន្លំ ត្រូវប្រព្រឹត្តដោយបណ្ដាអ្នកជាតំណាងភាគីខ្ចីឥណទាន ឬដោយបណ្ដាក្រុមអ្នកទទួលប្រយោជន៍ពីប្រាក់កម្ចីនេះ នៅក្នុងដំណើរការលទ្ធកម្ម ឬការប្រតិបត្តិកិច្ចសន្យានោះ ហើយភាគីខ្ចីឥណទានពុំបានចាត់វិធានការទាន់ពេលវេលា និងសមស្រប ដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចទទួលយកបានក្នុងការកែខៃសភាពការណ៍នោះ ។

(ឃ) នឹងប្រកាសយ៉ាងដាច់អហង្ការនូវការដកហូតសិទ្ធិជារៀងរហូត ឬសម្រាប់ចន្លោះពេលណាមួយជាកំណត់ក្នុងការទទួលកិច្ចសន្យាផ្ដល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើនៅពេលណាក៏ដោយ ធនាគារនេះរកឃើញថាក្រុមហ៊ុននោះមានពាក់ព័ន្ធនឹងអំពើពុករលួយ ឬគៃបន្លំ នៅក្នុងការប្រជែងដេញថ្លៃ ឬក្នុងពេលប្រតិបត្តិកិច្ចសន្យាដែលផ្ដល់ហិរញ្ញវត្ថុដោយធនាគារ អភិវឌ្ឍន៍អាស៊ី ។ និង

(ង) នឹងមានសិទ្ធិទាមទារឱ្យចែងនៅក្នុងកិច្ចសន្យាដែលផ្ដល់ឥណទានហិរញ្ញវត្ថុដោយធនាគារពិភលោក នូវខដែលតម្រូវឱ្យក្រុមហ៊ុនផ្គត់ផ្គង់ និងភាគីម៉ៅការ អនុញ្ញាតឱ្យធនាគារអភិឌ្ឍន៍អាស៊ីត្រួតពិនិត្យលើគណនេយ្យ និងរាល់កំណត់បញ្ជីទាក់ទងនឹងការអនុវត្តកិច្ចសន្យា ព្រមទាំងធ្វើសវនកម្មលើគណនេយ្យ និងបញ្ជីទាំងនោះ ដោយសវនករដែលជ្រើសរើសដោយធនាគារអភិឌ្ឍន៍អាស៊ី ។

---

[៣៨] បណ្ដាខប្រហែលគ្នានេះដែរនឹងត្រូវបញ្ចូលបន្ថែមទៅក្នុង *គោលការណ៍ណែនាំស្តីពីការជួលទីប្រឹក្សាដោយធនាគារអភិវឌ្ឍន៍អាស៊ី និងបណ្ដាភាគីអ្នកខ្ចីឥណទានរបស់ខ្លួន* របស់ធនាគារ អភិវឌ្ឍន៍អាស៊ី ។

២.១៥ ចំពោះកិច្ចសន្យាផ្តល់ហិរញ្ញវត្ថុជាទ្រង់ទ្រាយធំដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដោយមានកិច្ចព្រមព្រៀងជាពិសេសជាមួយធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការប្រកួតប្រជែងយកសិទ្ធិអនុវត្តកិច្ចសន្យា ភាគីខ្ចីឥណទាន អាចដាក់បញ្ចូលទៅក្នុងពាក្យសុំដេញថ្លៃនូវលក្ខខណ្ឌឱ្យអ្នកចូលដេញថ្លៃគោរពតាមបណ្តូច្បាប់ក្នុងស្រុក ប្រឆាំងនឹងអំពើគៃបន្លំ និងអំពើពុករលួយ (រួមទាំងការស៊ីសំណូក) ដូចដែលមានចែងនៅក្នុងឯកសារដាក់ដេញថ្លៃ ។ លេខយោងសម្គាល់មួយនឹងត្រូវដាក់នៅក្នុងឯកសារដេញថ្លៃ ដោយបញ្ជាក់ថា លក្ខខណ្ឌទាំងនេះត្រូវបានដាក់បញ្ចូលតាមសំណើរបស់ភាគីខ្ចីឥណទាន ។

២.១៦ ក្នុងករណីដែលកិច្ចសន្យាត្រូវផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ីទាំងស្រុង ឬដោយផ្នែក នៅក្នុងឯកសារកិច្ចសន្យាត្រូវមានដាក់បញ្ចូលការសន្យាដោយភាគីម៉ៅការថាពុំមានខ្ទង់ចំណាយជាប្រាក់កម្រៃ ប្រាក់ទឹកតែ ការបង្វិលប្រាក់សង អំណោយ កម្រៃជើងសារឬការចំណាយណាផ្សេងទៀត ដែលពុំមានចែងក្នុងឯកសារដេញថ្លៃ នឹងត្រូវផ្តល់ឱ្យ ឬទទួលយក ពាក់ព័ន្ធជាមួយដំណើរការដេញថ្លៃ ឬក្នុងការប្រតិបត្តិកិច្ចសន្យាឡើយ ។

ឧបសម្ព័ន្ធ ៣

# សំណើវិសោធនកម្មចំពោះបទបញ្ញាទូទៅ និងបទបញ្ញាពិសេស ស្តីពីការប្រើប្រាស់ប្រាក់កម្ចី

ជំពូកទី ៨.០៣ នៃបទបញ្ញាទូទៅស្តីពីការប្រើប្រាស់ប្រាក់កម្ចី និងបទបញ្ញាពិសេសស្តីពីការប្រើប្រាស់ប្រាក់កម្ចី នឹងត្រូវធ្វើវិសោធនកម្មដូចខាងក្រោម ។ ចំនុចដែលស្នើឱ្យមានការកែប្រែមានគូសបន្ទាត់ពីក្រោម :

ជំពូក ៨.០៣ **ការលុបចោលដោយធនាគារអភិវឌ្ឍន៍អាស៊ី** ។ ប្រសិនបើ (i) សិទ្ធិរបស់ភាគីខ្ចីឥណទានក្នុងការសុំដកប្រាក់ពីគណនេយ្យប្រាក់កម្ចីទាក់ទងនឹងប្រាក់កំចីក្នុងចំនួនណាមួយ ត្រូវព្យួរទុកសម្រាប់រយៈពេលសាមសិប (៣០) ថ្ងៃជាប់គ្នា ឬ (ii) នៅពេលណាមួយក្រោយពីមានការពិគ្រោះយោបល់ជាមួយភាគីខ្ចីឥណទាន ធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថាពុំមានចំនួនទឹកប្រាក់ក្នុងបរិមាណណាមួយដែលត្រូវការចាំបាច់ សម្រាប់ប្រើប្រាស់ក្នុងគោលបំណងនៃគម្រោងទេ ឬ (iii) នៅពេលណាមួយធនាគារ រកឃើញថាមានការប្រព្រឹត្តិអំពើពុករលួយ ឬគៃបន្លំពាក់ព័ន្ធ នឹងកិច្ចសន្យាណាមួយដែលផ្តល់ហិរញ្ញវត្ថុដោយផ្នែកណាមួយនៃប្រាក់កម្ចី ដោយបណ្តាអ្នកតំណាងរបស់ភាគីខ្ចីឥណទាន ឬដោយអ្នកទទួលប្រយោជន៍ពីគម្រោងប្រាក់កម្ចីនេះ នៅក្នុងពេលធ្វើលទ្ធកម្ម/ការជ្រើសរើសទីប្រឹក្សា ឬក្នុងពេលអនុវត្តកិច្ចសន្យានេះ ហើយភាគីខ្ចីឥណទានពុំបានចាត់វិធានការកែខៃសភាពការណ៍ឱ្យបានទាន់ពេល និងសមស្រប ដែលអាចទទួលយកបានដោយធនាគារអភិវឌ្ឍន៍អាស៊ី ឬ (iv) នៅពេលណាមួយធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថា លទ្ធកម្មសម្រាប់កិច្ចសន្យាណាមួយដែលត្រូវផ្តល់ហិរញ្ញវត្ថុដោយផ្នែកណាមួយនៃប្រាក់កម្ចីប្រព្រឹត្តទៅដោយមិនស្របគ្នា ជាមួយនីតិវិធីចែងនៅក្នុងកិច្ចសន្យាផ្តល់ប្រាក់កម្ចី ឬ (v) នៅពេលផុតកាលបរិច្ឆេទកំណត់សម្រាប់ការដកប្រាក់កម្ចី ដូចមានចែងនៅក្នុងកិច្ចសន្យាខ្ចីឥណទាន ចំនួនទឹកប្រាក់ដែលបានខ្ចីនៅតែពុំទាន់ត្រូវបានដកពីគណនេយ្យប្រាក់កម្ចី នោះធនាគារអភិវឌ្ឍន៍អាស៊ីអាចធ្វើសេចក្តីជូនដំណឹងទៅភាគីខ្ចីឥណទាន និង អ្នកធានា (ប្រសិនបើមាន) អំពីការបញ្ចប់សិទ្ធិរបស់ភាគីខ្ចីឥណទានក្នុងការដកប្រាក់តាមចំនួន ឬតាមកិច្ចសន្យា ។ ក្រោយពេលបានផ្តល់សេចក្តីជូនដំណឹងនេះហើយ ចំនួនទឹកប្រាក់កម្ចី ឬបរិមាណប្រាក់ពាក់ព័ន្ធដែលនៅសល់មិនបានប្រើប្រាស់ នឹងត្រូវលុបចោល ។

## សុចរិតភាព និងការប្រឆាំងអំពើពុករលួយ: ក្របខ័ណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្ររបស់យើង

ឯកសារបោះពុម្ពផ្សាយនេះ មានឯកសារចំនួន ២ របស់ធនាគារអភិវឌ្ឍន៍អាស៊ី: *គោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាព* (ខែ ឧសភា ឆ្នាំ ២០១០) និង *គោលនយោបាយប្រឆាំងអំពើពុករលួយ* (ខែ កក្កដា ឆ្នាំ ១៩៩៨)។

ការិយាល័យសុចរិតភាព និងប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការស៊ើបអង្កេតលើការចោទប្រកាន់អំពីអំពើគៃបន្លំ អំពើពុករលួយ ការបង្ខិតបង្ខំ ការសមគំនិត ទំនាស់ផលប្រយោជន៍ ការបន្ទុចបង្អាក់ និងការប្រព្រឹត្តមិនត្រឹមត្រូវ ដែលពាក់ព័ន្ធ ក្នុងសកម្មភាពដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដោយអនុលោមទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។




គោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីតម្រូវឱ្យគ្រប់ភាគីទាំងអស់ ដូចជា បុគ្គលិក អ្នកខ្ចី អ្នកទទួលផល អ្នកចូលរួមដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការ គោរពទៅតាមស្តង់ដាសីលធម៌វិជ្ជាជីវៈក្នុង កម្រិតខ្ពស់បំផុត នៅពេលដែលពួកគេចូលរួមនៅក្នុងសកម្មភាព ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ គោលនយោបាយនេះគាំទ្រដល់កាតព្វកិច្ច របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីធានាយ៉ាងណាឱ្យថវិកា ដែលបានមកពីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានប្រើប្រាស់ តែសម្រាប់គោលបំណងដែលានគ្រោងទុកតែប៉ុណ្ណោះ ដោយអនុលោមទៅតាមមាត្រាទី ១៤ (xi)។

ឯកសារបោះពុម្ពផ្សាយនេះជំនួសឱ្យកំណែទីមួយនៃ *គោលនយោបាយសុចរិតភាព និងប្រឆាំងអំពើពុករលួយ* (សូមមើលខាងស្តាំ) ទាំងស្រុងតែម្តង។

## អំពីធនាគារអភិវឌ្ឍន៍អាស៊ី

ចក្ខុវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺតំបន់អាស៊ី និងប៉ាស៊ីហ្វិចមួយ ដែលពុំមានភាពក្រីក្រ។ បេសកកម្មរបស់ធនាគារនេះ គឺដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍជាសមាជិករបស់ខ្លួន នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋរបស់ខ្លួន។ បើទោះបីជាតំបន់នេះទទួលបានជោគជ័យយ៉ាងច្រើនក៏ដោយ ក៏តំបន់នេះមានប្រជាពលរដ្ឋក្រីក្រប្រមាណពីរភាគបី នៃប្រជាពលរដ្ឋក្រីក្រ នៅក្នុង ពិភពលោក: ១,៨ ពាន់លាននាក់ ដែលរស់នៅជាមួយនឹងចំណូលតិចជាង ២ ដុល្លារ ក្នុងមួយថ្ងៃ ហើយ ៩០៣ លាននាក់ កំពុងតស៊ូជាមួយនឹងចំណូលតិចជាង ១,២៥ ដុល្លារ ក្នុងមួយថ្ងៃ។

ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាចិត្តកាត់បន្ថយភាពក្រីក្រ តាមរយៈកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា កំណើនដែលធានានិរន្តរភាពបរិស្ថាន និងសមាហរណកម្មថ្នាក់តំបន់។

ដោយមានការិយាល័យនៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាកម្មសិទ្ធិរបស់ប្រទេសចំនួន ៦៧ ដែលក្នុងនោះមាន ៤៨ ប្រទេស មកពីតំបន់នេះ។ ឧបករណ៍សំខាន់បំផុតរបស់ធនាគារនេះ ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក របស់ខ្លួន រួមមាន កិច្ចពិគ្រោះយោបល់គោលនយោបាយ កម្ចី ការវិនិយោគលើមូលធន ការធានា ជំនួយឥតសំណង និងជំនួយបច្ចេកទេស។

Asian Development Bank
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
www.adb.org/indigenouspeoples
ISBN: 978-92-9092-428-9
លេខសម្គាល់នៃឯកសារ TIM114001

ISBN 978-92-9092-428-9

បោះពុម្ពដោយប្រើប្រាស់ក្រដាសកែច្នៃ